ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤០**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតូ គ្រីស្ពារ
*(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក រ៉ូប៊ឺត ពើទីត *(Mr. Robert Petit)*

លោក សេង ប៊ុនឃាង

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល *(Mr.Zachery LAMPEL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក យុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រីនណា

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកហ្វីន(ហ្សាកកាំង)

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

# សាក្សី

## លោក ឡាយ ចាន់

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ទំព័រ ២
សួរដោយ ចៅក្រម ធូ មណី ផ្ដើមពី ........ទំព័រ ១៩
សួរដោយ លោក យ៉េត ចរិយា ផ្ដើមពី ........ទំព័រ ២១
សួរដោយ លោក គីម ម៉េងឃី ផ្ដើមពី ........ទំព័រ ២៥
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្ដើមពី ........ទំព័រ ២៩
សួរដោយ លោក គង់ ពិសី ផ្ដើមពី ........ទំព័រ ៣១
សួរដោយ លោក ហុង គីមសួន ផ្ដើមពី ........ទំព័រ ៣៤
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី ........ទំព័រ ៣៧

## លោក តោគ ខន

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ទំព័រ ៤៥
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........ទំព័រ ៧៣
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ទំព័រ ៧៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ឡាយ ចាន់ | ខ្មែរ |
| លោក ភោគ ខន | ខ្មែរ |
| លោក អានីស អះម៉េត | អង់គ្លេស |
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| ចៅក្រម ធូ មណី | ខ្មែរ |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០១:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន ចំណែកឯបុគ្គលដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះដែរ ក៏មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

មុននឹងអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលត្រូវធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃនេះ អង្គជំនុំជម្រះសម្រេចលើពាក្យស្នើសុំរបស់មេធាវី ស្ទួតហ្សិនស្គី ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ដែលបានស្នើមកអង្គជំនុំជម្រះកាលពីព្រឹកម្សិលមិញ ដូចខាងក្រោម៖

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សំណើសុំរបស់មេធាវី ស្ទួតហ្សិនស្គី ជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ កាលពីព្រឹកថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៩ សុំបន្ថែមរយៈពេលកន្លះថ្ងៃទៀតក្នុងការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី E2-32 ដោយគិតពិចារណាទៅដល់ការជំនុំជម្រះមួយប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័ស ការកំណត់អំពីពេលវេលាសម្រាប់ស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬស្តាប់សក្ខីកម្មរបស់សាក្សីម្នាក់ៗ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីយូរថ្ងៃមកហើយ មិនមានការតវ៉ាឡើយ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចច្រានចោលនូវសំណើសុំរបស់មេធាវី ស្ទួតហ្សិនស្គី តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ដែលបានស្នើសុំបន្ថែមរយៈពេលកន្លះថ្ងៃទៀត ក្នុងការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី E2-32 ។

មន្ត្រីតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ ។

[០៩:០៥:៣៧]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកឈ្មោះអ្វីដែរលោក?

**លោក ឡាយ ចាន់៖**

**ឆ៖** សូមជម្រាបសួរលោកប្រធាន! ខ្ញុំឈ្មោះ ឡាយ ចាន់ ។

**ស៖** លោកមានឈ្មោះហៅផ្សេងក្រៅពី ចាន់ ដែរឬទេ?

**ឆ៖** សូមជម្រាបសួរលោកប្រធាន! ខ្ញុំឈ្មោះហៅក្រៅ បដិវត្តន៍គេហៅឈ្មោះខ្ញុំថា ឡាយ ថន ក៏ប៉ុន្តែ ប្រធានអង្គភាពរបស់ខ្ញុំច្រើនហៅតែ "អាម៉ាប់ៗ" ។

**ស៖** ដល់ឆ្នាំនេះ លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំនៅពេលបច្ចុប្បន្ននេះ គឺខ្ញុំអាយុ៥៥ឆ្នាំហើយ ។

**ស៖** សព្វថ្ងៃនេះលោកមានទីលំនៅនៅទីកន្លែងណា ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នៅពេលបច្ចុប្បន្ននេះ គឺរូបយើងខ្ញុំផ្ទាល់ គឺយើងខ្ញុំ បើនិយាយអំពីការកើតកំណើតពីរបស់ខ្ញុំបាទ គឺកើតភូមិវិហារចិន ឃុំសាលាកំរើក ស្រុកសៀមរាប និងខេត្តសៀមរាប ។

**ស៖** ទីលំនៅបច្ចុប្បន្ន បច្ចុប្បន្ននៅទីណា? ហើយប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នៅពេលបច្ចុប្បន្ននេះខ្ញុំបាទរស់នៅក្នុងភូមិគោកមន ឃុំដំដែក ស្រុកសូទ្រនិគម ជាមុខរបរជាកសិករ ។

**ស៖** នៅក្នុងរឿងក្តីនេះ គឺមានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅឌុច សំណួរសួរថា តើលោកបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ តើលោកប្តឹងទាមទារសំណងដោយផ្ទាល់ខ្លួនឯង ឬក៏ទុកសិទ្ធិក្នុងការប្តឹងទាមទារនេះទៅមេធាវីរបស់លោកក្នុងការប្តឹងទាមទារសំណង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺការប្តឹងដើមបណ្តឹងរដ្ឋប្បវេណី គឺខ្ញុំបាទផ្ទាល់ គឺមិនចង់បានអំពីសំណងផ្ទាល់ខ្លួនទេ ក៏ប៉ុន្តែសម្រេចទៅលើលោកមេធាវី ។

**ស៖** អ៊ីចឹងបានសេចក្តីថា ការប្តឹងទាមទារសំណងហ្នឹង គឺលោកប្រគល់សិទ្ធិទៅឲ្យមេធាវីរបស់លោកក្នុងការប្តឹងទាមទារសំណង អ៊ីចឹងមែនទេ?

**ឆ៖** ពិតប្រាកដមែន ។

[០៩:០៩:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអភ័យទោស ដែលខ្ញុំសូមកាត់លោកប្រធាន ដែលខ្ញុំគិតថា អាចនឹងមានប្រយោជន៍ ដែលថា នៅដំណាក់កាលនេះ ខ្ញុំសូមបញ្ជាក់ជូនតុលាការថា ជនជាប់ចោទបានបញ្ជាក់ពីការសង្ស័យថា បុគ្គលដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺថាគាត់សង្ស័យថា ទំនងជាមិនមែនធ្លាប់ជាប់ឃុំនៅ ស-២១ ទេ ។

**ប្រធានអង្គជំនុំ៖**

នោះជាសិទ្ធិរបស់ជនជាប់ចោទ។ ប៉ុន្តែ កិច្ចការដំណើរការនីតិវិធីរបស់តុលាការ ទោះបីនៅក្នុងករណីណាក៏ដោយ ត្រូវតែសួរដេញដោល ស្តាប់នូវសម្តីរបស់ភាគីដែលបានចូលរួមនៅក្នុងនីតិវិធី ហើយសួរហេតុផលទាំងឡាយ ទំនាក់ទំនងទៅនឹងអង្គហេតុ និងការគោរពសិទ្ធិក្នុងការចូលរួមរបស់គេ ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងពិចារណាសម្រេចថាតើគាត់ជាអ្នកជនរងគ្រោះ ឬក៏មិនមែននោះ ។ មិនមែនអត្តនោម័តិកណ្តាលទីអ៊ីចឹងទេ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកដែលបានដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង លោកមានទំនាក់ទំនងទៅនឹងអង្គហេតុណាមួយនៃអំពើដែលបានចោទប្រកាន់-- នៃបទល្មើសដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ដូចជាអង្គហេតុហ្នឹងដែលកើតឡើងនៅមន្ទីរណាមួយ នៅកន្លែងណាមួយ ដែលពាក់ព័ន្ធជាមួយនឹងរូបលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលយើងខ្ញុំបានដាក់ជាបណ្តឹងជូនមកតុលាការនេះ គឺខ្ញុំបាទធ្លាប់មានការរងគ្រោះ ដោយការភាន់ច្រឡំ ឬមួយយ៉ាងម៉េចនោះក៏ខ្ញុំពុំដឹងដែរ ។ នៅឆ្នាំ ១៩៧៦ គឺខ្ញុំបានរស់នៅនៅក្នុងអង្គភាព ៧០៥--

**ស៖** លោកឆ្លើយសំណួរឲ្យចំសិន ថាតើលោកមានការពាក់ព័ន្ធទៅនឹងអង្គហេតុណាមួយ ហើយទីកន្លែងណា? អំពើយ៉ាងម៉េចដែលប៉ះពាល់មកលើលោក ទើបលោកធ្វើការប្តឹងទាមទារ? ចំណែកប្រវត្តិ

នៃហេតុការណ៍ទាំងឡាយនាំឲ្យលោកមានការពាក់ព័ន្ធនឹងអង្គហេតុនោះ អង្គជំនុំជម្រះនឹងតាំងសំណួរលោកនៅសំណួរបន្ទាប់ទៀត ។

[០៩:១២:២៥]

**ផ:** គឺខ្ញុំបាទធ្លាប់បានចូលរួមក្នុងការធ្វើទុក្ខវេទនាចំពោះរូបខ្ញុំនៅឆ្នាំ១៩៧៦ ដោយគេធ្វើទារុណកម្មខ្ញុំបាទ ហើយខ្ញុំបាទក៏បានលាក់ទុកនៅក្នុងចិត្តរបស់យើងខ្ញុំរហូត លុះត្រាតែយើងខ្ញុំបានទទួលបាននូវការផ្សព្វផ្សាយអំពីសាលាក្តីនេះកើតឡើង យើងខ្ញុំបានដាក់ពាក្យបណ្តឹង ។

**ស:** លោកអះអាងថា គេធ្វើទារុណកម្មលោកកាលពីឆ្នាំ១៩៧៦ ហ្នឹង តើការធ្វើទារុណកម្មចំពោះលោកហ្នឹង គេប្រព្រឹត្តទៅនៅទីកន្លែងណា? ហើយនៅអំឡុងពេលណា?

**ផ:** ជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលខ្ញុំបាទបានចាប់ខ្លួន គឺខ្ញុំបាទពុំដឹងថា ខ្ញុំនៅកន្លែងណាទេ គឺនៅពេលដែលគេចាប់ គឺខ្ញុំបាទពុំបានដឹងអ្វីក្រៅពីគេចងមុខ រួចហើយគេដាក់លើឡានចេញមកទេ ។

**ស:** យើងចង់ដឹងថា-- លោកមិញអះអាងថាគេធ្វើទារុណកម្ម សំណួរសួរថា ទីតាំង ទីកន្លែងដែលគេបានធ្វើទារុណកម្មលោកនោះ នៅកន្លែងណាជាក់លាក់? ទីមួយ ។ ទីពីរ អំឡុងពេលធ្វើទារុណកម្មនុ៎ងប្រហែលជានៅក្នុងថ្ងៃខែឆ្នាំណា? បើមិនចាំថ្ងៃទេ មិនចាំខែទេ ក៏ចាំឆ្នាំដែរ ឬក៏អំឡុងពេលរយៈពេល បានន័យថានៅក្នុងឆ្នាំណាមួយជាក់លាក់ ហើយរយៈពេលនៃការធ្វើទារុណកម្មហ្នឹងគឺបីថ្ងៃ ដប់ថ្ងៃ ប្រាំថ្ងៃ គឺមានអំឡុងពេលមួយជាក់លាក់ ។ លោកអាចបញ្ជាក់បញ្ហានេះបានទេ ។ នេះជាចំណុចមូលដ្ឋាននៃអង្គហេតុដែលត្រូវពាក់ព័ន្ធទៅនឹងការដែលអះអាងរបស់លោក ។

**ផ:** ជម្រាបប្រសាសន៍លោក! នៅពេលដែលគេធ្វើទារុណកម្មខ្ញុំនោះ ខ្ញុំអត់ដឹងថាការធ្វើទារុណកម្មនោះខ្ញុំនៅកន្លែងណា គឺខ្ញុំអត់ដឹងដែរ ។ ក៏ប៉ុន្តែ នៅពេលដែលគេចងមុខខ្ញុំហើយ គេបណ្តើរខ្ញុំទាំងជាប់ចំណងបណ្តើរទៅ ហើយដល់តែពេលដល់កន្លែងសួរចម្លើយនោះ គឺគេពុំបានស្រាយមុខខ្ញុំទេ ។ ហើយក៏គេវ៉ៃធ្វើទារុណកម្មខ្ញុំ ដោយគេសួរហេតុផលថា មិត្តឯងធ្លាប់រស់នៅក្នុងអង្គភាព មិត្តឯងដែលបានលួចអង្ករ បម្រើខ្មាំងមែនទេ? ហើយខ្ញុំឆ្លើយបដិសេធថា ខ្ញុំពុំដែលបានលួចអង្ករឲ្យខ្មាំងទេ ហើយក៏ខ្ញុំមិនដែលបានបម្រើការងារអ្វីទាំងអស់រហូតដល់គេ-- *(ឮមិនច្បាស់)* ខ្ញុំឆ្លើយថា ដដែលៗទៅគេក៏បានវាយខ្ញុំត្រូវពីរដៃគំត្រចៀក ក្រោយមកទៀតខ្ញុំក៏មិនដឹងត្រង់ណាទៀត ខ្ញុំក៏សន្លប់បាត់ទៅ ។ បាទនេះជាអង្គហេតុដំបូងដែលខ្ញុំឈឺចាប់នៅពេលបច្ចុប្បន្ន វានៅតែមាន ។

**ស៖** លោកដែលអះអាងថា គេចាប់លោកហ្នឹងគឺចាប់លោកនៅទីកន្លែងណា? ចាប់ពីកន្លែងណាទៅ? ហើយលោកកំពុងធ្វើអីនៅទីនោះ? ហើយចាប់នឹងនៅពេលណា?

**ឆ៖** ជម្រាបប្រសាសន៍! ក្នុងការចាប់ខ្ញុំបាទមកនេះក៏អត់មានចាប់តែខ្ញុំបាទមួយទេ គឺខ្ញុំបាទសូមធ្វើអង្គហេតុពីដើមពេលដែលចាប់ខ្ញុំមកដល់នៅទីក្រុងភ្នំពេញនេះ គឺនៅឆ្នាំ-- ខ្ញុំមិនបានចាំខែថ្ងៃទេ នៅក្នុងឆ្នាំ១៩៧៦ គឺមានរូបខ្ញុំ ពេលនោះខ្ញុំនៅ-- ការលីសែងនៅកំពង់ផែនៅគីឡូលេខ៦ ។ នៅពេលនោះគេបានស្នើឲ្យមិត្ត យីន, មិត្តលឿន ហើយនិងមិត្តនាន់ ដូច្នេះគេអស់នោះសុទ្ធសឹងតែជាថ្នាក់កងអនុសេនាធំជាបក្ខជន ខ្ញុំសូមជម្រាបលោកប្រធានពីអង្គហេតុដំបូងនៅពេលនោះខ្ញុំជា គេហៅថា ខ្ញុំជានីរសារគេទេ ហើយខ្ញុំនៅតូចណាស់ ថ្វីត្បិតតែខ្ញុំអាយុច្រើនមែន ។ ក៏ប៉ុន្តែ ខ្ញុំនៅតូចហើយទាប សម័យនោះ ។ ហើយគេហៅខ្ញុំតែអាម៉ាប់ៗ ដូច្នេះខ្ញុំកំពុងតែធ្វើការនៅឃ្លាំងគីឡូលេខ៦ កំពុងតែលីស្រូវ ហើយក៏លីស៊ីម៉ងត៍នៅក្នុងឃ្លាំង ស្រាប់តែអ្នកឃ្លាំងហ្នឹងគេហៅខ្ញុំថា មិត្តលឿន-- មិត្តអាត-- មិត្តយីនហ្នឹង ឲ្យមិត្តឯងទៅជាមួយនឹងគាត់ ។ ខ្ញុំក៏រៀបចំអីវ៉ាន់មកជាមួយនឹងគាត់មក ។ លុះដល់ខ្ញុំឡើងឡាន កាលនុំងឡាននៅក្នុងឃ្លាំងហ្នឹង គឺឡានឡាំប្រ៊ីតា ដែលមានហ៊ុមឃ្ពុបជិត ហើយខ្ញុំឃើញថា ពេលដែលឡើងទៅលើឡាំប្រ៊ីតានោះមានមានគ្នាបួននាក់រួមទាំងខ្ញុំផង ។ មានមិត្ត យីន, មិត្តលឿន ហើយនិងមិត្តនន់ ។ ហើយខ្ញុំនៅអង្គុយខាងក្រោយគេ ។ ក្រោយមកដល់មកស្ពានជ្រោយចង្វា-- ក្រោមស្ពានជ្រោយចង្វាដែលជាកន្លែងងងឹត ឡាននោះក៏ឈប់ ពេលនោះគេបើកសន្ទះឡានខាងក្រោយមក គេភ្ជង់ខ្ញុំហើយគេចាប់គេចងមុខតែម្តង ។ រួចហើយគេដោះអាវដោះខោខ្ញុំចេញអស់ពីខ្លួនហើយ គេដាក់ខ្ញុំឈរដោយឡែក ។ មួយសន្ទុះក្រោយមកឡាននោះក៏ចេញទៅ ស្រាប់តែខ្ញុំពុំដឹងអ្វីទាំងអស់នៅពេលនោះ មិនដឹងជាគេយ៉ាងម៉េចទេ? គេដោះក្រមាខ្ញុំ គេចងមុខរួចហើយក៏គេចាប់ខ្ញុំបោះទៅលើឡានមួយទៀត ។ គេបណ្តើរខ្ញុំចេញបន្តិចមកគេចាប់ដាក់លើឡានមួយទៀត ។ ដល់ពេលដែលគេចាប់ខ្ញុំដាក់លើឡានមួយនោះទៀត ខ្ញុំមានការរន្ធត់ណាស់ ហើយរហូតដល់គេបោះអ្នកពីរបីនាក់ទៅលើឡានទៀតក៏ខ្ញុំមិនដឹងថា យ៉ាងម៉េចៗក៏ខ្ញុំមើលគេអត់ឃើញដែរ ។ ដូច្នេះហើយបានជាយើងខ្ញុំ មានការព្រួយបារម្ភរហូត លុះដល់ប្រហែលជាកន្លះម៉ោងក្រោយមក ទើបមានឈប់ឡានមួយភ្លែត ប្រហែលជាបួននាទី ឬបីនាទី ហើយឡាននោះក៏បន្តទៅប្រហែលជាដប់នាទីទៀត ទើបដល់ទៅកន្លែងរួចហើយក៏គេបោះខ្ញុំមកខាងក្រោមមក ។ ពេលនោះចំណងដៃខ្ញុំនៅជាប់ដដែល ភ្នែកខ្ញុំនៅតែងងឹតចងជាប់ដដែល ។ ហើយក៏គេបង្អូសខ្ញុំចេញផុតទៅ ក៏ខ្ញុំមិនដឹងថាទៅទីកន្លែងណា ទៅណាទេ ដាច់ដោយឡែកពីគ្នា ។ ហើយនៅពេលដែលយើងខ្ញុំទៅដល់កន្លែងដែលគេ

ឃាត់ខ្លួនគេក៏-- គេឃុំខ្លួនខ្ញុំនោះ ទើបគេដាក់ខ្នោះជើងរបស់ខ្ញុំទាំងពីរ នៅកន្លែងមួយដែលខ្ញុំបាទចាំពុំបាន ។

ដោយក្ដីរន្ធត់ក្នុងចិត្តនោះពេកខ្ញុំចាំអ្វីមិនបានទាំងអស់ ។ រួចហើយគេស្រាយមុខខ្ញុំចេញក៏ខ្ញុំអត់ដឹងទិសតំបន់កន្លែងណាជាកន្លែងណាទេ ។ សូមជម្រាបលោកប្រធានដោយខ្លី ។

[០៩:២២:១៥]

**ស៖** លោកត្រូវបានគេចាប់ហ្នឹង លោកមិនចាំថ្ងៃខែឆ្នាំណាច្បាស់លាស់ទេ មែនទេ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំចាំបានតែប្រហែលជាឆ្នាំ១៩៧៦ ។

**ស៖** លោកត្រូវបានគេចាប់យកទៅឃុំឃាំងហ្នឹង អស់រយៈពេលប្រហែលជាប៉ុន្មានថ្ងៃខែដែរនៅទីនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេចាប់ខ្ញុំទៅដាក់កន្លែងនោះ ខ្ញុំចាំបានថាថ្ងៃទី២ គឺគេហៅខ្ញុំទៅសួរចម្លើយ ហើយបានគេធ្វើទារុណកម្មខ្ញុំយ៉ាងធ្ងន់ធ្ងរ ។ ដោយខ្ញុំប្រកែកថាខ្ញុំយកអង្ករពីឃ្លាំងដើម្បីបម្រើក្នុងអង្គភាពរហូតដល់គេកៀបខ្ញុំសួរថា "អ្អែងបានឃុបឃិតជាមួយខ្មាំងនិង អាយីន, អាលឿន ហើយនិង អានន់ យកអង្ករឲ្យខ្មាំងមែនទេ? ខ្ញុំថា ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំជានីរសារខ្ញុំអត់ដឹងរឿងអីទាំងអស់ ។ ខ្ញុំនៅតែឆ្លើយដដែល១អ៊ីចឹងគេវ៉ៃខ្ញុំទៀត វ៉ៃខ្ញុំលើកទីមួយហ្នឹងឯងដែលខ្ញុំត្រូវសន្លប់ដោយដោយវ៉ៃពុំដឹងជាដាល់ខ្ញុំយ៉ាងម៉េចអីយ៉ាងម៉េចក៏ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំងងឹតមុខ ចងមុខខ្ញុំជិតហើយខ្ញុំអត់ស្គាល់ថា គេវ៉ៃនឹងដំបង ឬក៏វ៉ៃនឹងអីអត់ដឹងទេ? ដូច្នេះ វ៉ៃនៅត្រចៀកខាងឆ្វេងរបស់ខ្ញុំនេះមួយដៃហើយនៅពេលនោះងើបមកវិញ ហាក់បីដូចជាមានរបស់អីរឹងមួយត្រូវខ្ញុំមួយទៀតបានខ្ញុំដួលសន្លប់ទៅ ខ្ញុំអត់ដឹងអីរហូតដល់គេយកទៅកន្លែងឃុំឃាំងវិញ ។

**ស៖** យើងចង់ដឹងថា ចាប់ពីពេលដែលគេចាប់ចូលទៅដល់កន្លែងឃុំឃាំង និងការសួរចម្លើយដែលមានការប្រើអំពើហិង្សា ដែលលោកនិយាយអំមិញថា ប្រើទារុណកម្មនេះចាប់ពីពេលនោះរហូតដល់ពេលលោកចេញត្រឡប់មកវិញអស់រយៈពេលប្រហែលប៉ុន្មាន?

លោកឆ្លើយសំណួរឲ្យត្រូវនឹងសំណួរ ។

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលខ្ញុំបាទបានចូលទៅនៅកន្លែងឃុំឃាំងនិងធ្វើទារុណកម្មនោះ បើខ្ញុំស្មានប្រមាណជាបីខែ ឬក៏ក្រោយបីខែ ។

**ស៖** អំឡុងពេលដែលលោកទៅជាប់នៅទីនោះ តើលោកត្រូវបានបុគ្គលិកនៅទីនោះគេបានដោះកំណាត់រុំមុខលោកចេញដែរឬទេ ឬក៏គេរុំមុខលោកជាអចិន្ត្រៃយ៍នៅក្នុងរយៈពេលបីខែនេះ ទាំងយប់ទាំងថ្ងៃ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅដែលគេធ្វើការ-- ពេលដែលគេចូលទៅដាក់ក្នុងឃុំឃាំង គឺគេស្រាយមុខហើយ គេដាក់ខ្នោះជើងយើងតែប៉ុណ្ណឹងហើយ គេស្រាយមុខយើងចេញ ។ ពេលដែលគេឲ្យខ្ញុំយកលាមកខ្លួនឯងទៅចោលទើបគេចងមុខខ្ញុំ ហើយគេដោះខ្នោះជើងខ្ញុំមួយចំហៀង ចង់ខ្ញុំហើយឲ្យខ្ញុំកាន់ខ្នោះ កាន់លាមកមួយចំហៀងយកទៅចាក់ចោល រហូតដល់គេ-- ដល់កន្លែងចាក់ហើយបានគេស្រាយមុខខ្ញុំចាក់ ។ ចាក់រួចហើយបានអ្នកយាមឲ្យគេហ្នឹង គេឲ្យខ្ញុំនេះកាប់អន្លង់ មួយអន្លង់ ពីរអន្លង់ដែលមានទំហំប្រហែលជាប្រាំមួយតឹកទៅប្រាំពីរតឹក ឬទៅមួយម៉ែត្រទៅតាមគេប្រើរួចហើយគេចងមុខខ្ញុំហើយគេបណ្តើរចូលមកកន្លែងដើមវិញ ។ សូមជម្រាបលោកប្រសាសន៍ដោយប៉ុណ្ណឹង ។

[០៩:២៧:០៦]

**ស៖** លោកចាំទេកន្លែងដែលគេចាប់លោកទៅឃុំឃាំងហ្នឹងទីមួយនៅកន្លែងណា? កន្លែងរបៀបកន្លែងដែលឃុំឃាំងហ្នឹងជាអគារឃុំឃាំងរួមធំ ឬក៏ជាអគារតូចទេ? ហើយអគារនោះធ្វើអំពីអ្វីដែរ? កន្លែងបន្ទប់ឃុំឃាំងលោកនុ៎ង?

**ឆ៖** សូមជម្រាបលោកប្រធាន! ខ្ញុំបាទពុំចាំបានថាអគារនោះកសាងអំពីអ្វីទេ ។ ក៏ប៉ុន្តែ ខ្ញុំអាចចាំបានថា នៅបន្ទប់ដែលខ្ញុំបាទជាប់គឺជាប់តែឯងម្នាក់ ។ ហើយជញ្ជាំងក្តារនៅកៀនខាងក្រោយខ្នងខ្ញុំ ហើយបន្ទាប់មកគឺថ្មនៅជុំវិញកន្លែងដែលឃុំខ្លួនខ្ញុំ គឺមានតែខ្ញុំម្នាក់គត់ ។ សូមជម្រាបប្រសាសន៍លោកប្រធាន ។

**ស៖** អគារ-- កន្លែងបន្ទប់ឃុំឃាំងលោកនុ៎ងធំទេ? ហើយទំហំប្រហែលប៉ុនណាដែរ? ហើយជាសំណង់ធ្វើថ្មី ឬក៏ជាសំណង់ចាស់?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលខ្ញុំបាទមើលឃើញស្ថានភាពដែលខ្ញុំបាទជាប់នោះ គឺទំហំមិនហួសពីមួយម៉ែត្រទេ ហើយចង្អៀត ។ ហើយហាក់បីដូចជាខ្ញុំនឹកឃើញថា នៅលើក្បាលរបស់ខ្ញុំនោះគឺ ស្នូរមនុស្សដើរឡើងចុះជាងញឹកញាប់ ។ សូមជម្រាបលោកប្រសាសន៍ដែលបានដឹង ។

**ស៖** នៅអំឡុងពេលដែលជាប់ឃុំឃាំងហ្នឹង តើលោកមានបានដឹងថាអ្នកជាប់ឃុំឃាំងផ្សេងទៀតមានចំនួនច្រើនទេនៅទីនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ការឃុំឃាំងខ្លួនមនុស្សនៅកន្លែងនោះខ្ញុំពុំបានឃើញទេ ដោយឮស្ងរតែសំឡេងថ្ងូរ ហើយនិងសំឡេងស្រែកតែប៉ុណ្ណោះ ។ ដោយខ្ញុំពុំអាចមានសិទ្ធិក្រោកមើល ឬក៏ងើបមើល អើតមើលឆ្វេងស្តាំ គឺពុំដែលមានទេ ជម្រាបប្រសាសន៍ ។

**ស៖** កន្លែងដែលឃុំឃាំងលោកហ្នឹង គឺនៅផ្ទាល់ដី ឬក៏នៅជាន់ទីមួយ ឬក៏ជាន់ទីពីរ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន! តាមដែលខ្ញុំចាំបានប្រហែលជាជាន់ក្រោមព្រោះនៅពេលដែលគេបណ្តើរខ្ញុំចងមុខខ្ញុំចេញនៅពេលយប់ ហើយខ្ញុំដឹងបានថា ខ្ញុំចុះបានបីជំហាន ហើយខ្ញុំជំពប់ជើងដួលបែកក្បាលជង្គង់នុំងគឺ នៅផ្ទាល់ដីទេ បើខ្ញុំប៉ាន់ស្មាន អានេះដោយខ្ញុំដឹងដែលអារម្មណ៍ជើងរបស់ខ្ញុំ ដែលខ្ញុំដើរចុះ ។

**ស៖** អំមិញលោកបានឆ្លើយថា លោកត្រូវអំឡុងពេលនៃការជាប់ឃុំឃាំងក្រោយពេលសួរចម្លើយរួចហ្នឹងគេបានបញ្ចេញលោក ដើម្បីឲ្យជីករណ្តៅ ជីករណ្តៅហ្នឹងគឺមានទំហំកន្លះម៉ែត្រ ឬក៏ទំហំកន្លែងខ្លះមួយម៉ែត្រ ដែលកាលពីនៅក្នុងពាក្យបណ្តឹងរបស់លោក លោកបាននិយាយថា គេឲ្យលោកជីករណ្តៅសម្រាប់ដាំចេកក្នុងមួយយប់បីគុម្ព ។ ចម្លើយពីរនេះ តើមួយណាត្រឹមត្រូវ? ជីករណ្តៅដើម្បីដាំចេកក្នុងមួយយប់បីគុម្ព ឬក៏ជីករណ្តៅទៅតាមទំហំ ដែលលោកបាននិយាយអម្បាញ់មិញនេះ មានការប្រែប្រួលខ្លះធំខ្លះតូចនេះ ដោយមិនដឹងថាពីមូលហេតុនៃការឲ្យជីករណ្តៅនេះ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេឲ្យខ្ញុំទៅជីករណ្តៅនោះ គឺអ្នកយាមវាប្រាប់ថារណ្តៅនេះគឺរណ្តៅដាំចេក ក៏ប៉ុន្តែយើងខ្ញុំបាទពុំបានដាំទេចេកនោះ គ្រាន់តែបានតែជីក ។ តែជីកនោះក៏អត់បានមានពេលវេលា ជីកថ្ងៃដែរ គឺពេលយប់ បានគេឲ្យខ្ញុំបាទចេញទៅជីក ។

**ស៖** លោកចេញទៅជីករណ្តៅពេលយប់ហ្នឹង គឺនៅចំណុចខាងណា ទិសណានៃកន្លែងដែលលោកធ្លាប់ឃុំឃាំង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេយកខ្ញុំទៅជីកនោះ ពេលនោះគឺខ្ញុំពុំដឹងថាគេឲ្យទៅកន្លែងណា ទៅកន្លែងណាទេ ក៏ប៉ុន្តែ ខ្ញុំអាចចាំបានថា នៅពេលដែលគេចងមុខខ្ញុំហើយគេបណ្តើរចេញពីកន្លែងឃុំឃាំងនោះ គឺមានរយៈពេលវែងដែរ បើខ្ញុំប៉ាន់ស្មានមើលប្រហែលជាពីដប់ប្រាំនាទី ទៅម្ភៃនាទី បានដល់កន្លែង ។ ក៏ប៉ុន្តែ នៅពេលដែលចុះមកដល់ជាន់ស្មើហើយគឺ ខ្ញុំបាទសូមជម្រាប

ប្រសាសន៍ថា នៅពេលនោះគេទាញឲ្យខ្ញុំងាកឆ្វេង ថ្ងៃពេលណាខ្លះគេទាញឲ្យខ្ញុំងាកស្តាំ ។ តែការដើរនោះដូចខ្ញុំជម្រាបប្រសាសន៍លោកប្រធានពីខាងដើម មានរយៈពេលពីដប់ប្រាំនាទី ទៅម្ភៃនាទី ។

**ស៖** លោក-- តាមលោកនិយាយហ្នឹងបានន័យថា ទីមួយការដែលបញ្ចេញលោកទៅក្រៅ ដើម្បីធ្វើការជីករណ្តៅហ្នឹង គឺបញ្ចេញនៅពេលយប់ ។ ហើយទីពីរ គឺការបញ្ចេញនេះមានទាំងចងមុខ យកកំណាត់ចងមុខផង ។ ហើយទីបី គឺការចាកចេញពីកន្លែងនោះ ទៅកន្លែងជីករណ្តៅហ្នឹង ត្រូវដើរចម្ងាយផ្លូវហ្នឹង គឺដើរប្រើពេលវេលារហូតដល់ទៅ ដប់ប្រាំនាទីឯណោះបានដល់ ។ អ៊ីចឹង មែនទេ?

[០៩:៣៣:៥៤]

**ឆ៖** ពិតមែនហើយលោកប្រធាន ។

**ស៖** នៅក្នុងអំឡុងពេលដែលលោករស់នៅហ្នឹង ដូចជាបីខែរយៈពេលវែងដែរ ។ តើលោកបានពិនិត្យនូវទិដ្ឋភាព ឬក៏បានឃើញនូវទិដ្ឋភាពអ្វីខ្លះ? ដូចជាអគារនៅទីកន្លែងនោះ វាមានអគារ មានសំណង់អ្វីខ្លះនៅជុំវិញ នៅទីកន្លែងដែលលោកត្រូវឃុំឃាំងនោះ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលថ្ងៃខ្ញុំបាទ ពុំដែលបានអើតអ្វីក្រៅអំពីនៅកន្លែងឃុំឃាំងតែឯងនោះទេ ។ ខ្ញុំពុំដឹងថា កន្លែងណា ជាកន្លែងណា ខ្ញុំអត់ដឹង គ្រាន់តែយើងខ្ញុំអើតមើលទៅលើក្បាលប៉ុណ្ណោះ ដឹងថានៅលើក្បាលរបស់ខ្ញុំ ប្រផាត់ៗក្បាលហ្នឹងគឺជា ស៊ីម៉ងត៍ ហើយនិងខាងក្រោយរបស់ខ្ញុំជាជញ្ជាំងក្តារដោយបិទជិត ។

**ស៖** ប្រផាត់ៗក្បាលយ៉ាងម៉េច ពេលដែលលោកឈរទៅប្រផាត់ក្បាល ឬក៏លោកអង្គុយទៅវាអា *តេរ៉ាស់* អាដំបូលខាងលើហ្នឹង វាប្រផាត់ក្បាលលោក? លោកនិយាយប្រផាត់ក្បាលហ្នឹង បានន័យថាអាខាងលើហ្នឹងវា ពេលដែលលោកអង្គុយទៅប្រផាត់ក្បាល ឬក៏លោកងើបឈរទៅប្រផាត់ក្បាលលោក?

**ឆ៖** គឺនៅពេលដែលខ្ញុំបាទ ងើបឈរមិនបានអស់ខ្លួនទេ ដល់ក្បាល ។

**ស៖** អ៊ីចឹងបានន័យថា កន្លែងដែលបន្ទប់ឃុំឃាំងលោកហ្នឹង ទីមួយ គឺវាតូច ទីពីរ គឺវាខាងលើនេះទាប ។ បានន័យថា កម្ពស់តែក្បាលមនុស្សទេ ឬក៏ពេលដែលលោកទៅគឺអាចប៉ះក្បាលផង បើសិនជាលោកមិនឱនក្បាលបន្តិចនោះ ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតប្រាកដមែនហើយ លោកប្រធាន ។

**ស៖** អាលើហ្នឹង ដំបូលខាងលើហ្នឹង វាជាថ្ម ឬក៏ឈើ?

**ឆ៖** គឺជាថ្ម លោកប្រធាន ។

**ស៖** សំណួរសាជាថ្មីម្តងទៀត សួរថាទីកន្លែងនោះលោកស្គាល់ទេ ជាទីកន្លែងអី កន្លែងអីទៅ កន្លែងដែលលោកត្រូវគេឃុំឃាំងនៅជំនាន់នុំង បីខែហ្នឹង? លោកដឹងថាកន្លែងនោះ គេហៅថាកន្លែងអីទេ?

[០៩:៣៧:០២]

**ឆ៖** កាលពីមុនមកខ្ញុំបាទអត់ស្គាល់មែនកន្លែងនោះ ។ តែក្រោយមកមានឆ្នាំ ដែលនៅយាមនៅហ្នឹងពីរនាក់ដែលវានិយាយគ្នា ទើបបានខ្ញុំដឹងថា ជាសាលាទួលស្លែង គេហៅថា សាលាទួលស្លែងដោយមូលហេតុអី? ដោយមានអ្នកឆ្មាំម្នាក់ដែលខ្ញុំមិនអាចស្គាល់បាន គេនិយាយខាងក្រៅ រអ៊ូៗ ថាយប់មិញយកមួយឡានមក អញអត់បានដេកទាំងអស់ ។ ដល់ក្រោយមកទៀត អាមួយនោះថាន៎ អ្ហឺអ្ហា! នៅកន្លែងនេះតែអ៊ីចេះឯង គេថាទួលស្លែង នេះឲ្យតែមកហើយលំបាកទាំងអ្នែង លំបាកទាំងមិត្តឯង លំបាកទាំងខ្ញុំទាំងគ្នានេះឯង ។ ហើយខ្ញុំស្តាប់បាន អាសំឡេងហ្នឹង គឺខ្ញុំអាចសម្គាល់បានថា ជាសាលាទួលស្លែង ។

**ស៖** ក្រោយពេល១៩៧៩ តើលោកបានចូលទៅពិនិត្យមើលកន្លែងទួលស្លែងដែរឬទេ? គុកទួលស្លែងហ្នឹងដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅក្រោយដែលរំដោះឆ្នាំ១៩៧៩មកនេះ រហូតដល់ពេលដែលកើតសាលាជំនុំជម្រះនេះមក គឺខ្ញុំបាទបានមកម្តងគត់ ដោយការរៀបចំអគារកន្លែងដែលកើតហេតុនោះរៀបចំរួច ហើយខុសបំណឹងពីដើមមុនបាត់ទៅហើយ ។ អ៊ីចឹង ខ្ញុំមិនអាចចាំបាន ។

**ស៖** អ៊ីចឹង លោកធ្លាប់បានចូលទៅមកមើលកន្លែងទួលស្លែងម្តងនៅក្រោយឆ្នាំ១៩៧៩ ប៉ុន្តែចំណាំៗនៅកន្លែងឃាំងលោកហ្នឹងអត់បានទេ ដោយសារមានការរៀបចំជាថ្មី មានការប្រែប្រួលនៅទីកន្លែងដែលឃុំឃាំងលោក ។ អ៊ីចឹងមែនទេដែលលោកចង់និយាយអំមិញនេះ?

**ឆ៖** ពិតប្រាកដហើយ លោកប្រធាន ។

**ស៖** ឥឡូវត្រលប់ក្រោយបន្តិច ។ នៅពេលដែលគេចាប់បញ្ជូនលោកមកដល់ដំបូង ពេលដែលចូលទៅមុននឹងចូលទៅឃុំឃាំងហ្នឹង តើគេបានប្រព្រឹត្តនូវសកម្មភាពអ្វីខ្លះចំពោះលោក មុននឹងរុញលោកបញ្ចូលទៅក្នុងអគារនៅក្នុងបន្ទប់ឃុំឃាំងនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ។

នៅពេលដែលខ្ញុំបាទចូលទៅដល់ទីកន្លែងនោះ គឺនៅយប់ទីមួយហ្នឹង គឺគេអត់មានសួរខ្ញុំអ្វីទាំង

អស់ គេគ្រាន់តែបណ្ដើរខ្ញុំយកទៅដាក់កន្លែងឃុំឃាំង តែប៉ុណ្ណោះ ។

**ស៖** គេមានបានធ្វើការសួរសម្ភាសន៍ អំពីជីវប្រវត្តិ អំពីទីលំនៅ ឪពុកម្ដាយ មុខរបរ អីអ៊ីចឹង ទេពេលដែលលោកចូលមកដល់ភ្លាម? ឬមួយក៏មកដល់ភ្លាមគេរុញលោកទៅដាក់ឃុំឃាំងតែម្ដង?

[០៩:៤១:៣៦]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ។ នៅពេលដែលខ្ញុំបាទទៅដល់ភ្លាម គេពុំបានសួរអ្វីទាំងអស់ ក្រៅអំពីគេរុញទៅដាក់កន្លែងឃុំឃាំងនោះទេ ។

**ស៖** គេបានថតរូបលោកដែរទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ពេលនោះខ្ញុំអត់ដឹងដែរ ព្រោះនៅពេលនោះក៏អត់ឃើញមានគេថត គេអីផង នៅពេលដែលគេចងមុខខ្ញុំជាប់ ដឹងគេថត ដឹងអត់ ខ្ញុំអត់ដឹងដែរ ។

**ស៖** ចុះសម្លៀកបំពាក់លោកស្លៀកពាក់មក ដែលពេលគេ-- អំឡុងពេលចាប់ហ្នឹងលោកស្លៀកពាក់សម្លៀកបំពាក់យ៉ាងដូចម្ដេច?

**ឆ៖** នៅពេលអំឡុងពេលដែលគេចាប់ខ្ញុំបាទមកពីអង្គភាពមក គឺខ្ញុំបាទស្លៀកពាក់ខោអាវខ្មៅ ហើយនិងបង់កក្រមា ។

**ស៖** ចុះអំឡុងពេលគេឃុំខ្លួនលោក តើលោកស្លៀកបំពាក់យ៉ាងដូចម្ដេចដែរ? ហើយក្រមានៅឯណា? ក្រមានោះលោកមានសិទ្ធិប្រើប្រាស់ទេ ក្នុងអំឡុងពេលដែលគេឃុំឃាំងលោក?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេចាប់ខ្ញុំនៅក្រោមស្ពានជ្រោយចង្វា ពេលនោះគេដោះក្រមារបស់ខ្ញុំហ្នឹង ចងមុខខ្ញុំហើយ ខ្សែគេផ្សេងគេចងដៃខ្ញុំ តែពេលនោះគេដោះអាវដោះអីអស់ហើយ ខោអីក៏គេស្រាតអស់ដែរ ។ នេះសូមជម្រាបប្រសាសន៍ លោកប្រធានដោយខ្លី ។

**ស៖** អ៊ីចឹងបានសេចក្ដីថា ពេលដែលគេមកដល់ រុញលោកមកដល់ចូលឃុំឃាំងហ្នឹង លោកមិនមានគេដោះសម្លៀកបំពាក់វែងចេញហើយ ហើយក្រមាក៏គេដោះមក យកមកចងមុខ ។ អ៊ីចឹងលោកនៅស្លៀកអីទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំនៅតែខោខ្លីហើយនិងអាវយឺត ដែលខ្ញុំធ្វើការប៉ុណ្ណឹង ។

**ស៖** លោកនិយាយអំមិញថា គេនាំលោកទៅសួរចម្លើយ សំណួរសួរថា តើការសួរចម្លើយហ្នឹងប៉ុន្មានដង? ហើយរបៀបក្នុងការនាំយកទៅសួរចម្លើយនេះគេប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរចំពោះលោក?

[០៩:៤៤:២៣]

**ឆ៖** សូមជម្រាបលោកប្រសាសន៍! ឯការសួរចម្លើយ គឺដូចខ្ញុំជម្រាបប្រសាសន៍លោក ទីមួយបានជ្រាបស្រាប់ហើយថា ទីមួយ គេសួរអំពីខ្ញុំបានធ្វើការជាមួយនឹង មិត្តយឺន ហើយនិង មិត្តលឿន ។

**ស៖** យើងអត់សួរអ៊ីចឹងទេ សំណួរសួរថា គេនាំលោកទៅសួរចម្លើយប៉ុន្មានដង? ក្នុងអំឡុងពេលចាប់ដែលឃុំឃាំងលោកហ្នឹង?

**ឆ៖** ជម្រាបលោកប្រសាសន៍! គឺពីរដង ។

[០៩:៤៥:00]

**ស៖** សួរនៅកន្លែងដែលគេឃុំឃាំងលោក ឬក៏គេនាំលោកទៅសួរនៅកន្លែងផ្សេង?

**ឆ៖** សូមជម្រាបប្រសាសន៍! នៅពេលដែលគេសួរចម្លើយខ្ញុំ គឺគេចងមុខខ្ញុំហើយបានគេដឹកខ្ញុំចេញ បណ្តើរខ្ញុំចេញទាំងជើងជាប់ខ្នោះមួយចំហៀង ហើយដៃជាប់ចំណង ហើយឲ្យដៃខ្ញុំមួយចំហៀងដែលជាប់ចំណងហ្នឹងឲ្យគេយួរ ឲ្យខ្ញុំយួរខ្នោះដែលជាប់ជើងហ្នឹងដើរទៅ ។ ហើយនៅពេលដែលដល់ដីរាបហើយនោះគេអូសខ្ញុំទៅ បើខ្ញុំប៉ាន់ស្មានមើលជារាប់ជាជំហានប្រហែលជាសាមសិបជំហាន ។ រួចហើយបានគេទាត់ខ្ញុំកំភ្លៅខ្ញុំមួយជើងទៅ ខ្ញុំដួលលត់ជង្គង់នៅហ្នឹង គេសួរ ហើយបានគេវៃដំខ្ញុំសួរចម្លើយតែម្តង ហើយខ្ញុំក៏សន្លប់បាត់ទៅ ។

**ស៖** អំឡុងពេលគេសួរចម្លើយលោកហ្នឹងគេមានដាក់ខ្នោះលោកទេ អាដោះខ្នោះជើងអំមិញដោះនៅមួយចំហៀង តើគេមានដាក់ខ្នោះជើងវិញដែរទេ? ហើយខ្នោះដៃគេដោះដែរទេឬក៏នៅដដែល? ហើយកំណាត់រុំមុខទុកដដែលឬក៏គេដោះចេញ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេសួរខ្ញុំ ហើយគេទាត់ខ្ញុំដួលនោះគឺខ្នោះគឺគេអត់ដាក់ទៀតទេ ហើយដៃរបស់ខ្ញុំគេចងទៅក្រោយរបៀបនេះ ហើយដៃខ្ញុំមួយចំហៀងដែលខ្ញុំកាន់ខ្នោះជើងខាងស្តាំនេះ គឺខ្ញុំកាន់ដដែលពេលដែលគេទាត់ដួលទៅ បានខ្ញុំដួលលុតជង្គង់ទៅទេ ។ ហើយគេនៅតែចងមុខខ្ញុំដដែល គេអត់ស្រាយមុខខ្ញុំទេ។ សូមជម្រាបប្រសាសន៍លោកប្រធានដោយខ្លីប៉ុណ្ណេះ។

**ស៖** អ្នកសួរចម្លើយលោកហ្នឹងមានប៉ុន្មាននាក់?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ។ បើខ្ញុំស្តាប់សំឡេងពុំច្បាស់ទេនោះ ខ្ញុំអាចដឹងថានៅ កៀនខ្ញុំមានម្នាក់នាក់ ហើយនៅខាងមុខខ្ញុំមានម្នាក់ដែលសួរខ្ញុំ ។

**ស៖** ហើយកន្លែងសួរចម្លើយនោះមានប្រដាប់ប្រដាឧបករណ៍អ្វីខ្លះដែរ ដែលលោកបានដឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងឧបករណ៍ក្នុងការប្រើប្រាស់ ការសួរចម្លើយហ្នឹង ខ្ញុំមើលពុំឃើញទេ ហើយក៏ខ្ញុំក្តាប់មិនបានដែរ ។

**ស៖** ចុះលោកថាគេវាយលោកហ្នឹង តើគេវាយនឹងឧបករណ៍អ្វីទៅ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន នៅពេលដែលគេវាយ ខ្ញុំដឹងមុនដំបូងប្រហែលជាដាល់ ខ្ញុំគុម្ពត្រចៀកខាងឆ្វេង រួចហើយខ្ញុំដួលជើបមកវិញ ត្រូវទៀត ខ្ញុំអត់ដឹងថាត្រូវជាដំបងធំ ឬក៏តូចយ៉ាង ម៉េចទេ គឺខ្ញុំសន្លប់បាត់ទៅ ។

[០៩:៤៨:៤៧]

**ស៖** នៅក្នុងអំឡុងពេលនៃការដែលជាប់ឃុំឃាំង គេដាក់ឃុំឃាំងលោក តើគេដាក់ខ្នោះជើងទាំងខ្នោះដៃ ឬក៏ដាក់តែខ្នោះជើងទេ ហើយខ្នោះដៃមិនដាក់ ឬក៏មិនចងសេកលោកទេ នៅក្នុងអំឡុងពេលដែលគេដាក់នៅក្នុងបន្ទប់ឃុំឃាំងនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេដាក់កន្លែងខ្ញុំឃុំឃាំងនោះ គឺចំណងដៃរបស់ខ្ញុំគឺគេស្រាយបន្ធូរទេ ហើយជើងគឺជាប់ខ្នោះដដែល ។ គេបន្ធូរតែដៃទេ តែជើងនៅជាប់ខ្នោះដដែល។

**ស៖** អ៊ីចឹងបានសេចក្តីថា នៅក្នុងអំឡុងពេលដែលជាប់ឃុំឃាំង នៅក្នុងរយៈពេលឃុំឃាំងហ្នឹងគឺគេដាក់ទាំងខ្នោះជើង ហើយទាំងចងស្លាបសេក ដៃហ្នឹងគឺជាប់ចងស្លាបសេក ប៉ុន្តែគ្រាន់តែបន្ធូរមិនបានដោះលែងទាំងស្រុងទេ ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតប្រាកដអ៊ីចឹងមែនហើយលោកប្រធាន ។

**ស៖** ចុះរបបអាហារហូបចុកយ៉ាងម៉េចដែរនៅទីនោះ នៅកន្លែងឃុំឃាំងលោកនោះ គេផ្តល់ផ្គត់ផ្គង់ឲ្យយ៉ាងម៉េចរបបម្ហូបអាហារ?

**ឆ៖** ចំពោះអាហារខ្ញុំសូមជម្រាបលោកប្រធានថា ក្នុងមួយថ្ងៃគឺគេឲ្យបាយដែលមានបបរហ្នឹងដែលមានអង្ករ ខ្លះទៅក៏ទឹកវាច្រើនទៅ ខ្លះទៅក៏អង្ករនោះតិចទៅ ប៉ះជួនណានោះបបរនោះក៏រឹងគ្រាន់ទៅនេះខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន ។

**ស៖** អ៊ីចឹងរបបដែលគេផ្គត់ផ្គង់ក្នុងអំឡុងពេលឃុំឃាំងហ្នឹងគឺហូបបបរ គ្រាន់តែបបរហ្នឹងពេលខ្លះបបរខាប់ទៅ ពេលខ្លះបបររាវ ។ អ៊ីចឹងមែនទេ ឬក៏ហូបបាយ?

**ឆ៖** និយាយពីរឿងបាយវិញ សូមជម្រាបប្រសាសន៍ប្រធាន! តិចណាស់មិនដែលបានឃើញមិនសូវមានបាយផ្តល់ឲ្យទេ បើបបរវាងរឹងអីឃើញមាន ។

**ស៖** មានសម្លទេ ផ្តល់នូវសម្លឲ្យហូបជាមួយបាយ ជាមួយបបរដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងម្ហូបគឺមិនមានទេ ។ គឺបានតែ បើសិនណាបបរហ្នឹងបានល្វែមៗ តែប៉ុណ្ណោះ ។ ហើយជួនណាក៏ឃើញត្រីរៀល ប៉ុនមេដៃដាក់ពីលើចាន តែប៉ុណ្ណោះឯងទេទាន ។

[០៩:៥២:៣៦]

**ស៖** គេផ្តល់ឲ្យបបរ ឬក៏បាយ-- បបរខាប់ បបររាវ ពេលខ្លះមានបាយហ្នឹងគេឲ្យហូបគ្រប់គ្រាន់ទេ? ឬក៏របបនោះប្រហែលប៉ុន្មាន?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធានដោយត្រង់ថា ក្នុងការហូបនៅកន្លែងនោះគឺមិនហួសពីមួយចានចង្កឹះទេ ។ បើបបររាវបានមួយកា ហើយបើបបរខាប់ទៅបានមួយចានចង្កឹះ ។

**ស៖** ម៉េចបានជាលោកឆ្លើយថា បបររាវហ្នឹងបានមួយកា? បានន័យថាគេដួសដាក់កាហើយយកមកចែកឲ្យលោកហូប ឬក៏យ៉ាងម៉េច? បានជាលោកអះអាងថា បបររាវមួយកា?

**ឆ៖** ក្នុងការដួសបបររាវមួយកា នោះគឺវាមានជាតិទឹកច្រើនជាងអង្ករ បានច្រើនទៅ ។ ពេលណា ដែលបានបបររឹងមកគឺវាតិច មួយចានចង្កឹះ ។

**ស៖** យើងចង់ដឹងថា ពេលដែលទទួលបបរដែលលោកអះអាងថា មួយកា នេះ គេដាក់មួយកាអាប្រដាប់ដងទឹកផឹកហ្នឹងធ្វើពីដេរ៉ាហ្នឹងអី? មួយកាហ្នឹងឲ្យមកលោកតែម្តង ឬក៏គេដាក់ចានទេ លោកស្មានថា មួយចានហ្នឹងវាប្រហែលជាមួយកា?

**ឆ៖** គឺមួយកា ហ្នឹងអត់បានពេញមួយកាទេ សូមជម្រាបលោកប្រធាន គ្រាន់ធំតែកាទេ តែនៅកន្លះកាហ្នឹងទេ ។ នេះបបររាវ ។

**ស៖** ចុះការមុជទឹក តើគេឲ្យលោកមានការមុជទឹកដែរឬទេ? ហើយមុជទឹកហ្នឹងមួយថ្ងៃប៉ុន្មានដង? ហើយចាត់ចែងការងូតទឹកហ្នឹងយ៉ាងដូចម្តេច?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! អាបញ្ហាងូតទឹកនេះ គឺជាទូទៅ ពុំដែលបានញឹកញាប់ទេតាំងពីខ្ញុំនៅកន្លែងនោះ ។ គឺបានពីរដង ដោយសារខ្ញុំចេញទៅធ្វើការអីទៅ មានទឹកអីនៅតាមអំបែងពាងអំបែងអីទៅខ្ញុំចេះតែដងលាបខ្លួនអីទៅ ហ្នឹងជម្រាបប្រសាសន៍ដោយខ្លីប៉ុណ្ណោះ ។

**ស៖** អ៊ីចឹងនៅក្នុងអំឡុងពេលដែលលោកជាប់ឃុំឃាំងហ្នឹង គេអត់បានឱ្យលោកងូតទឹកទេ? អ៊ីចឹងមែនទេ ទាំងងូតនៅក្នុងបន្ទប់ ឬក៏នាំងូតនៅក្រៅគឺអត់មានទេ?

**ឆ៖** ពិតប្រាកដអ៊ីចឹងមែនហើយ ។

[០៩:៥៥:៥០]

**ស៖** ត្រឡប់ក្រោយបន្តិច លោកចាំទេ លោកគិតមើលថាតើលោកត្រូវបានគេបញ្ជូនចូលទៅក្នុងកន្លែងដែលត្រូវឃុំឃាំងលោកហ្នឹង គេបញ្ចូលទៅច្រកតាមទិសខាងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅពេលនោះគឺខ្ញុំពុំដឹងថា ចូលច្រកអីច្រកណា ខ្ញុំអត់ដឹងទេ ព្រោះពេលនោះមុខក៏ចងជាប់ ឡានក៏បិទជិត សូមជម្រាបប្រសាសន៍ដោយខ្លីប៉ុណ្ណោះ ។

**ស៖** ចុះពេលលោកចេញមកវិញ តើលោកចាកចេញពីកន្លែងនោះដោយរបៀបណា? ហេតុផលយ៉ាងម៉េចបានជាលោកត្រូវបានចាកចេញពីទីនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! នៅពេលដែលខ្ញុំបាទបានចេញ នៅពេលនោះគឺខ្ញុំក៏ពុំដឹងថាគេ គិតឃើញយ៉ាងម៉េច ហើយក៏គេយ៉ាងម៉េចក៏ខ្ញុំអត់ដឹងដែរ ។ ក៏ប៉ុន្តែ នៅពេលដែលគេឱ្យខ្ញុំចេញនោះក៏ក្នុង អំឡុងពេលដូចគេធ្វើ គេហៅខ្ញុំយកទៅប្រើទៅធ្វើការងារដែរ ក៏ប៉ុន្តែ គេបណ្តើរខ្ញុំមកតែខ្នោះជើងគេដោះចេញ រួចហើយគេចងមុខខ្ញុំដដែល ដៃខ្ញុំគេចងជាធម្មតានៅពេលដែលខ្ញុំចេញ ។ ក៏ប៉ុន្តែ វាខុសប្លែកថា គេដោះខ្នោះជើងខ្ញុំចេញហើយ គេចងដៃខ្ញុំជាប់ទៅវិញហើយ គេបណ្តើរខ្ញុំចេញមកវិញហើយគេលើកបោះទៅលើឡានតែប៉ុណ្ណោះ ។

**ស៖** មានចងមុខទេ នៅពេលគេបោះលើឡានពេលដែលបញ្ចេញនេះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលនោះគឺគេចងមុខខ្ញុំដដែលដូចដែលគេឱ្យខ្ញុំទៅចាក់លាមកដូចគ្នាអ៊ីចឹង ។

**ស៖** ហើយពេលគេធ្វើហ្នឹងពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** សូមជម្រាប្រសាសន៍លោកប្រធាននៅពេលយប់ ។

**ស៖** ហើយគេដឹកលោកទៅឱ្យចុះនៅកន្លែងណា?

**ឆ៖** សូមជម្រាបប្រសាសន៍! រឿងទីតាំងដែលចុះនោះខ្ញុំបាទពុំបានដឹងច្បាស់ទេ នៅពេលដែលគេ ទម្លាក់ខ្ញុំចុះនោះ គឺកន្លែងនោះគឺមានភាពងងឹត ។ ហើយពេលដែលស្រាយមុខខ្ញុំហើយគេដាក់ឱ្យខ្ញុំចុះមកហ្នឹង បើសិនណាខ្ញុំមិនភ្លេចទេ ហើយខ្ញុំក៏ចាំពុំបានដែរ បើខ្ញុំប៉ាន់ស្មានមើលដែលល្បឿនឡានដែល

បើក ដែលខ្ញុំនៅក្នុងឡាននោះប្រហែលជាដប់ប្រាំនាទី រួចហើយគេឈប់ឡាននោះ គេស្រាយមុខខ្ញុំគេធាក់ខ្ញុំទម្លាក់មក ឡាននោះក៏ចេញបាត់ទៅ ។

[០៩:៥៩:២៦]

**ស៖** ចុះចំណងដៃដែលគេចងធ្វើម៉េច?

**ឆ៖** ពេលនោះចំណងដៃគឺគេបន្ធូរហើយ គេបន្ធូរតែចំណងដៃទេ តែខ្ញុំដូចថា ខ្ញុំបានប៉ុណ្ណេះតែវាអត់ស្រាយផុតពីដៃទេ ។ ក្រោយមកគឺមានមនុស្សពីរនាក់បើកម៉ូតូមកឌុបខ្ញុំទៅតទៅទៀត។

**ស៖** ហើយឌុបលោកយកទៅដាក់នៅកន្លែងណា?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន នៅពេលដែលពីរនាក់ដែលមកស្រាយចំណងខ្ញុំហើយឌុប ខ្ញុំបន្តទាំងខ្លួនទទេរ ហើយនិងខោខ្លីនោះ ខ្ញុំពុំដឹងថា មនុស្សនោះជាអ្នកណា ហើយខ្ញុំក៏មិនដែលស្គាល់មនុស្សផង រាងចំណាស់ៗផង ហើយខ្ញុំក៏សួរស្គាល់ដែរ ។ ក្រោយពេលដែលដឹកខ្ញុំទៅវិលវល់ៗនៅទីក្រុងភ្នំពេញហ្នឹង ស្រាប់តែខ្ញុំហាក់បីដូចជានឹកឃើញកន្លែងមួយដែលខ្ញុំចាប់អារម្មណ៍ប្រហែលជាស្ពាតចុងស្ពានជ្រោយចង្វា ស្ពាតចាស់ ។ នេះបើតាមខ្ញុំបាទចំណាំបាន គឺប្រហែលជួរនុ៎ង ហើយបានខ្ញុំហាក់បីដូចជាឃើញមិត្តអ៊ាម ដែលជាប្រធានអង្គភាពទទួលបន្ទុកពី មិត្តយ៉ឺន មិនដឹងអីក៏មិនដឹង ខ្ញុំអត់ដឹងដែរ ។ ក៏ប៉ុន្តែគេបានបញ្ជាឲ្យអ្នកម៉ូតូហ្នឹង ឌុបមកវ៉ារទេះភ្លើងសំរោងទាំងយប់ហ្នឹង ។ លុះដល់ ឌុបដល់វ៉ាសំរោងខ្ញុំក៏អត់ដឹងថា កន្លែងនោះធ្វើអីៗក៏ខ្ញុំអត់ដឹងដែរ ក៏ស្រាប់តែ ប៉ុន្តែនៅពេលដែលខ្ញុំទៅដល់វ៉ាសំរោងនោះខ្ញុំហាក់បីដូចជាឃើញស្ថានភាពមួយកន្លែងនោះ ហាក់បីដូចជាកន្លែងដែលពួកកសិកម្មគេធ្វើស្ករត្នោត រួចហើយក៏ខ្ញុំគេទុកខ្ញុំនៅហ្នឹងទៅ ។ ចៃដន្យខ្ញុំទាំងខ្លួនទទេរ ហើយនិងខោខ្លីដដែលហ្នឹង ហាក់បីដូចជាខ្ញុំមានស្គាល់មិត្តម្នាក់ដែលធ្លាប់ស្គាល់គ្នាហ្នឹង គេឲ្យខោខ្ញុំ ហើយនិងអាវខ្ញុំទាំងយប់ហ្នឹង ខ្ញុំផ្លាស់ទៅ ក៏សម្រាកដាច់ដោយឡែកពីគ្នាទៅ ។ គឺយើងខ្ញុំចាំបានដោយខ្លីប៉ុណ្ណេះ ។

សូមប្រសាសន៍លោកប្រធាន ។

**ស៖** ហើយជាបន្តទៀតលោកទៅធ្វើដំណើរទៅទិសខាងណា? ទៅរស់នៅទីណា?

**ឆ៖** សូមជម្រាបលោកប្រសាសន៍លោកប្រធាន! នៅពេលដែលខ្ញុំបាទបានរស់នៅនៅក្នុងកសិដ្ឋានធ្វើស្ករហ្នឹង គឺនៅពេលដែលខ្ញុំសម្រាកយប់ដែលខ្ញុំទៅដល់ហ្នឹង គឺខ្ញុំសម្រាក គឺខ្ញុំមិនប៉ាននិយាយអីទាំងអស់ ហើយក៏ខ្ញុំសម្រាកដាច់ពីគេ ពីឆ្ងាយពីគេ ក្នុងរោងជាមួយគ្នា តែខ្ញុំដាច់ឆ្ងាយពីគេ ។ នៅពេលដែលព្រឹកឡើង បានខ្ញុំស្គាល់ច្បាស់ថា មិត្តអ៊ាម នេះ គេទៅអប់រំខ្ញុំ ។ គេថា “មិត្តឯង គឺមក

កសាងខ្លួនសាជាថ្មីម្តងទៀត ហើយកុំទៅតាម មិត្តយឹន ហើយនិងតាមមិត្តលឿន, មិត្តនន់ ដែលជាខ្មាំងនោះ ហើយមិត្តឯងនៅពេលដែលមិត្តឯងមកដល់កន្លែងនេះ មិត្តឯងខំធ្វើការ" ហើយក៏បានគំរាមខ្ញុំថា "ក្បាលអ្នកណា គឺសក់អ្នកនោះ អ្វីដែលអង្គការនិយាយប្រាប់មិត្តឯង គឺមិត្តឯងមិនបាននិយាយតទៅទៀតទេ ក្បាលអ្នកណាគឺសក់អ្នកនោះ" ។ ដូច្នេះហើយអារម្មណ៍របស់យើងខ្ញុំចាប់តាំងពីគេនិយាយរឿងនោះមក គឺខ្ញុំមិននិយាយសូម្បីតែនៅជាមួយគ្នា និយាយជាមួយគ្នា គេសួរនាំពីរឿងអី គឺខ្ញុំមិនខ្វល់ពីរឿងអីទាំងអស់ គឺខ្ញុំគិតតែពីរឿងការងារដែលគេប្រគល់ការងារឲ្យធ្វើរហូតដល់មកឆ្នាំ-- ខ្ញុំធ្វើការនៅនោះក្នុងរយៈពេលប្រមាណជាមួយឆ្នាំដែលគេឲ្យខ្ញុំហ្នឹងរកអសដើម្បីស្ទូរត្នោត ។ ហើយគេកំណត់ឲ្យខ្ញុំទៀតថា ក្នុងត្នោតបីខ្នះ ពីរនាក់គ្នាប្រាំមួយនាក់-- ពីរនាក់ត្នោតប្រាំមួយខ្នះនេះ ធ្វើម៉េចមិត្តឯងរកអុសដុតឲ្យបាន តែបើសិនណាមិត្តឯងរកអត់បានទេ មិត្តឯងទទួលខុសត្រូវចំពោះមុខអង្គការ ។

[១០:០៤:៥៥]

ដូច្នេះការទាំងអស់នេះហើយបានជាយើងខ្ញុំខំរហូតដល់ខ្ញុំបានចប់ ហើយក៏មិត្តអ៊ាម ហ្នឹងគេហៅខ្ញុំទៅអង្គភាពវិញ នៅក្រសួងកម្មករកំពង់ផែភ្នំពេញដែល ជាគឺឡូលេខ៦ដដែលហ្នឹង ។ គេអត់ចូលទៅក្នុងអង្គភាពទៀត ជាពេលនោះ គេឲ្យខ្ញុំបាទហ្នឹងនៅដាំអីវ៉ាន់នៅមេភ្លើង គេហៅថាបឹងបាយ៉ាបនោះតទៅទៀត ។ នៅពេលដែលយើងខ្ញុំដាំអីវ៉ាន់ ហើយនិងធ្វើស្រែធ្វើអី គេឲ្យយើងដាំតែអីវ៉ាន់ទេ ប៉ុន្តែខ្ញុំអាចឆ្លៀតធ្វើស្រែក្នុងមួយរ៉ៃមួយអីអ៊ីចឹងទៅ ក្នុងរយៈពេលដែលខ្ញុំទៅរស់នៅនៅតំបន់បឹងកបាយ៉ាបនោះហើយនិងដាំអីវ៉ាន់ដើម្បីផ្គត់ផ្គង់ឲ្យអង្គភាព ។

ដូច្នេះ គេមិនបានឲ្យខ្ញុំច្រើនគ្នាទេ គឺខ្ញុំឲ្យខ្ញុំហ្នឹងដាំអីវ៉ាន់សម្រាប់អង្គភាពកម្មករគឺឡូលេខ៦ហ្នឹងគឺឲ្យដាំតែខ្ញុំទេ ហើយនិងសល់ពេលប៉ុនណា គឺឲ្យខ្ញុំធ្វើស្រែបន្តបន្ទាប់រហូតផ្គត់ផ្គង់បន្លែបង្ការ ដើម្បីឲ្យអង្គ-ភាពសម្រាប់សហជីពរបស់គាត់ របស់យើងហ្នឹងឲ្យបានធូរធារតែប៉ុណ្ណោះ ។

**ស៖** នៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ លោកនៅកន្លែងណា ហើយធ្វើអី?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលយើងខ្ញុំរស់នៅបឹងបាយ៉ាបមេភ្លើងនោះគឺខ្ញុំបាទចាប់តាំងពីចេញអំពីវត្តសំរោង ហៅវ៉ាសំរោងនេះទៅ គឺខ្ញុំបាទឆ្នាំ១៩៧៩ នៅថ្ងៃទី៦ ខែមករាហ្នឹង ខ្ញុំក៏មិនដឹងហេតុការណ៍ដែរ ដោយសារខ្ញុំប្រឹងខំកសាងខ្លួននៅកន្លែងនោះមានប្រជាជន ហើយនិងកម្មករមួយចំនួនដែលគាត់ទៅយកបន្លែពីខ្ញុំ ទៅកាប់បន្លែយកពីខ្ញុំមកហ្នឹង គាត់ប្រាប់ថា "ភ្នំពេញ យើងអត់ស្រួលទេ ឥឡូវកម្មករទាំងអស់គ្នាហ្នឹងគេរៀបអីវ៉ាន់ត្រៀមអស់ហើយ" ។ ខ្ញុំក៏អត់មានចាប់អារម្មណ៍

ហើយក៏ខ្ញុំមិនសូវជាយកចិត្តទុកដាក់ ។ សូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់បានយកចិត្តទុកដាក់ទេ គឺខ្ញុំគិតខំតែពីការងារកសាងសតិអារម្មណ៍និងស្មារតីរបស់ខ្ញុំរហូត ។ លុះដល់ល្ងាចម៉ោងប្រាំឡើង គេទៅប្រាប់ទៀតថា “ម៉េចមិត្តឯងអត់ទៅនឹងគេទេ?” ខ្ញុំថា “មិនដឹងទៅណា បើខ្ញុំនៅតែឯង ខ្ញុំចោលអីវ៉ាន់ហ្នឹង?” ។

ខ្ញុំសូមជម្រាបអ៊ីចេះ ស្រាប់តែម៉ោងប្រាំកន្លះឡើង ខ្ញុំមិនទុកចិត្តទេ ឮគេនិយាយអ៊ីចឹងខ្ញុំដើរឡើងមកលើផ្លូវរទេះភ្លើង ដល់ដើរឡើងមកលើផ្លូវរទេះភ្លើង ឃើញឡានខាងរោងចក្រ រោងអីណាចេញប្រសេចប្រសាច ខ្ញុំចុះទៅវិញៗ ខ្ញុំប្រមូលអីវ៉ាន់ខោអាវរបស់ខ្ញុំហ្នឹង ដើរឡើងមក ។ ចៃដន្យមកដល់ហ្នឹង អង្គភាពរបស់ខ្លួនក៏ចេញអស់រលីង ខ្ញុំក៏រត់រហូតមកដល់ហ្នឹងរោងចក្រប្រេងកន្ទក់នឹងច្រាំងចំរេះ ខ្ញុំឃើញឡានរោងចក្រគេហ្នឹង ខ្ញុំសុំដោយសារគេៗដល់មកវត្តដងទង់មក ។ គេឡានខាងមុខគេថាអត់មានសាឡាងឆ្លងទៅ ឆ្លងទឹកទេ ទាំងអស់គ្នាហ្នឹងក៏ចុះដើរទៅ ហើយឡានហ្នឹងក៏គេបើកខ្ញុំចុះមក គេឡានហ្នឹងគេបើកចេញទៅផ្លូវជាតិលេខ៥ រហូតមក ហើយខ្ញុំនេះក៏ងេកងាកហើយនៅតែឯងហើយ ងេកងាក--

[១០:០៩:០៣]

**ស៖** បានហើយៗ ។ មើលមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ព្រោះលោក ឡាយ ចាន់ ហ្នឹងនៅក្នុងក្រុមបី តើមេធាវីក្រុមបីហ្នឹងមានឯកសារណាគាំទ្រដល់ការប្ដឹងទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? ដោយសារនៅក្នុងឯកសារដែលមាន គឺមានតិចតួចណាស់អំពីឯកសារគាំទ្រដល់ការប្ដឹងទាមទារ ។ មូលហេតុនេះហើយបានជាអង្គជំនុំជម្រះធ្វើការកោះអញ្ជើញកំណត់យកដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឡាយ ចាន់ ហ្នឹងមកដេញដោល ។

**លោក គឹម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ។ តាងនាមឲ្យជនរងគ្រោះដែលជាដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី យើងខ្ញុំសុំបញ្ជាក់ថា យើងមិនមានលទ្ធភាពនៅក្នុងការរកឯកសារដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះបានទេ ។ ក៏ប៉ុន្តែ យើងនៅមានសំណួរមួយចំនួនដែលអាចនឹងពន្យល់ឲ្យអង្គសវនាការទាំងមូលឲ្យយល់ អំពីស្ថានភាពជាក់លាក់ចំពោះជនរងគ្រោះនេះ ដែលគាត់បានអះអាងនៅក្នុងពាក្យបណ្ដឹងរបស់គាត់ ។

ដូច្នេះ ចំពោះឯកសារយើងខ្ញុំមិនមានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកចៅក្រម ធូ មណី ។

**សួរដោយចៅក្រម ធូ មណី៖**

**ស៖** សូមអរគុណលោកប្រធាន! លោក ឡាយ ចាន់ លោកបានបញ្ជាក់អំម្បាញ់មិញហើយថា ដំបូងគ្រាន់លោកបញ្ជាក់ថា លោកមិនបានដឹងថាទីកន្លែងលោកធ្លាប់ឃុំហ្នឹងនៅកន្លែងណាទេ ប៉ុន្តែរយៈកាលក្រោយមកលោកបានឮអ្នកយាមហ្នឹងជជែកគ្នាណ៎ាថា កន្លែងហ្នឹងគឺជាសាលាទួលស្លែង ។ តើលោកបានស្តាប់ឮយ៉ាងម៉េច? តើសាលាទួលស្លែងអ៊ីចឹង ឬក៏គុកទួលស្លែង?

[១០:១១:៤៣]

**ឆ៖** គឺខ្ញុំបាទឮសំឡេងដែលវានិយាយ អ្នកយាមដែលគេនិយាយហ្នឹង គេនិយាយថាសាលាទួលស្លែងអ៊ីចឹងតែម្តង គឺខ្ញុំមិនបានឮថាគុកអីទេ ។ ខ្ញុំអត់ដឹងដែរ គេនិយាយអ៊ីចឹង ។

**ស៖** ក្រៅពីឮអ្នកយាមពីរនាក់ដែលលោកបានឮអ៊ីចឹង លោកអាចមានស្អីផ្សេងទេ ដែលសម្គាល់ថាកន្លែងដែលលោកជាប់ឃុំហ្នឹង គឺជាគុកដែលយើងសព្វថ្ងៃហៅថា គុកទួលស្លែងហ្នឹង គឺមន្ទីរស-២១ហ្នឹង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំបាទ ដែលខ្ញុំបាទកត់សម្គាល់ថា ជាកន្លែងឃុំឃាំងមនុស្ស គឺដោយខ្ញុំបាទបានឮសម្រែកថ្ងូរ ហើយនិងសម្រែកយំ ដែលខ្ញុំបាទមើលពុំឃើញជាច្រើននាក់ប៉ុណ្ណឹង ។

**ស៖** លោកបានបញ្ជាក់ហើយថា មិនបានឮសំឡេងថ្ងូរ និងសំឡេងស្រែកយំ ប៉ុន្តែរយៈពេលបីខែដែលលោកជាប់នៅនុ៎ង លោកដែលបានជួបអ្នកជាប់ឃុំដទៃទៀតដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលនោះ ខ្ញុំបាទគ្មានសិទ្ធិសេរីភាពនឹងដើរ ហើយនិងអើតមើលអ្នកទោសដទៃទៀតទេ ។ សូមជម្រាបប្រសាសន៍ដោយខ្លី ។

**ចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ ។

**សួរដោយប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីថៅក្រមមានសំណួរអីទៀតទេ?

**ស៖** លោក ឡាយ ចាន់ តើពេលដែលគេសួរចម្លើយលោកហ្នឹង គេប្រព្រឹត្តទៅនៅពេលយប់ ឬក៏នៅពេលថ្ងៃ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ពេលដែលសួរចម្លើយខ្ញុំបាទ ពីរដងសុទ្ធតែសឹងពេលយប់ទាំងអស់ ។ សូមជម្រាបប្រសាសន៍ ។

[០៩:១៤:០៧]

**ស៖** ហើយគេសួរចម្លើយលោកនៅពេលយប់ហ្នឹង ប្រហែលម៉ោងប៉ុន្មានដែរ? ហើយគេប្រើ សួរម្តងៗប្រើ-- ចំណាយរយៈពេលប៉ុន្មានម៉ោង?

**ឆ៖** សូមជម្រាបប្រសាសន៍ នៅពេលដែលគេសួរចម្លើយខ្ញុំបាទ ខ្ញុំបាទ នៅពេលដែលខ្ញុំបាទឆ្លើយនូវសំណួរគេមួយៗ គឺខ្ញុំដឹងបានប្រហែលជាដប់ប្រាំនាទី ឬក៏ម្ភៃនាទីក៏ខ្ញុំសន្លប់បាត់ទៅ ខ្ញុំអត់ដឹងអីបន្តទៀត ។

**ស៖** អំឡុងពេលគេសួរចម្លើយហ្នឹង គេមានបំភ្លឺកន្លែងសួរចម្លើយទេ? ហើយបានអីបំភ្លឺកន្លែងសួរចម្លើយ?

**ឆ៖** សូមជម្រាបប្រសាសន៍! នៅពេលនោះ ខ្ញុំអត់ដឹងអីទាំងអស់ ពីព្រោះអីនៅពេលនោះ ភ្នែកខ្ញុំគេចងងងឹតរហូត ។ នៅពេលដែលគេនាំចេញពីកន្លែងឃុំឃាំងមក គឺខ្ញុំងងឹតភ្នែករហូត ។ សូមជម្រាបប្រសាសន៍លោកប្រធានដោយខ្លី ។

**ស៖** លោកមានឮសំឡេងអ្វីផ្សេងទៀតទេ? ពេលក្នុងអំឡុងពេលគេសួរចម្លើយ ។ ពេលចាប់ផ្តើមដំបូងមុនពេលសន្លប់នោះ តើលោកមានឮសំឡេងអ្វីដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលមុនខ្ញុំបាទសន្លប់នោះ គឺខ្ញុំបាទឮឈើហើយនិងឮសម្រែកអ្នកផ្សេងៗដែលថ្ងូរ ហើយឆ្ងាយពីខ្លួនខ្ញុំគ្រាន់ដែរ ។ បើខ្ញុំស្មានមើលប្រហែលជាប្រាំទៅប្រាំមួយម៉ែត្រចេញពីខ្លួន ឬដប់ម៉ែត្រ តាមខ្ញុំស្តាប់បានសំឡេងដែលថ្ងូរ ហើយនិងស្រែក ។ សូមជម្រាបប្រសាសន៍លោកប្រធាន ។

**ស៖** មានឮសំឡេងម៉ាស៊ីនភ្លើងរោទ៍ខ្លាំងដែរឬទេ នៅក្នុងអំឡុងពេលនៃការនាំលោកទៅសួរចម្លើយមុនដំបូងនៅពេលលោកសន្លប់នោះ?

**ឆ៖** សូមជម្រាបលោកប្រសាសន៍! ហាក់បីដូចជា ឮស្នូរដែរ ប៉ុន្តែមិនដឹងជាឮស្នូរសំឡេងឡាន ឬយ៉ាងម៉េចខ្ញុំមិនសូវដឹងដែរ ពីព្រោះខ្ញុំងងឹតភ្នែកគេចងមុខបាត់ទៅហើយ ។

**ប្រធានអង្គជំនុំ៖**

នៅក្នុងពាក្យបណ្តឹងរបស់លោក លោកសរសេរដូច្នេះថា "ពេលដែលគេសួរចម្លើយខ្ញុំ គឺបិទមុខមិនឲ្យឃើញពួកវា បញ្ឆេះម៉ាស៊ីនភ្លើងយ៉ាងខ្លាំងកុំឲ្យសំឡេងស្រែក ឬធ្វើទារុណកម្មឮដល់ខាងក្រៅ" នេះជាខ្លឹមសារដែលលោកបានសរសេរនៅក្នុងពាក្យបណ្តឹងរបស់លោក ។ អ៊ីចឹង ហើយបានជាយើងសួរសំណួរនេះឲ្យបានជាក់លាក់ ។

ឥឡូវនេះ សូមប្រគល់វេទិកានេះជូនទៅខាងសហព្រះរាជអាជ្ញា តើសហព្រះរាជអាជ្ញាមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** អរគុណលោកប្រធាន ។ លោក ឡាយ ចាន់ លោកបញ្ជាក់មកមើល តើលោកធ្លាប់ស្គាល់ទីក្រុងភ្នំពេញទេ មុនពេលចាប់ខ្លួន?

[១០:១៨:០២]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំបាទស្គាល់ដែរទីក្រុងភ្នំពេញ ក៏ប៉ុន្តែច្រកល្ហកល្ហេវអីណាអីណីខ្ញុំមិនដឹងទេ ព្រោះនៅពេលដែលខ្ញុំមករស់នៅទីក្រុងភ្នំពេញ ជាកម្មករក្រសួងពាណិជ្ជកម្មនេះ គឺខ្ញុំបាទទើបតែនឹងមកអំពីសមរភូមិដែលខ្ញុំបាទរបួស។ ហើយខ្ញុំបាទបានមករស់នៅនឹងទួលគោក ហើយទួលគោកហ្នឹងនៅមិនបានយូរដែរ ដោយអង្គភាពខ្ញុំនេះ គេឲ្យទៅរៀបឃ្លាំងនៅគីឡូលេខប្រាំមួយ ។ ដូច្នេះខ្ញុំស្គាល់បានតែគីឡូលេខប្រាំមួយ ហើយនិងមកទួលគោកវិញ ហើយទួលគោកនោះខ្ញុំចាំបានតែអង់តែនទូរទស្សន៍ពីដើមទេ ។ សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។

**ស៖** អរគុណ ។ អម្បាញ់មិញលោកបានបញ្ជាក់ថា ពេលលោកជិះឡាំប៉ាតា និងគូរកនរបស់លោកមកដល់គុលស្ពានជ្រោយចង្វា លោកត្រូវចុះពីឡាំប៉ាតានោះ ហើយគេចងមុខ និងចងដៃខ្លួន បោះទៅលើឡាន ។ ពីកន្លែងឡាន-- ពីកន្លែងដែលគុលស្ពានជ្រោយចង្វា មកកន្លែងឃុំឃាំងធ្វើដំណើររយៈពេលប៉ុន្មាន?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ប្រហែលជាពីដប់ប្រាំនាទី ទៅម្ភៃនាទី ព្រោះទីក្រុងកាលនោះ ស្ងាត់អត់សូវមានឡានដូចពេលបច្ចុប្បន្នទេ ។

**ស៖** ឡាននោះបត់ចូលមកភ្នំពេញ ឬចេញពីភ្នំពេញ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដឹងអ្វីទាំងអស់នៅពេលនោះ គឺខ្ញុំដឹងតែខ្ញុំចងមុខ គេបោះទៅលើឡាន គឺគេឃុំជិត ។ ខ្ញុំអត់ដឹងថាគេទៅអីណាមកអីណា ខ្ញុំអត់ដឹងដែរ ។ សូមជម្រាបលោកព្រះរាជអាជ្ញា ។

**ស៖** ឡាននោះបែរមុខទៅខាងណាជាស្រេចហើយ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា នៅពេលដែលគេបានចងខ្ញុំបាទ ចងមុខខ្ញុំបាទហើយនោះ ឡានគេក៏គេមិនដឹងថាចតខាងណា អីខាងណា ក៏ខ្ញុំអត់ដឹងដែរ ។ ស្រាប់តែគេចងរួចហើយបានកូនឡានឡាំប៉ាតា ដែលដឹកខ្ញុំចេញពីនេះមក គេចេញឮសំឡេងទៅខាងស្តាំខ្ញុំ មិនដឹងគេទៅអីណាហើយ ។ បានឡានមួយទៀតហ្នឹង គេចូលមក ហើយគេលើកបោះទៅ ខ្ញុំមិនដឹងថា ឡាននោះបរទៅខាងណា អីខាងណា ។ សូមជម្រាបលោកសហព្រះរាជអាជ្ញា ដោយខ្លីប៉ុណ្ណេះ ។

**ស៖** អរគុណ ។ សូមលោកបញ្ជាក់មួយទៀត លោកបានបញ្ជាក់ថា ពេលដែលគេធ្វើទារុណកម្មលោកធ្វើដែលលោកជាប់ឃុំ គេសួរចម្លើយលោកពីរដង ។ លើកទីមួយ គឺគេវៃគំត្រចៀក និងទាត់លោកបណ្តាលឲ្យលោកសន្លប់ ។ ចុះលើទីពីរ? គេធ្វើទារុណកម្មយ៉ាងម៉េចមកលើលោក?

[១០:២១:៤១]

**ឆ៖** ហើយលើកទីពីរ ក៏មិនខុសគ្នាពីលើកទីមួយដែរ ក៏ប៉ុន្តែគ្រាន់តែការសួរនោះ វាប្រយោគខុសគ្នា ។ គ្រាន់តែប្រយោគទីមួយដែលគេសួរខ្ញុំ ថាខ្ញុំធ្លាប់រួមជាមួយ មិត្តយិន និងមិត្តអាត ។ បញ្ចាលួចអង្ករ ហើយក្បត់ជាមួយអង្គការ គឺខ្ញុំឆ្លើយថា “ខ្ញុំអត់ដឹង” ។ ដល់លើកទីពីរទៀត ថាមិត្តឯងបានរួមជាមួយ មិត្តយិន, មិត្តអាត ចូល *សេអ៊ីអា* ដែរឬទេ? ខ្ញុំឆ្លើយថា “ខ្ញុំអត់ដឹង” ថ្វីត្បិតតែខ្ញុំជានីរសារមែន ក៏ប៉ុន្តែពេលដែលគេទៅប្រជុំទៅអី ខ្ញុំអត់ដឹងអត់ដែលបានទៅទេ ។ ទើបតែហ្នឹងពេលនេះទេ ដែលខ្ញុំ ដែលគេហៅខ្ញុំមក ។ ខ្ញុំឆ្លើយប៉ុណ្ណឹង ក៏គេធ្វើទារុណកម្មខ្ញុំតែម្តងទៅ ខ្ញុំសន្លប់បាត់ទៅ ។ សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។

**ស៖** លោកបញ្ជាក់ឲ្យច្បាស់មើល៎ ពេលដែលធ្វើទារុណកម្មលើកទីពីរ គេធ្វើយ៉ាងម៉េច?

**ឆ៖** ពេលដែលគេសួរខ្ញុំរួចហើយ គេទាត់ដើមទ្រូងខ្ញុំមួយជើង រួចហើយគេវៃខ្ញុំមួយដៃ រួចហើយខ្ញុំងើបមក គេសួរនៅតែចូល *សេអ៊ីអា* ថ្ងៃណា? លើកនេះ ហើយបានថា ខ្ញុំអត់មានចូល *សេអ៊ីអា* ទេ ។ ដូច្នេះ គេវៃខ្ញុំម្តងទៀត ត្រូវកៀនត្រចៀកខាងឆ្វេងហ្នឹងម្តងទៀត ខ្ញុំក៏ដួលសន្លប់ទៅទៀតទៅ

ហើយក៏គេអូសខ្ញុំយកទៅកន្លែងឃុំឃាំងវិញ ។ ពេលដល់កន្លែងឃុំឃាំងហើយ គេជះទឹកខ្ញុំហើយ បានខ្ញុំដឹងខ្លួនឡើង ខ្ញុំមិនដឹងនៅកន្លែងណាទេ លីលើហើយពេលនោះ ។

**ស៖** លោកបញ្ជាក់ម្តងទៀតមើល ពេលឃុំខ្លួនលោកគេឲ្យរបបមួយថ្ងៃប៉ុន្មានពេល? ព្រឹកម៉ោងប៉ុន្មាន? ល្ងាចម៉ោងប៉ុន្មាន?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នៅពេលដែលរបបហូបចុកនៅតំបន់នោះ កន្លែងនោះ គឺមិនទៀងទេ ។ ប៉ះត្រង់ណាពេលថ្ងៃត្រង់ក៏ម្តងទៅរហូតដល់ព្រឹកតែម្តង ប៉ះត្រង់ណាក៏ល្ងាចទៅ ប៉ះត្រង់ណាក៏បានពីព្រឹកមក វាអត់ទៀង ។ សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាដោយខ្លី ។

**ស៖** ពេលកាប់រណ្តៅដាំចេក តើគេដោះដែល-- គេស្រាយមុខខ្លួនទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! នៅពេលដែលគេនាំខ្ញុំបាទ ចេញពីកន្លែងឃុំឃាំង គឺគេចងមុខរហូតដល់ទៅកន្លែងកាប់ ។ គេគ្រាន់តែដល់កន្លែងងងឹតហើយ បានគេស្រាយមុខខ្ញុំបាទហើយអ្នកយាម អ្នកនាំខ្ញុំទៅនោះ គឺចង្អុលថា កាប់ត្រង់នេះ កាប់ត្រង់នេះ ត្រង់នោះហើយទេ ហើយក៏ខ្ញុំធ្វើទៅតាមគេទៅ ។ ហើយប្លុកជាមួយនឹងអាយកលាមក៏ទៅកប់ផង ទៅចាក់ផង តែប៉ុណ្ណឹង ។ សូមជម្រាបប្រសាសន៍ ។ ដោយខ្ញុំមិនដឹងថា តំបន់នោះកន្លែងណា ព្រោះកន្លែងខ្លះគេនាំខ្ញុំទៅខាងនេះ ម្តងខ្លះគេនាំទៅខ្ញុំទៅខាងនោះ ស្រេចតែហ្នឹងកន្លែងគេដែលគេនាំខ្ញុំទៅ ។ ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។

[១០:២៥:០៧]

**ស៖** ពេលជីករណ្តៅនោះមាននរណាក្រៅពីរូបលោកទៀតទេ?

**ឆ៖** សូមជម្រាបប្រសាសន៍! នៅពេលដែលខ្ញុំកាប់រណ្តៅនោះ គឺខ្ញុំសម្លឹងនៅជុំវិញខ្លួនរបស់ខ្ញុំ គឺអត់មានអ្នកណាក្រៅអំពីអ្នកយាម នៅដើរខ្វាត់ខ្វែងនៅកន្លែងដែរងងឹតៗនោះទេ ។ នេះសូមជម្រាបប្រសាសន៍ដោយខ្លីប៉ុណ្ណេះ ។

**ស៖** ពេលគេចាប់លោក លោកបានបញ្ជាក់ថា គេដោះយកខោអាវលោកទុកតែខោខ្លី រីឯក្រម៉ាគេចងមុខ ។ ចុះពេលដែលគេដោះលែងលោកវិញ គេឲ្យសម្លៀកបំពាក់អីទៅលោក?

**ឆ៖** សូមជម្រាបលោកប្រសាសន៍លោកព្រះរាជអាជ្ញា! នៅពេលដែលគេដោះលែងខ្ញុំបាទ គេពុំទាន់មានខោអាវអ្វីសម្រាប់ឲ្យខ្ញុំបាទទេ គឺចងមុខ គេបោះខ្ញុំទៅលើឡានដដែល តែគេដឹកខ្ញុំចេញរួចហើយឡានបើកដល់ឆ្ងាយ ហើយបានគេធាក់ខ្ញុំទម្លាក់ហើយ តែគេគ្រាន់តែស្រាយមុខរួច គេបន្ធូរដៃខ្ញុំចេញមក

ហើយ ។ មិនទាន់មានខោអាវអីទេ ដូច្នេះ គេទម្លាក់ខ្ញុំនៅក្រោយឡាន ឡាននោះគឺគេបើកចេញបាត់ទៅ ។ ហើយខ្ញុំក៏មិនដឹងថា ឡាននោះក៏គេបើកទៅខាងណា អីខាងណា គឺខ្ញុំសម្លឹងមើលវាមិនឃើញដែរ ។ វាមើលឃើញតែវាអត់ស្គាល់ថា ទៅជ្រុង ទៅច្រកណា ហើយខ្ញុំអត់ដឹង ។ សូមជម្រាបលោកព្រះរាជអាជ្ញា ។

**ស៖** លោកបញ្ជាក់មើល តើគេឲ្យសម្លៀកបំពាក់អីក្រៅពីខោខ្លីហ្នឹងទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នៅពេលដែលគេឲ្យសម្លៀកបំពាក់ខ្ញុំនោះ គឺគេអត់មានឲ្យអីក្រៅអំពីសម្លៀកបំពាក់ដែលខ្ញុំទៅពីចូលកន្លែងឃុំឃាំងហ្នឹងទេ ។ ខោតែមួយចង្កេះហ្នឹង រហូតដល់ពីរនាក់ដែលគេនៅរង់ចាំខ្ញុំ ដែលគេទម្លាក់ខ្ញុំហ្នឹងហើយ គេបាន-- ខ្ញុំទៅដល់ដែលមកសំរោងដែលទេបានមានមិត្តដែលខ្ញុំស្គាល់ហ្នឹង គេឲ្យខោអាវខ្ញុំស្លៀកពាក់ ។

[១០:២៧:២២]

**លោក អានីស អះម៉េត៖**

សូមគោរពលោកប្រធាន គឺថាខ្ញុំមិនមានសំណួរអ្វីទេ ហើយខ្ញុំស្នើថា ខ្ញុំនឹងទាក់ទងទៅនឹងការថ្លឹងថ្លែងពិចារណារបស់អង្គជំនុំជម្រះទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ ។ ខ្ញុំអត់មានសំណួរទេ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី អញ្ជើញចូលវិញដើម្បីបន្តនីតិវិធីនៃការពិភាក្សាដេញដោល ។ មន្ត្រីតុលាការសម្របសម្រួលរកកន្លែងសមរម្យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីបានសម្រាក ។

*[សវនាការសម្រាកពីម៉ោង ១០:២៨នាទី ដល់ម៉ោង ១០:៤៩នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ហើយជាបន្តនេះ សូមប្រគល់វេទិការនេះជូនទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសអាចសួរសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយមិនដឹងថាក្រុមណាមុនទេ ព្រោះ

ដើមបណ្តឹងរដ្ឋរូបនេះ ។ ហើយមិនដឹងថាក្រុមណាមុនទេ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺនៅក្នុងក្រុម៣ ដែលក្រុមបីត្រូវសួរមុន ហើយសួរជាអាទិភាពនូវពេលវេលាដែលមាន ហើយនៅសល់ទើបផ្តល់ក្រុមខាងក្រោយ ក្រុមផ្សេងទៀតឬក៏យ៉ាងម៉េច?

**សួរដោយលោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល ។ ជម្រាបសួរលោក ឡាយ ចាន់ នៅក្នុងការសួរសំណួរទៅកាន់លោក ឡាយ ចាន់ នេះ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីជាអ្នកសួរ ។ ហើយដំបូង គឺម៉ោងដែលសេសសល់ គឺទុកឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត ។

**ស៖** លោកអ៊ំ ឡាយ ចាន់ ខ្ញុំមានសំណួរមួយ ទីមួយគឺសួរទៅកាន់លោកអ៊ំ ពាក់ព័ន្ធទៅនឹងការកត់សម្គាល់របស់លោកអ៊ំ ដែលលោកអ៊ំបានជម្រាបលោកប្រធានថា លោកអ៊ំមិនអាចដឹងថាទីតាំងនោះនៅទីណាពិតប្រាកដទេ ក៏ប៉ុន្តែដោយសារមានសភាពខុសប្លែកគ្នា តើលោកអ៊ំអាចពន្យល់បានទេ អំពីសភាពខុសប្លែកគ្នានោះ លោកអ៊ំចង់មានប្រសាសន៍ថា យ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ភាពខុសប្លែកគ្នានៅពេលដែលខ្ញុំបានចូលទៅមើលនៅពេលដែលក្រោយមក វាខុសប្លែកគ្នាត្រង់ថា នៅកន្លែងទាំងអស់នោះ មានភាពល្អជាងកាលដែលខ្ញុំជាប់នៅនោះ ហើយគឺថា ភាពគ្រលីតគ្រលុកដែលខ្ញុំនិយាយ ខ្ញុំអីនៅជាប់កន្លែងហ្នឹង គឺវាដូចថា វាល្អឡើងវិញ វាល្អហើយ វាល្អខុសប្លែកពីមុន ។ ពីមុនវាដី ឬក៏សាបដែលចាក់នោះ វាគ្រហេងគ្រហូង វាបាក់បែក ហើយវាផ្លេះ វាផ្លាបច្រើនជាង គ្រាន់តែខុសប្លែកគ្នាប៉ុណ្ណឹង ។

**ស៖** សូមលោកអ៊ំពន្យល់បន្តិច ។ លោកអ៊ំថាដីគ្រលុកដែលអ៊ំឃើញ ឬក៏វាមានភាពផ្លេះផ្លាបដែលអ៊ំឃើញនៅពេលបច្ចុប្បន្នហ្នឹង តើនៅកន្លែងណាដែលលោកអ៊ំថាខុសគ្នាហ្នឹង ពីមុនដែលលោកអ៊ំថាជានៅកន្លែង ហើយបច្ចុប្បន្នវាខុសគ្នាយ៉ាងម៉េចកន្លែងហ្នឹង? ទីតាំងសព្វថ្ងៃដែលអ៊ំបានទៅហ្នឹង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅពេលដែលវាខុសប្លែកគ្នាត្រង់ថា នៅពេលដែលខ្ញុំទៅពេលបច្ចុប្បន្ន វាដីដែលខ្ញុំដើរហ្នឹង គឺវាស្មើជាងដីដែលអង្គាល់ខ្ញុំនៅជាប់ ។ នៅជាប់នៅកន្លែងនោះពេលដែលខ្ញុំដើរនោះ គឺរកិបរកុបច្រើនជាង ដែលខ្ញុំអាចដឹងបាន ។ សូមជម្រាបមេធាវី ។

**ស៖** ក្រៅពីដី តើមានការកត់សម្គាល់លើបរិវេណជុំវិញ ឬក៏ទីតាំងអគារអ្វីផ្សេងទៀត ដែលលោកអ៊ំ អាចមានឱកាសបានឃើញម្តងម្កាលនោះបានទេ មានអ្វីខុសប្លែកទៀតទេ?

**ឆ៖** គឺក្រៅអំពីដីវាបស្មើហើយ និងជុំវិញនោះ គឺខ្ញុំមិនបានដឹងអីតទៅទៀតទេ គឺខ្ញុំដឹងថា ក្នុងបរិវេណដែលខ្ញុំដើរ ពេលដែលខ្ញុំទៅសួរចម្លើយខ្ញុំតែប៉ុណ្ណឹង ។ សូមជម្រាបប្រសាសន៍លោកមេធាវី ។

[១០:៥៣:៣៣]

**ស៖** បន្តទៅទៀត ។ ខ្ញុំសូមសួរលោកអ៊ំ ទាក់ទងទៅនឹងបន្ទប់ដែលឃុំលោកអ៊ំ ។ លោកអ៊ំបានជម្រាបថា វារាងបានជម្រាបលោកប្រធានរួចហើយ ក៏ប៉ុន្តែខ្ញុំនៅឆ្ងល់ថា តើលោកអ៊ំបានឃើញនៅបន្ទប់ហ្នឹងឡើងវិញដែរឬទេ ថាវានៅទីណា ឬក៏លោកអ៊ំអាចចាំបានឲ្យលម្អិតជាងនេះបន្តិចបានទេ បន្ទប់ហ្នឹងរាងយ៉ាងម៉េច? នៅក្នុងអគារយ៉ាងម៉េច? ហើយស្ថានភាពនៃការរស់នៅក្នុងបន្ទប់ហ្នឹង គឺលោកអ៊ំអាចស្គាល់តាមការសម្រាកហ្នឹង លោកអ៊ំអាចដឹងថាយ៉ាងម៉េច វាហាប់ ឬក៏វាមានអាកាសធាតុយ៉ាងម៉េច?

**ឆ៖** សូមជម្រាបលោកមេធាវី! នៅកន្លែងបន្ទប់ដែល បន្ទប់ដែលខ្ញុំបាទជាប់ឃុំឃាំងហ្នឹង គឺបើខ្ញុំដឹងបានត្រង់ថា រាងរបៀបដូចក្រចកសេះ នៅពេលបច្ចុប្បន្ន គឺថាក្រចកសេះចុះ ព្រោះវាដូចថា វាមូលហើយក៏វាវង់ រាងវង់នៅលើក្បាលខ្ញុំបាទ ដូចខ្ញុំជម្រាបជូនខាងដើម នៅពេលដែលខ្ញុំបាទងើបឈរទៅបានវាប៉ះ នៅពេលដែលខ្ញុំអង្គុយនោះ វាមិនប៉ះទេ ប៉ុន្តែវាគ្រាន់តែបន្ទប់ដែលគេឃាំងខ្ញុំពីក្រោយហ្នឹង វាបាត់លំនាំ វាដូចថា វានៅលំនាំដើមដែរ ។ នេះសូមជម្រាបនៅពេលខ្ញុំបាទបានឃើញ ហើយបានដឹងហើយវាជាកន្លែងមួយហាប់ ហើយនៅជញ្ជាំងក្រោយខ្នងខ្ញុំហ្នឹង គឺជាក្ដារដែលវាផុតក្បាលខ្ញុំ ដែលខ្ញុំមិនអាចមើលអ្វីឃើញតទៅទៀតបាន ក្រៅអំពីបរិវេណដែលខ្ញុំបាទជាប់នៅកន្លែងនោះ ។ នេះសូមអស់ប្រសាសន៍ ជម្រាបប្រសាសន៍ជូន ។

**ស៖** បន្តទៅទៀត ចុះនៅខាងៗបន្ទប់ ឬក៏ដូចលោកអ៊ំថា ចូលពីទ្វារទៅនៅខាងឆ្វេង ឬក៏ស្ដាំនៃបន្ទប់ហ្នឹង វាមាន-- យើងអាចដឹងថា មានអ្វីនៅជាប់ហ្នឹងដែរឬទេ? ឬក៏ដាច់តែឯងបន្ទប់ហ្នឹង?

**ឆ៖** បើខ្ញុំមិនច្បាស់ទេនោះ ប្រហែលជាខ្ញុំភ្លាប់បានថា នៅពេលដែលខ្ញុំឡើងដល់ ពេលដែលគេបណ្ដើរខ្ញុំថ្ងៃទីមួយទៅដល់នោះ គឺគេឲ្យខ្ញុំងាកឆ្វេង គឺទាញខ្ញុំខាងឆ្វេងអ៊ីចឹងទៅ ។ រួចហើយគេឲ្យខ្ញុំត្រង់បានបួនដប់ជំហ៊ាន គេរុញចូលមក ហើយនៅខាងស្ដាំដៃខ្ញុំនោះ ខ្ញុំហាក់បីដូចជាមិនបានឃើញថា ហេតុការណ៍ជារបស់ ឬក៏ជាអីៗ ក៏ខ្ញុំមិនដឹងដែរ ។ ក៏ប៉ុន្តែគ្រាន់តែឮសំឡេងនៅខាងស្ដាំដៃខ្ញុំ ខាងឆ្វេងខ្ញុំនោះ គឺមានឮសូរសំឡេងមនុស្សស្រែក ហើយនិងថ្ងូរជាច្រើនប៉ុណ្ណឹង ដែលខ្ញុំឮបាន ។

**ស៖** តើសំឡេងថ្ងូរហ្នឹង ជាញឹកញាប់ទេ ហើយឮសូរជាស្រែករបៀបម៉េច ដោយសារការធ្វើទារុណកម្ម ឬក៏ស្រែកនិយាយគ្នា ឬក៏ជេរគ្នា ឬក៏សំឡេងយ៉ាងម៉េច?

**ផ៖** ជម្រាបជូនលោកមេធាវីថា នៅពេលដែលខ្ញុំស្ដាប់ឮនោះ គឺឮសូរតែសម្រែក សម្រែកថាស៊ុំទឹក ហើយនិងជុះអាចម៍ នោម ហើយនិងស្រែក ហើយនិងឮសូរសំឡេងសម្រែកគំរាមរបស់អ្នកណាក៏ខ្ញុំមិនដឹងដែរ ឮសូរសំឡេងស្រែកគំរាមរបស់ "អាចម៍នោមៗ!មួយយប់ទៅហើយ" ខ្ញុំឮសំឡេងតែប៉ុណ្ណឹង អាហ្នឹងជម្រាបប្រសាសន៍លោកមេធាវី ។

**ស៖** សូមអរគុណ ។ ជាបន្តទៅទៀត ខ្ញុំសួរលោកពាក់ព័ន្ធទៅនឹង លោកថា អះអាងថា មានការដាក់ខ្នោះជើង តើលោកមានស្លាកស្នាម ឬក៏អ្វីសម្គាល់អំពីការជាប់ខ្នោះទេ នៅបច្ចុប្បន្ននេះ?

**ផ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅពេលបច្ចុប្បន្ននេះ យើងខ្ញុំនឹងបង្ហាញជូននៅអាជើងដែលខ្ញុំសម្គាកជាងសាមសិបឆ្នាំមកនេះ គឺខ្ញុំសម្គាកនៅមាន ជើងខាងឆ្វេង ហើយនិងខាងស្ដាំឃើញស្នាមតិចៗ ដោយរយៈពេលវាយូរដែរហើយ ។ សូមជម្រាបជូនលោកមេធាវីខ្លី ។

[១០:៥៩:០៨]

**ស៖** សូមអរគុណ ។ ខ្ញុំមានសំណួរបន្តទៀត សួរទៅកាន់លោកអ៊ំដែរ គឺថាពាក់ព័ន្ធទៅនឹងរបួសស្នាមហ្នឹង គឺជារឿងមួយ មួយទៀត គឺទាក់ទងទៅនឹងផ្លូវចិត្តរបស់លោកអ៊ំ ដែលលោកអ៊ំតែងតែនិយាយថាខ្លាច មានអារម្មណ៍ថាខ្លាចអង្គការ តើអារម្មណ៍បែបហ្នឹង គឺនៅតែមាន ឬក៏វាផុតរលត់ចាប់តាំងពីថ្ងៃដែលអង្គការហ្នឹងបានរំលាយទៅហើយ ឬក៏យ៉ាងម៉េច?

**ផ៖** សូមជម្រាបលោកមេធាវី! ការភ័យខ្លាចរបស់យើងខ្ញុំផ្ទាល់ ចាប់តាំងពី មិត្តអ៊ាម គាត់បានអប់រំខ្ញុំ នៅពេលដែលខ្ញុំទៅដល់អង្គភាពនៅវត្តសំរោង ដែលគេហៅថា វ៉ាសំរោង នោះ គាត់បានគំរាមខ្ញុំថាក្បាលអ្នកណា គឺសក់អ្នកនោះ គឺមិនបានឲ្យអ្នកឯងនិយាយតាមតែចិត្តរបស់អ្នកឯងទេ ព្រោះអ្នកឯងមកនេះ ក្នុងនាមតែអ្នកឯងមក មកលត់ដំ ហើយនិងកសាងខ្លួននៅកន្លែងនេះ ។ នៅពេលនោះឯងដែលខ្ញុំហៅថាផ្លូវចិត្តរបស់ខ្ញុំ គឺខ្ញុំចងជាប់រហូត សូម្បីតែកូនខ្ញុំនៅពេលបច្ចុប្បន្ននេះ ក៏ខ្ញុំពុំដែលនិយាយ រឿងរ៉ាវដែលពាក់ព័ន្ធជាមួយនិងផ្លូវចិត្តខ្ញុំឲ្យកូន ឬក៏ឲ្យអ្នកណាម្នាក់ដែលគេពុំបានធ្លាប់ជាប់ ហើយក៏មិនបាននិយាយរឿងរ៉ាវអ្វីដែលធ្វើឲ្យវាមានការពាក់ព័ន្ធ ដែលជាខ្លួនរបស់ខ្លួន ឬក៏អ្នកផ្សេងទៀត ដែលគេមិនបានរួមជាមួយ គឺខ្ញុំពុំដែលបាននិយាយទេ ។ ដូច្នេះហើយ ជាកម្លាំង ហើយជាគំនិត ជាផ្លូវចិត្តរបស់ខ្ញុំ គឺខ្ញុំរក្សាផ្ដុំទុក រហូតនៅពេលដែលខ្ញុំមានបញ្ហារំឭករឿងនេះម្ដងៗមក គឺថាចិត្តរបស់ខ្ញុំដូចថា វាគាំង

ហើយវាមិនអាចនឹងនិយាយទៅឲ្យអ្នកផ្សេងទៀតបាន ដូចថាគេ មកដូចថាវាមើលទៅគេឃើញតែការគំរាមថា ក្បាលអ្នកណាសក់អ្នកនោះ ហើយជាសកម្មភាព ជាផ្លូវចិត្តរបស់ខ្ញុំ គឺមានប៉ុណ្ណេះ ។ ហើយចំពោះនៅពេលបច្ចុប្បន្ន ក៏ដូចជាពីមុនមក បញ្ហារបួសខាងផ្លូវកាយ គឺត្រចៀកយើងខ្ញុំខាងឆ្វេង ចាប់តាំងពីពេលនោះមក គឺត្រចៀករបស់ខ្ញុំ គឺហូររហូត ហើយកន្លែងខ្លះក៏វាខាស់ ហើយកន្លែងខ្លះក៏វាហូរ តែនៅទីចុងបញ្ចប់ គឺត្រចៀករបស់ខ្ញុំនៅតែហឹងតែខាងឆ្វេងមួយចំហៀង ។ ហើយនៅពេលដែលហឹង ខ្ញុំត្បាល់មក គឺមានឈាម ហើយនិងខ្ទុះជាប្រចាំ ។ នេះគឺខ្ញុំបាទ សូមជម្រាបលោកមេធាវីខាងផ្លូវចិត្ត ហើយនិងផ្លូវកាយ ។

**លោក គឹម ម៉េងឃី៖**

សូមអរគុណលោកអ៊ំ! ខ្ញុំមិនមានសំណួរអ្វីសួរទៅកាន់លោកអ៊ំទេ ក៏ប៉ុន្តែសហមេធាវីអន្តរជាតិលោកស្រី ម៉ាទីន នឹងមានសំណួរសួរទៅកាន់លោកអ៊ំបន្តពីខ្ញុំបាទ ។ សូមអរគុណ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** សូមគោរពលោកប្រធាន លោក លោស្រីចៅក្រមជាទីគោរព! អរុណសួស្តីលោក ឡាយចាន់ ខ្ញុំសូមឲ្យលោកជម្រាបជូនអង្គសវនាការអំពីការកើតឡើងនៅពេលដែលលោកបានចូលទៅដល់មន្ទីរឃុំឃាំងនៅក្នុងបន្ទប់មួយ ដែលលោកទំនងនឹងត្រូវគេថតរូប ហើយលោកបានពិភាក្សាជាមួយនឹងអ្នកយាមនោះ ។ សូមឲ្យលោកលើកឡើងអំពីបញ្ហានេះ?

**ឆ៖** សូមជម្រាបលោកស្រីមេធាវី! នៅពេលដែលយើងខ្ញុំចូលដល់កន្លែងឃុំឃាំង ឃុំខ្លួននោះ គឺខ្ញុំបាទពុំបានគេស្រាយមុខ ហើយគេស្រាយដៃ ស្រាយចំណងអ្វីទាំងអស់ ហើយគេថតរូប ថតអី ក៏ខ្ញុំមិនដឹងដែរ ។ នៅពេលនោះ គឺសូម្បីតែការសួរចម្លើយរបស់ខ្ញុំ ក៏គេពុំទាន់មានសួរប្រវត្តិ អ្នែងកើតនៅណា អ្នែងឈ្មោះអ្វី ឈ្មោះអី? ក៏គេពុំដែលបានមានទំនាក់ទំនង គ្រាន់តែគេសួរសង្កត់ថា អ្នែងដើរតាម អាយើន ហើយនិង អាលឿន គេមាននិយាយអី គេមានបង្កប់រឿងអី អាថ៌កំបាំងអី ដែលគួរអ្នែងដឹងបានទេ ខ្ញុំឆ្លើយថា ខ្ញុំអត់ដឹង មានតែប៉ុណ្ណឹងដែលខ្ញុំឆ្លើយប្រាប់គេ ។

**ស៖** ប៉ុន្តែតើលោកអាចជម្រាបយើងបានដែរឬទេ ថាតើមានអ្វីដែលគេប្រាប់លោកនៅពេលដែលលោកទៅដល់ ដោយសារតែលោកអត់បានមិនអាចមើលឃើញទេ ប៉ុន្តែលោកអាចស្តាប់បាន ។ អ៊ីចឹងថាតើអ្នកយាមគេប្រាប់លោកយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបប្រាប់អ្នកស្រីមេធាវី! នៅពេលដែលគេនិយាយ ហើយអ្នកយាម ក៏ខ្ញុំឮអ្នកយាមគេនិយាយដែរ គេថាបើពិបាកចិត្តជាងគេ គឺអ្នកថតរូបដែលវាអាចនឹងធូរស្រាលបាន ប៉ុន្តែ បើអ្នកអត់ថតរូប យើងកម្មរហូត កម្មយាមមើលវាហ្នឹង គេគ្រាន់តែខ្ញុំស្តាប់បានតែប៉ុណ្ណោះ ។ ដូច្នេះ អារម្មណ៍របស់ខ្ញុំនៅពេល នោះ ខ្ញុំគិតរិតតែភ័យទៅទៀតហើយ ។ មិនដឹងថា គេថតរូបខ្ញុំហើយ ឬមួយយ៉ាងម៉េច ក៏ខ្ញុំអត់ដឹង ។ នេះសូមជម្រាបលោកស្រីដោយខ្លី ។

**ស៖** នៅពេលដែលលោកទៅធ្វើការនៅពេលយប់ លោកត្រូវបានគេចងមុខ ហើយលោកដើរប្រហែលជា១៥នាទី ហើយនៅពេលដែលលោកកំពុងតែដើរនោះ គឺលោកត្រូវបានគេដោះរបាំងមុខហ្នឹងចេញនៅពេលដែលលោកធ្វើការក្នុងទីងងឹតនោះ?

**ឆ៖** ជម្រាបប្រសាសន៍! ដូចអ្នកស្រីមានប្រសាសន៍អ៊ីចឹង នៅពេលដែលគេឲ្យខ្ញុំធ្វើការ ទៅដល់កន្លែងធ្វើការបានគេស្រាយមុខ ហើយស្រាយមុខនោះ ក៏អត់មានស្រាយនៅពេលកន្លែងភ្លឺដែរ គឺគេស្រាយនៅកន្លែងងងឹត នេះខ្ញុំសូមជម្រាបអ្នកស្រីដោយខ្លីហ្នឹង ។

**ស៖** ថាតើនៅនឹងកន្លែងនុំងហ្នឹង មានការដុតបំភ្លឺអីដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍អ្នកស្រី! នៅពេលនោះ ហាក់បីដូចជាខ្ញុំដឹងថា ប្រហែលជាមានភ្លើងហ្វា តែភ្លើងនោះមិនដឹងចេញពីប្រភពណាមកទេ ។ ហ្វា កន្លែងខ្ញុំធ្វើការហ្នឹង ។

**ស៖** លោកនិយាយអំពីរណ្តៅដែលលោកជីក តើលោកអាចនិយាយអំពីជម្រៅ និងប្រវែងនៃរណ្តៅទាំងអស់នេះដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍អ្នកស្រីមេធាវី! បញ្ហារណ្តៅមានទំហំ ហើយនិងជម្រៅ ខ្ញុំសូមជម្រាបថា មានកន្លែងខ្លះ គេឲ្យកាប់៦តឹក ជម្រៅ៤តឹក ឬក៏កន្លះម៉ែត្រ ហើយកន្លែងខ្លះទៀត មានរណ្តៅធំដល់ទៅមួយម៉ែត្រ ហើយជម្រៅ ក៏ប្រហាក់ប្រហែលគ្នាដែរ ។ សូមជម្រាបអ្នកស្រីតែប៉ុណ្ណោះ ។

**ស៖** ហើយគេតាមដាន និងពិនិត្យលោក នៅពេលដែលលោកកំពុងធ្វើការនោះ តើមានអ្នកយាមហ្នឹងតាមមើលលោកហ្នឹងប៉ុន្មាននាក់ ។

**ឆ៖** សូមជម្រាបប្រសាសន៍អ្នកស្រីមេធាវី! ចំពោះបញ្ហាអ្នកយាម ខ្ញុំបាន មិនបានចាំច្បាស់ទេ មិនដឹងជាប៉ុន្មាននាក់ ក៏ប៉ុន្តែនៅពេលដែលខ្ញុំលួចមើលនៅជុំវិញខ្លួនខ្ញុំ នៅគ្រប់ជ្រុងទាំងអស់ ។ នេះខ្ញុំសូមជម្រាប ។

[១១:០៨:៥៦]

**ស៖** ប្រសិនបើយើងនិយាយអំពីស្ថានភាពឃុំខ្លួនលោកវិញ នៅពេលដែលលោកចង់ផឹកទឹក តើគេឲ្យទឹកលោកផឹកដែរឬទេ?

**ផ៖** សូមជម្រាបប្រសាសន៍អ្នកស្រី! នៅពេលដែល បើសិនណាតែខ្ញុំស្រេកទឹក ក៏ខ្ញុំពុំហ៊ានសុំគេទេ ។

**ស៖** លោកនិយាយមុនហ្នឹងថា លោកត្រូវការយកប្រអប់ដែលបត់ដៃ បត់ជើងហ្នឹង ក្នុងការយកទៅចាក់ចោលខ្លួនឯង ហើយគឺលោកធ្វើការបត់ដៃ បត់ជើងនៅក្នុងប្រអប់ហ្នឹង តើលោកអាចរៀបរាប់អំពីស្ថានភាពនៃការដែលលោកធ្វើការងារយកទៅចាក់ចោលដោយខ្លួនឯងនេះដែរឬទេ?

**ផ៖** សូមជម្រាបប្រសាសន៍អ្នកស្រី! នៅពេលដែលគេឲ្យខ្ញុំបាទយកលាមកខ្លួនឯងនិងទឹកនោមខ្លួនឯងយកទៅចាក់នោះ ក៏គេពុំបានបើកមុខខ្ញុំបាទឲ្យដឹងថាចេញពីកន្លែងទារុណ ឲ្យធ្វើកន្លែងដែលខ្ញុំឃុំឃាំងនោះ ឲ្យខ្ញុំឃើញ ហើយមើលឃើញថាខាងឆ្វេង ឬខាងស្តាំ ខ្ញុំនុ៎ងមានអី មានអីនោះ ក៏គេអត់បាននេះទេ គេអត់បានបើកខ្ញុំឃើញទេ ។ ពេលនោះ គឺគេឲ្យខ្ញុំកាន់ខ្ទេះមួយចំហៀង ហើយនិងកាន់លាមកធុងហ្នឹងមួយចំហៀង គឺគេចងមុខខ្ញុំ តែគេបណ្តើរខ្ញុំរហូត គេទៅចាប់ដៃខ្ញុំបណ្តើរដឹកអូសផង បណ្តើរផងទៅឆ្ងាយ បើខ្ញុំប៉ាន់ស្មានមើលទៅប្រហែលជាមួយរយជំហាន ទៅពីររយជំហាននោះ អានេះតាមដំណើរ របស់ខ្ញុំដើរខ្ចី ខ្ចីដែលវាមានបញ្ហាឈឺចាប់ និងបញ្ហាដំបៅក្នុងជើងហ្នឹង ។ សូមជម្រាបលោកស្រី ។

**ស៖** ចំណុចចុងក្រោយ តើលោកអាចជម្រាបបញ្ជាក់យើងខ្ញុំដែរឬទេ ថាតើលោកមានទម្ងន់ប៉ុន្មាននៅពេលដែលលោកទៅដល់មន្ទីរឃុំឃាំងហ្នឹង? ហើយលោកមានទម្ងន់ប៉ុន្មានក្រោយពីចេញពីមន្ទីរឃុំឃាំងនោះ?

**ផ៖** សូមជម្រាបមេធាវី! នៅពេលដែលខ្ញុំ មុនពេលដែលខ្ញុំជាប់ឃុំឃាំងនៅកន្លែងនោះ គឺខ្ញុំមានទម្ងន់សែសិបពីរគីឡូ ទៅសែសិបប្រាំគីឡូ ធំហើយសែសិបប្រាំគីឡូ ហើយនៅពេលដែលខ្ញុំបាទជាប់មន្ទីរឃុំឃាំងនោះ គឺខ្ញុំបាទ ស្មានមិនត្រូវទេ បើខ្ញុំដឹងតែកម្លាំងរបស់ខ្ញុំប្រហែលជាសាមសិបប្រាំគីឡូ ឬក្រោមសាមសិបប្រាំគីឡូ ។

**ស៖** ហើយចំពោះត្រចៀករបស់លោក ដែលគេវ៉ៃលោក តើលោកមានបញ្ហានៅ មានបញ្ហាចំពោះត្រចៀករបស់លោកដែរឬទេ ឬក៏ត្រចៀកហ្នឹងវាជាហើយ?

**ឆ៖** សូមជម្រាបប្រសាសន៍អ្នកស្រីមេធាវី! បញ្ហាត្រចៀករបស់ខ្ញុំបាទនេះ វាមិនជាទេ គ្រាន់នៅពេលបច្ចុប្បន្ន នៅពេលនេះ ដែលអង្គុយនិយាយនេះ គឺកាសឮបានតែមួយចំហៀងខាងស្តាំទេ តែចំហៀងខាងឆ្វេង គឺឮតែខ្យល់ទេ អត់ដឹងសំឡេងថាម៉េចផង ។ សូមជម្រាបប្រសាសន៍អ្នកស្រី ។

[១១:១៣:២៣]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោក ឡាយ ចាន់ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមនៅពេលនេះខ្ញុំសូមផ្តល់វេទិកានេះជូនមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ ។

**សួរដោយលោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបាទសូមគោរពអង្គជំនុំជម្រះ ។ ខ្ញុំបាទមានសំណួរមួយចំនួនដែលជាសំណួរដើម្បីសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បន្ថែមបន្តិច បាទ ។

**ស៖** ចំណុចទីមួយខ្ញុំចង់សូម សួរលោកថា នៅពេលដែលលោកមកដល់មន្ទីរឃុំឃាំងបានពីរថ្ងៃបានលោកត្រូវបានគេសួរចម្លើយ អ៊ីចឹងនៅយប់ទីមួយនោះ លោកមានបានអាហារទទួលទានទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅយប់ទីមួយ គឺយើងខ្ញុំបាទ ពុំបានម្ហូបអាហារហូបទេនៅទីមួយ ។

**ស៖** អ៊ីចឹង គេឃុំលោកបានប៉ុន្មានថ្ងៃ បានគេផ្តល់អាហារឲ្យលោកហូប?

**ឆ៖** គឺថ្ងៃទីពីរ នៅពេលល្ងាចទើបឃើញគេយកបបរវាទៅឲ្យមួយចានចង្កឹះ ហើយក៏ល្ងាចនោះ ក៏គេយកខ្ញុំទៅសួរចម្លើយជាលើកទីមួយ ។ សូមជម្រាបប្រសាសន៍ ។

**ស៖** បាទៗ សូមអរគុណ ហើយខ្ញុំសូមតាំងសំណួរបន្តទៅទៀត លោកបានបញ្ជាក់ជូនអង្គជំនុំជម្រះហើយថា លោកធ្លាប់បានទទួលបបរចំនួនមួយកា ក្រោយមកលោកបានបញ្ជាក់ជូនថា មួយកានោះ គឺថាបានតែកន្លះកា វិញទេ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមឲ្យច្បាស់ទៀតថា តើ កានោះជា កានោះទំហំប៉ុនណា ហើយកានោះជាធ្វើអំពីអ្វី ដើម្បីឲ្យច្បាស់ថា កានោះទំហំប៉ុនណា?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! បញ្ហាកានោះបើខ្ញុំស្គាល់មិនច្បាស់ទេ ប្រហែលជាខ្ញុំស្តាប់មិនបាន ហើយស្គាល់បានថា កានោះ កាពីដុងទឹករបស់អាមេរិកកាំង ។ ដូច្នេះ គឺនៅក្រោម វ័ណ្ឌ

វ័ណ្ឌអាកន្ទះ កាហ្នឹង វ័ណ្ឌក្រចាប់វាហ្នឹង គឺត្រឹមនោះមកក្រោម-- ពេលដែលគេយកទៅឲ្យខ្ញុំអាបបរវាហ្នឹង ។ សូមជម្រាបប្រសាសន៍លោកមេធាវី ។

[១១:១៦:៣៦]

**ស៖** សូមអរគុណ អ៊ីចឹងបើសិនណាជាយើងចាក់ចេញមក សួរថាតើបបរនោះបានប្រហែលមួយចានចង្កឹះទេ?

**ឆ៖** បើយើងចាក់មកខាងក្រៅ បានប្រហែលជាមួយចានចង្កឹះ ស្មើមាត់មួយចានចង្កឹះ ។ សូមជម្រាបលោកមេធាវី ។

**ស៖** សូមអរគុណ ខ្ញុំចង់សួរសំណួរបន្ថែមតទៅទៀត សួរថា ខ្ញុំដឹងហើយថា រស់ជាតិអាហារនោះយ៉ាងម៉េចហើយ ប៉ុន្តែ ខ្ញុំចង់ដឹងពីលោកវិញ សួរថា តើរស់ជាតិអាហារដែលលោកទទួលទាននោះដែលលោកបានបញ្ជាក់ថា មានសម្លអីខ្លះនោះ សួរថាតើរស់ជាតិហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! រស់ជាតិនៃបបរនោះ ខ្ញុំពិបាកនឹងថ្លឹងថ្លែង ហើយនិងពិបាកនឹងបរិយាយណាស់ ដូចពិបាក ខ្ញុំថានិយាយទៅថា ពិបាកនឹងគណនាឲ្យបានថា វាមានប្រភេទវា ឆ្ងាញ់ ឬក៏វាមិនឆ្ងាញ់ ក៏ខ្ញុំបាទអត់ៗបានិយាយដែរ ព្រោះរឿងដែលខ្ញុំនិយាយនេះ គឺនិយាយរឿងពិតគឺបបរនោះបើយើងនិយាយទៅថា វាហាក់ឡាំដូចទៅនឹងបបរដែលគេយកទៅឲ្យសត្វអ៊ីចឹង ។

**ស៖** សូមអរគុណ លោកបានបញ្ជាក់ជូនខាងដើមហើយថា ពេលដែលលោកត្រូវការទឹកទទួលទាន លោកមិនបានសុំគេផឹកទេ អ៊ីចឹងលោកនៅតែអត់ទ្រាំទាំងថ្ងៃទាំងយប់ទៀត ឬមួយយ៉ាងម៉េច ឬមួយក៏ដល់ពេលណាដែលគេយកឲ្យលោកហូប បានៗលោកបានទទួលទាន?

**ឆ៖** សូមជម្រាបលោកមេធាវី! នៅចំណុចនេះ គឺខ្ញុំពុំអាចនឹងឆ្លើយតបបានទេ ពេលដែលខ្ញុំស្រេកទឹក ពេលដែលខ្ញុំឈឺនោម *(សាក្សីយំខ្សឹកខ្សួល)* ។

**ប្រធានអង្គជំនុំ៖**

លោក ចាន់ ខន (ឡាយ ចាន់) លោកធ្វើអារម្មណ៍ឲ្យបានល្អ ពង្រឹងសតិអារម្មណ៍ឲ្យបានល្អឡើងវិញ ហើយ លោកត្រូវការសម្រាកដែរឬទេ ឥឡូវនេះ ឬក៏លោកអាចឆ្លើយនឹងសំណួរបន្តទៀត?

[១១:២០:០០]

**ឆ៖** ជម្រាបលោកមេធាវី! នៅពេលដែលខ្ញុំបាទស្រេកទឹក ដែលខ្ញុំបាទពុំបានសុំគេនោះ នៅពេលនោះដែលខ្ញុំបាទឈឺនោម គឺខ្ញុំបាទនោម ទឹកនោមរបស់ខ្ញុំទោះបីបានតិចក៏ដោយ ច្រើនក៏ដោយ ខ្ញុំ

យកទឹកនោមខ្លួនឯងមកហូប សូមជម្រាបប្រសាសន៍លោកមេធាវី ។

**ស៖** សូមអរគុណ ហើយខ្ញុំសូមអភ័យទោសដោយសារសួរសំណួរនេះធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់លោក ហើយបើសិនណាជាលោកអាចបន្តទៀតបាន គឺខ្ញុំសូមសួរបន្តទៀត ដោយទាក់ទងទៅនឹងបញ្ហាបន្ទប់នៃការឃុំឃាំង ។ នៅក្នុងបន្ទប់ឃុំឃាំងលោកបានលើកពីទំហំនៃការបន្ទប់នោះហើយៗ ។ អ៊ីចឹងនៅពេលដែលលោកដល់-- ចូលដល់ក្នុងបន្ទប់នោះតើក្លិននៅក្នុងបន្ទប់នោះយ៉ាងម៉េចដែរ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបលោកមេធាវី! នៅបន្ទប់ដែលខ្ញុំបាទជាប់ឃុំឃាំងនោះ នៅពេលដែលខ្ញុំបាទចូលទៅដល់ គឺមានក្លិនស្អុយ ឆ្អាប ហើយនិងឆ្អេះ សូមជម្រាបលោកមេធាវី ។

**ស៖** សូមអរគុណ ។ ចុះនៅពេលយប់មានពន្លឺភ្លើងទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅកន្លែងខ្ញុំបាទនោះមិនមានទេ ។ សូមជម្រាបប្រសាសន៍លោកមេធាវី បើនៅខាងក្រៅៗទៀតខ្ញុំអត់ដឹង ។

**ស៖** សូមអរគុណ ថាពេលយប់អត់មានពន្លឺភ្លើងទេ ចុះនៅពេលថ្ងៃ មានពន្លឺថ្ងៃចាំងចូលបានទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅពេលថ្ងៃគឺមានពន្លឺថ្ងៃដែរ ក៏ប៉ុន្តែពន្លឺនោះហាក់បីដូចជាស្ទើរអត់ ស្ទើរមានអ៊ីចឹង ព្រោះព្រឹល ដែលវាអាចចោលរន្ធះភ្លើងព្រឹល ទៅតាមពន្លឺថ្ងៃដែលពន្លឺថ្ងៃចូលបានតែ-- ឲ្យចេញពន្លឺជាពន្លឺរង្វង់ ឬក៏ជាចំហាយថ្ងៃក្ដៅអីចូលអ៊ីចឹងគឺមិនមានទេ កន្លែងនោះហប់រហូតគ្រាន់តែមានពន្លឺភ្លឺអាចយើងមើលឃើញព្រឹលៗ ។ បើនិយាយអំពីស្ថានភាព យើងថា មេឃសន្លប់ចុះ យើងអាចមើលអញ្ចាញដៃឃើញបានបន្តិចៗបាន សូមជម្រាបប្រសាសន៍លោកមេធាវី បើឲ្យភ្លឺឲ្យច្បាស់ដូចអ៊ីចេះគឺមិនមានទេ ។

[១១:២៣:៣៣]

**ស៖** សូមអរគុណ ។ សូមលោកបញ្ជាក់ឲ្យច្បាស់មើល ថាតើមេឃសន្លប់ហ្នឹងយ៉ាងម៉េច ចង់និយាយពីមេឃសន្លប់នោះ ដើម្បីឲ្យបកប្រែឲ្យបានច្បាស់ ?

**ឆ៖** គឺពន្លឺអត់គ្រប់គ្រាន់ យើងមិនអាចមើលទៅ-- ឧទាហរណ៍មើលអក្សរអីអត់ច្បាស់ទេ បើថាមើលអញ្ចាញដៃយើងអាចមើលឃើញបាន គ្រាន់តែពន្លឺប៉ុណ្ណឹងបាន បើថាឲ្យយើងមានអក្សរមើលអី

មើល មើលអត់ឃើញទេ សូមជម្រាបប្រសាសន៍ ។

**ស៖** សូមអរគុណ ហើយខ្ញុំសូមបន្តសំណួរមួយសំណួរទៀតថា នៅពេលដែលលោកត្រូវបានគេសួរចម្លើយ លោកបានជម្រាបជូនអង្គជំនុំជម្រះហើយថា អត់បានដោះនិងស្រាយមុខចេញទេ សួរថាតើការដែលខ្ញុំស្តាប់ហ្នឹងត្រឹមត្រូវទេ?

**ឆ៖** គឺពិតប្រាកដ ។

**លោក គង់ ពិសី៖**

ខ្ញុំសូមអរគុណលោកប្រធាន ហើយលោកសហភាតាខ្ញុំមានសំណួរតទៀតបាទ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកហុង គឹមសួន នៅសល់បួនមីនុតទៀត ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទមានសំណួរតែបីសំណួរទេ ។ ដំបូងខ្ញុំបាទសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព ។

**ស៖** លោកឡាយ ចាន់ សំណួររបស់ខ្ញុំសួរថា តើចម្លើយដែលលោកឆ្លើយជាមួយលោកចៅក្រមអម្បាញ់មិញថា បានស្គាល់ភ្នំពេញខ្លះដែរ មានន័យថា លោកស្គាល់ភ្នំពេញមុនឆ្នាំ-- មុនថ្ងៃ១៧ មេសា ១៩៧៥ ឬក្រោយថ្ងៃ ១៧ មេសា ១៩៧៥?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី ខ្ញុំបាទស្គាល់ទីក្រុងភ្នំពេញនេះទើបតែនឹងស្គាល់នៅឆ្នាំ១៩៧៥ ដែលខ្ញុំបាទមករស់នៅ ចេញពីអង្គភាពមករស់នៅទីក្រុងភ្នំពេញក្រោយដាច់ភ្នំពេញហើយ ១៩៧៥ ។ សូមជម្រាប ។

**ស៖** សូមសួរបន្តទៀត ព្រោះពេលវេលាខ្លីពេក តើក្រោយថ្ងៃ៧ មករា ១៩៧៩ មានន័យថា ក្រោយពេលដែលខ្មែរក្រហមត្រូវដួលរលំទៅនោះ លោកធ្លាប់បានចូលទៅរកមើលទីតាំងដែលគេឃុំខ្លួនលោកនៅក្នុងបរិវេណនៃគុកទួលស្លែងឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបាទ ចាប់ពីឆ្នាំ១៩៧៩ មកដល់ឆ្នាំ២០០៧ ខ្ញុំបាទបានមកមើលសារមន្ទីរទួលស្លែងតែម្តងគត់ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរទាក់ទងជាមួយនឹង ការជាប់ឃុំក្នុងរយៈពេលប្រហែលជាបីខែរបស់លោកនោះ តើគេប្រើធ្វើការខុសពីការទៅជីករណ្តៅនោះឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ក្នុងការ ក្រៅពីការជីករណ្ដៅ នៅពេលខ្លះ បើខ្ញុំមិនភ្លេចទេនោះ ប្រមាណជាពីរដងដែរ ដែលគេឲ្យខ្ញុំទៅធ្វើខាងក្រៅ ក៏នៅនឹងក្នុងបរិវេណនោះដែរ ក៏ប៉ុន្តែខ្ញុំមិនដឹងជាកន្លែងណា ទៅកន្លែងណាទេ ទាល់ពេលដែលគេបណ្ដើរខ្ញុំចេញទៅធ្វើ ទៅរៀបនោះ គឺគេឲ្យទៅរៀបចំផ្ទះមួយ ថ្ងៃទីមួយគឺឲ្យរៀបផ្ទះមួយដែរ ។ ខ្ញុំបាទចាំមិនបាន ហើយខ្ញុំបាទសម្លឹងមើលមិនឃើញទេ ព្រោះនៅពេលនោះ-- ពេលយប់នោះ ខ្ញុំមិនដឹងខាងណាងខាងកើត មិនដឹងខាងណាខាងលិច មិនដឹងខាងណាខាងជើង ខាងត្បូងទេ សូមជម្រាបប្រសាសន៍ ។

**ស៖** អរគុណ ។ ជាសំណួរចុងក្រោយ ខ្ញុំសួរលោកថា ពេលដែលលោកធ្វើការងារពេលយប់នោះ លោកមើលមិនឃើញសោះ ឬមើលឃើញជាស្រមោលៗនៃអគារខ្ពស់ដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍! នៅពេលដែលខ្ញុំបាទចេញទៅរៀបនោះ គឺខ្ញុំបាទហាក់បីដូចជាខ្ញុំលួចសម្លឹងទៅលើអគារមិនហួសពីពីរជាន់ទេ សូមជម្រាបប្រសាសន៍លោកមេធាវីដោយខ្លីប៉ុណ្ណេះ ។

**ស៖** សូមលោកឆ្លើយខ្លីៗថា មកដល់ដែលពេលលោកបានទៅឃើញទួលស្លែង និងការដែលលោកមើលឃើញប្រហាក់ប្រហែលនោះ តើមានអារម្មណ៍ថាដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នាឬទេ?

សូមអរគុណលោកប្រធាន សំណួរត្រឹមនេះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ដល់ខាងភាគីការពារក្ដី ។ ហើយមុននឹងជូនវេទិកាទៅមេធាវីការពារក្ដី អង្គជំនុំជម្រះប្រគល់នាទីទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លី អំពីការ--

[១១:២៩:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីជាប្រតិចារឹកនិងដើម្បីជាព័ត៌មានសម្រាប់អង្គសវនាការ យើងមិនបានឮការឆ្លើយតបពីដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណួរដែលបានតាំងដោយលោកហុង គឹមសួន ទាក់ទងសំណួរចុងក្រោយ ដូច្នេះហើយ តើដើមបណ្ដឹងរដ្ឋប្បវេណីសូមឲ្យឆ្លើយឡើងវិញ ទៅនឹងសំណួរចុងក្រោយដែលបានសួរដោយលោក ហុង គឹមសួន នោះ ។

**លោក ឡាយ ចាន់៖**

សូមប្រសាសន៍លោក សំណួរលោកមេធាវីម្ដងទៀត ព្រោះខ្ញុំភ្លេច ។

**លោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកចៅក្រម ហើយក៏សូមសួរម្តងទៀតថា កន្លែងដែលលោកថាមើលឃើញជាព្រាល១ដូចអគារពីរជាន់ ជាមួយនឹងលោកទៅដល់គុកទួលស្លែងនៅក្នុង-- ក្រោយពេលដួលរលំរបបខ្មែរក្រហមនេះ តើលោកអាចចំណាំបានខ្លះទេ ប្រហាក់ប្រហែលគ្នាឬទេ? សូមអរគុណ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំមិនអាចប្រហាក់ប្រហែលបានទេ ព្រោះយូរដែរហើយ សូមជម្រាបប្រសាសន៍ដោយខ្លីអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

តទៅនេះសូមប្រគល់វេទិកានេះទៅខាងជនជាប់ចោទ បើសិនជាមានការចង់កត់សម្គាល់ខ្លីទៅលើការសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះសូមអញ្ជើញជនជាប់ចោទ សូមធ្វើការកត់សម្គាល់ខ្លី១បានហើយ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! បណ្តឹងរបស់ មិត្តចាន់ មកដល់ដៃខ្ញុំដែរហើយ ។ ខ្ញុំអាន ពិនិត្យចុះពិនិត្យឡើង របស់ដែលខ្ញុំចាប់អារម្មណ៍បំផុត គឺពាក្យមួយមាត់ដែលគាត់និយាយថា គាត់អត់ចង់ជាន់ដីភ្នំពេញទេ ។ ខ្ញុំឮពាក្យនេះ ខ្ញុំតក់ស្លុតណាស់ ខ្ញុំគិតថា សមត្ថភាពវប្បធម៌របស់ មិត្តចាន់ បើសិនជាគាត់គ្មានការឈឺចាប់បែបនេះទេ គាត់សរសេរមិនកើតទេ ។ ដូច្នេះ វាមានទុក្ខវេទនាស្អីមួយធំធេងហើយ បានជាគាត់ស្បថលែងជាន់ដីភ្នំពេញ ។ តើទុក្ខវេទនានោះនៅឯណា? ខ្ញុំរកអត់ទាន់ឃើញទេ ។ បើនិយាយថាគាត់ចូលទៅស-២១ ហើយគាត់-- ខ្ញុំដោះលែងគាត់ឲ្យរួចចេញទៅវិញ ទៅអត់រួចទេ ខ្ញុំអត់ប៊ានទេ ។ ខែ១២ ឆ្នាំ១៩៧៦ ខ្ញុំកាន់កាប់ស-២១ ពេញកណ្តាប់ដៃខ្ញុំ ។ អ្នកទោសដែលខ្ញុំទទួលចូលស-២១ គឺអចិន្ត្រៃយ៍ប្រគល់ឲ្យ តែគេប្រគល់ឲ្យហើយ ខ្ញុំអត់ប៊ានដោះលែងទេ គ្នាអ្នកណាក៏ដោយ តែចូលមកត្រូវតែស្លាប់ ។ ទន្ទឹមនេះ ខ្ញុំទៅបើកមើលបញ្ជីអ្នកទោសស-២១ ខ្ញុំរកឈ្មោះមិត្ត ឡាយ ចាន់ អត់ឃើញទេ ។ ដូច្នេះខ្ញុំទទួលស្គាល់ថាមិត្ត ឡាយ ចាន់ មានទុក្ខ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា រកភស្តុតាងស្អីបន្តិចក៏អត់ឃើញដែរ ថាមិត្ត ឡាយ ចាន់ ទៅរងទុក្ខនៅស-២១ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ សូមប្រគល់វេទិកានេះទៅដល់មេធាវីការពារក្តី ដើម្បីអាចមានឱកាសក្នុងការសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ប្រសិនបើមានសំណួរ សូមអញ្ជើញមេធាវីការពារក្តី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន សូមគោរពលោកចៅក្រមជាតិនិងអន្តរជាតិ សូមគោរពអង្គសវនាការ ។ លោកឡាយ ចាន់ ពេលដែលលោកចូលទៅស-២១ លោកបានឆ្លើយថា លោកអត់ចាំទេរឿងគេថត ឬមិនថតលោក រឿងគេដាក់លេខលោក ហើយថតអីហ្នឹងគឺលោកអត់បានចាំទេ ។ បើលោកមិនបានចាំទេ ពេលអ្នកសួរចម្លើយមកហៅលោកទៅសួរចម្លើយ តើគេហៅលោកយ៉ាងម៉េច? នេះសូមលោកឆ្លើយបញ្ជាក់ ។

[១១:៣៥:០០]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី នៅពេលដែលគេហៅខ្ញុំទៅសួរចម្លើយ គឺគេមិនហៅខ្ញុំថា អាច អាចាន់ ឬក៏អាចន ទេ គេហៅខ្ញុំថា អាម៉ាប់ អ្អែង គេហៅខ្ញុំថា អាម៉ាប់ហើយគេចងមុខខ្ញុំគេបណ្តើរចេញមក ។ ដល់ពេលដែលកន្លែងគេសួរចម្លើយទៀតសោត ក៏គេនិយាយថា "អ្អែងដឹងរឿងអាយីន រឿង អាលឿន ដែរទេ?" ខ្ញុំឆ្លើយថា ខ្ញុំៗអត់ដឹង រឿងខ្ញុំហ្នឹងប៉ុណ្ណឹង គឺខ្ញុំអត់ដឹងរឿងថា ខ្ញុំជានីរសារ ខ្ញុំអត់ដឹងរឿងអីផ្ទៃក្នុងគេខ្ញុំអត់ដឹង ។

**ស៖** សូមអរគុណ ។ សូមលោកបញ្ជាក់បន្ថែមទៀត លោកបានបញ្ជាក់ជូនតុលាការថា លោកឈ្មោះ ឡាយ ចាន់ ហៅ ឡាយ ផន ឯឈ្មោះ ម៉ាប់ នេះគឺប្រធានអង្គភាពហៅលោកទេ គ្មានអ្នកណាហៅលោកទេ ។ ឥឡូវលោកឆ្លើយថា អ្នកសួរសំណួរហៅលោក អាម៉ាប់ ទៅវិញ នេះសូមលោកបញ្ជាក់ទៅមើលហេតុអីបានជាអ៊ីចឹង?

**ឆ៖** ព្រោះនៅពេលនោះ គឺខ្ញុំរាងដូចថា វាតឿដែរ វាមិនមែនរាងដូចសព្វថ្ងៃ វារាងដូចតឿដែរ ។ នេះសូមជម្រាបលោកមេធាវី ។ ហើយវាក៏ម៉ាប់ដែរ ។

**ស៖** អ៊ីចឹង គេអត់ស្គាល់ឈ្មោះលោកថា ម៉ាប់ ទេ ប៉ុន្តែគេឃើញលោកអ៊ីចឹង គេហៅ អាម៉ាប់ អ៊ីចឹងតែម្តងទៅអ្ហែះ? សូមលោកបញ្ជាក់មើល ។

**ឆ៖** ពិតជាត្រឹមត្រូវអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ សុំលោកបញ្ជាក់ឲ្យបានច្បាស់ម្តងទៀត អំពីអ្នកយាមនិយាយគ្នាថា កន្លែងលោកជាប់គុកហ្នឹង ទួលស្លែង ពីព្រោះតាមខ្ញុំដឹង សម័យ ប៉ុល ពត គុកដែលលោកនិយាយហ្នឹង គឺគេហៅថា ស-២១ អ៊ីចឹងនៅសម័យ ប៉ុល ពត អ្នកណាក៏ដឹងថាកន្លែងហ្នឹង ស-២១ ដែរ គេអត់ហៅអីក្រៅពីស-២១ ទេ ។ កន្លែងនេះការពិតពីសម័យសីហនុគេហៅថា "វិទ្យាល័យពញាយ៉ាត" លុះដល់មក

សម័យ លន់ នល់ គេហៅថា "វិទ្យាល័យទួលស្វាយព្រៃ" ហើយក្រោយឆ្នាំ១៩៧៩ ពេលបច្ចុប្បន្នយើងឥឡូវនេះ ដោយសារនៅជុំវិញទាំងអស់វាអត់មានអក្សរទាំងអស់ស-២១ មិនដែលមានស្លាកថាស-២១ មិនដែលថា គុកស-២១ មិនដែលនិយាយថា "គុកទួលស្លែង" ទេក៏ប៉ុន្តែនៅក្រោយឆ្នាំ៧៩ វាមានសាលាបឋមសិក្សាទួលស្លែងដែលវានៅសល់ស្លាក នៅសល់*អេទិកែត* វានៅសល់ឥឡូវដឹងរុះចោលឬនៅទេនៅឆ្នាំ៨៥, ៨៦ ឆ្នាំ៩០ អីឃើញនៅហ្នឹង គេដាក់នៅសាលាបឋមទួលស្លែង ។ អ៊ីចឹងទេ ក្រោយឆ្នាំ១៩៧៩ មហាជនទូទៅគេទៅកន្លែងនោះ គេឲ្យឈ្មោះថា គុកទួលស្លែង ដោយគេអត់ដឹងថា អាហ្នឹងស-២១ ។ នែ៎អាគុកទួលស្លែងហ្នឹង គេហៅក្រោយឆ្នាំ៧៩ ។ អ៊ីចឹងសុំលោកបញ្ជាក់ ហេតុអីក៏បានអ្នកឆ្នាំនោះនិយាយថា កន្លែងហ្នឹងគុកទួលស្លែងទៅវិញ សូមលោកបញ្ជាក់ទៅមើល ។

[១១:៣៩:០៣]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! រឿងត្រង់ថា សាលាស្អីៗ ខ្ញុំមិនដឹងទេ ។ ខ្ញុំដឹងថា អ្នកយាមពីរនាក់ ដែលខ្ញុំមិនស្គាល់មុខ ហើយបើនិយាយទៅ មនុស្សនោះក៏វាមិនបងខ្ញុំដែរ អ្នកយាមនោះហើយក៏តូចៗដែរទេ ដែលនិយាយនៅខាងក្រៅខ្ញុំនោះ ដែលខ្ញុំក្តាប់បាន ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ សូមលោកបញ្ជាក់បន្ថែមមួយទៀត ។ អំមិញនេះ លោកប្រធានបានសួរលោកថា អំពីរបបអាហារ លោកបានឆ្លើយថា បបរ ហើយមានពាក្យថា បាយ ដែរ ហើយស្រាប់ដល់លោកប្រធានសួរបញ្ជាក់ឡើងទៅ តទៅទៀតទៅ លោកថាមានបបរ ជួនកាលអាបបរហ្នឹងវារាវ ជួនកាលទៅហ្នឹងអាបបរខាប់ វាបាត់អាបាយអត់មាននិយាយតទៅទៀតទេ ។ អ៊ីចឹង ខ្ញុំសុំសួរលោកបញ្ជាក់ឡើងវិញ តើក្នុងរយៈពេលបីខែដែលលោកជាប់នៅស-២១ តើគេមានឲ្យបាយលោកពិសាឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅបញ្ហារឿងបញ្ហាបាយ គេឲ្យខ្ញុំមែន ក៏ប៉ុន្តែបាយនោះចានចង្កឹះអត់ដែលពេញទេ តែមួយពេលហ្នឹងឲ្យខ្ញុំមួយពេលហ្នឹង ខ្ញុំសូមជម្រាបប្រសាសន៍អ៊ីចេះមិនមែនថា ខ្ញុំបដិសេធទេ សូមជម្រាប ។

**ស៖** សូមអរគុណ ។ អ៊ីចឹងក្នុងរយៈពេលបីខែ ដែលលោកជាប់នៅទីនោះ គេឲ្យតែម្តងទេ អ៊ីចឹងមែនទេ?

**ឆ៖** គឺបាយ គឺឲ្យខ្ញុំម្តងមែន ។

**ស៖** សូមអរគុណ។ សូមលោកបញ្ជាក់បន្ថែមទៀត បន្ទប់ឃុំឃាំងដែលយកទៅដាក់លោកហ្នឹង ជាតូចចង្អៀត លោកថាតូចចង្អៀត ទទឹងប្រហែលជាអាចមួយម៉ែត្រ ឬក៏ជាងតិចតួច ខាងលើពីខាងលើ គឺថ្ម លោកឈរទៅគឺថា មិនបានត្រង់ខ្លួនល្អទេ គឺវាអាចប៉ះក្បាលលោកទៅហើយ វាអាចប៉ះ ។ អ៊ីចឹង ខ្ញុំយល់ថា លោកអាចច្រឡំកន្លែង ក្រែងវាមិនមែនស-២១ ព្រោះស-២១ អើ!បន្ទប់វាតូចចង្អៀតដូចគ្នា ក៏ប៉ុន្តែវាទាស់រឿងកម្ពស់ ។ កម្ពស់ស-២១ គឺកម្ពស់ អាដែងន៉េ ព្រោះបន្ទប់ហ្នឹងជាបន្ទប់ថ្នាក់រៀន ជាថ្នាក់រៀន ហើយគេគ្រាន់តែធ្វើបន្ទប់តូច ក៏ប៉ុន្តែខាងលើបន្ទប់តូចហ្នឹង វាអត់មាន *ផ្លាស់ហ្វុង* អត់មានដំបូលទេ គឺវានៅបន្ទប់នៅឯលើងណោះ ដូច្នេះលោកមួយស្រឡាញ់ទៅទៀត ក៏វាអត់ប៉ះក្បាលលោកដែរ នេះវាខ្ពស់ ។ អ៊ីចឹង លោកអាចច្រឡំ អ៊ីចឹងលោកបញ្ជាក់ម្តងមើល កន្លែងហ្នឹងវាយ៉ាងម៉េច?

[១១:៤២:១៧]

**ឆ៖** ខ្ញុំចាំពុំបានច្បាស់ទេ ព្រោះនៅពេលដែលខ្ញុំបាទជាប់នៅបន្ទប់នោះ គឺខ្ញុំបានចាំបានថា នៅលើក្បាលរបស់ខ្ញុំបាទ គឺមានបេតុងដែលនៅខាងលើ ហើយខាងៗ ដោយឡែកតែខាងក្រោយខ្ញុំគឺជញ្ជាំងឈើតែប៉ុណ្ណោះ ។ មិនដឹងថា កន្លែងនោះយ៉ាងណាៗ គឺខ្ញុំអត់បានដឹងទេ ព្រោះធម្មតា ខ្ញុំអ្នកទោស ខ្ញុំមិនអាចមានសិទ្ធិទៅអើត ឬក៏ដើរសម្លឹងឈរសម្លឹងមើលគ្រប់បែប គ្រប់យ៉ាងនោះគឺខ្ញុំអត់មានសិទ្ធិ ។ នេះសូមជម្រាបប្រសាសន៍មេធាវីដោយខ្លីប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ខ្ញុំសុំសួរសំណួរអម្បាញ់មិញនេះ ក្រែងលោលោកច្រឡំកន្លែង ពីព្រោះកន្លែងសន្តិសុខ ស្រុកខ្មែរសម័យ ប៉ុល ពត ហ្នឹងមានច្រើនណាស់ ។ អ៊ីចឹងលោកអាចជាប់កន្លែងណាក្រៅពីកន្លែងនេះ ពីព្រោះកន្លែងនេះវា-- ទទឹងបណ្តោយបន្ទប់តូចចង្អៀតហ្នឹង ខ្ញុំអត់សួរទេ ខ្ញុំសួរអារឿងដំបូលខាងលើ ។ ខាងលើពីព្រោះទួលស្លែង វាអត់មានអីណាទាប លោកអាចឈរទៅទើសក្បាលលោកទេ លោកហាក់មួយស្រឡាញ់ឡើងលើទៀត ប៉ុនណាក៏អត់ទើសដែរ ។ រួចដែលលោកថា ទើស ដូច្នេះលោកអាចច្រឡំកន្លែង កន្លែងហ្នឹងក្រែងលោវាមិនមែនស-២១ បានជាខ្ញុំសួរបញ្ជាក់លោក ក្រែងលោលោកគិតទៅឃើញ ។ ឥឡូវ ខ្ញុំសុំសួរសំណួរតទៅទៀត នៅក្នុងបន្ទប់ឃុំឃាំងដដែល លោកថាត្រូវបានគេដាក់ខ្នោះជើង ចងស្ពាបសេកទៅក្រោយ និងបានចងមុខជាប់រហូត អ៊ីចឹងមែនឬទេ? សូមលោកបញ្ជាក់ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន-- មេធាវី ។ ក្នុងបញ្ហាដែលយើងខ្ញុំជាប់នៅទីកន្លែងនោះ ពេលដែលគេបញ្ចេញខ្ញុំទៅសួរចម្លើយ ឬឲ្យខ្ញុំទៅធ្វើការគេ ដែលគេប្រើ ឲ្យគេចងមុខខ្ញុំ ។ បើ

សិនជាតែខ្ញុំជាប់ខ្នោះ នៅក្នុងនោះគឺគេស្រាយតែមុខខ្ញុំហើយ តែខ្នោះគឺគេដាក់ខ្ញុំ តែចំណងដៃរបស់ខ្ញុំ គឺគេស្រាយបន្ធូរអត់មែនសេរីបានទេ ដៃយើងខ្ញុំ ។ នេះខ្ញុំសូមជម្រាបអ៊ីចឹង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងខ្នោះជើងនៅជាប់ ចំណងដៃគ្រាន់តែបន្ធូរទេ! អត់លែងទេ អ៊ីចឹង ខ្ញុំសុំសួរលោកតទៅទៀត តើពេលលោកបត់ជើងតូច ពេលលោកបត់ជើងធំ លោកធ្វើយ៉ាងម៉េចពេល បរិភោគអាហារអីហ្នឹង លោកធ្វើយ៉ាងម៉េច? បើជើងជាប់ខ្នោះ បើវានៅដៃ គេអត់ចងលោកបរិភោគ កើត លោកបត់ជើងធំ ជើងតូចអីកើត ។ ហើយចុះបើវាជាប់ទាំងអស់ គ្រាន់តែបន្ធូរបន្តិច ដូច្នេះវានៅ ជាប់ដដែល តើលោកបត់ជើងយ៉ាងម៉េច? លោកពិសាបាយយ៉ាងម៉េច? លោកបត់ជើងធំតូចយ៉ាងម៉េច? លោកបត់ជើងធំយ៉ាងម៉េច? សូមលោកបញ្ជាក់ជូនតុលាការឲ្យបានជ្រាបសូមអរគុណ ។

[១១:៤៥:២០]

**ឆ៖** សូមជម្រាបលោកមេធាវី! ក្នុងបញ្ហាដែលគេចាប់ ហើយគេចងដៃខ្ញុំដែលគេអត់ស្រាយនោះ គឺមូលហេតុដែលគេបន្ធូរខ្ញុំមិនមែនបន្ធូរឲ្យខ្ញុំធ្វើអ៊ីចេះៗរួចទេ គ្រាន់តែគេបន្ធូរឲ្យយើងគ្រាន់តែស្រាតខោ ឬក៏យើងអាចហូបអីៗបាន ។ ក៏ប៉ុន្តែ ចំណងអានេះនៅតែជាប់ដដែល ក៏ប៉ុន្តែវាធូរ វាអត់មែនយើងក្រៀក ជាប់រហូត យើងនោម ក៏មិនកើត យើងជុះក៏មិនកើតនោះ គឺមិនមែនទេ ។ ខ្ញុំសូមជម្រាបប្រសាសន៍ ដោយខ្លីប៉ុណ្ណេះ ។ គ្រាន់ថាគេថាគេបន្ធូរដៃយើង តែអាចំណងនោះនៅតែចំណងដដែលក៏ប៉ុន្តែគេបន្ធូរ យើងបានដូចដែលយើងបានអង្គុយបានប៉ុណ្ណេះអីបាន យើងថា យើងនោមឬយើងទៅទាញធុងអីយើង អាចលូកបានទាញបាន ។ ខ្ញុំសូមជម្រាបប្រសាសន៍ ។

**ស៖** សូមអរគុណ ។ ខ្ញុំសុំសួរលោកបន្ថែមទៀតមួយសំណួរទៀត ។ តើលោកមានភស្តុតាងអ្វី ដែលបញ្ជាក់ថា លោកបានមកជាប់នៅស-២១? ហើយស-២១ បានលែងលោកទៅវិញ? សូមលោក បញ្ជាក់លោកមានភស្តុតាងអី? ពីព្រោះកន្លងមកអ្នកឲ្យតែជាប់នៅស-២១ យ៉ាងហោចណាស់ក៏គេមាន ប្រវត្តិរូបមួយនៅស-២១ តែចូលទៅគេសួរប្រវត្តិរូបរបស់លោកហើយ ។ ហើយអ៊ីចឹងកន្លងមក ទោះបី ថាខ្ញុំមិនទទួលស្គាល់ថា គាត់ជាប់នៅស-២១ ក៏ដោយឲ្យតែគាត់បង្ហាញប្រវត្តិរូបមក ខ្ញុំទទួលស្គាល់ភ្លាម ឲ្យកូនក្តី ឲ្យជនជាប់ចោទទទួលស្គាល់ភ្លាម គាត់ពិតជារងគ្រោះនៅស-២១ ពិតប្រាកដមែន ។ ឥឡូវសូម លោកបញ្ជាក់មើលបើរូបថតលោកនៅស-២១ ក៏អត់មាន ប្រវត្តិរូបរបស់លោកនៅស-២១ ក៏អត់មាន គេសួរចម្លើយលោកពីរដងនៅស-២១ ចម្លើយរបស់លោកក៏គ្មានឃើញនៅស-២១ ។ ដូច្នេះ សូមលោក បញ្ជាក់មើលៗ តើមានភស្តុតាងអីដែលបញ្ជាក់ថា លោកបានជាប់នៅស-២១ ហើយស-២១ បានលែង

លោកទៅវិញ? ពីព្រោះស-២១ តែចូលហើយគ្មានលែងអ្នកណាទៅវិញទេ ស-២១ ទោះបីចាប់ច្រឡំយកមកឱ្យតែចូលដល់ក្នុងរបងហើយ គេអត់លែងទៅវិញទេ ប្រាប់ថា ចាប់ច្រឡំក៏គេកម្ទេចចោលដែរ។ ពាក្យស្លោក ប៉ុល ពត ថា "សូវសម្លាប់ច្រឡំ កុំឱ្យលែងច្រឡំ" ហើយចុះរឿងអីដែលលោកចូលមកបីខែហើយគេលែងលោកទៅវិញ លោកមានភស្តុតាងអី? សូមលោកបញ្ជាក់ ។

**ឆះ** សូមជម្រាបលោកមេធាវី! ចំពោះភស្តុតាងដែលជាឯកសារ គឺខ្ញុំរកមិនឃើញទេ ក៏ប៉ុន្តែបើភស្តុតាងនៅលើរូបរាងកាយរបស់យើងខ្ញុំ យើងអាចបង្ហាញបាន ។ នៅជើងរបស់ខ្ញុំខាងឆ្វេង និងខាងស្តាំអាចនឹងមានស្នាម អត់ទាន់រលុបបាត់ទេ ។ នេះខ្ញុំសូមជម្រាបមេធាវីដោយខ្លី ។

[១១:៤៨:២៥]

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ ខ្ញុំបាទមេធាវីការពារមិនបដិសេធ គឺសុំទទួលស្គាល់ថាលោកធ្លាប់រងទុក្ខ ធ្លាប់រងទារុណកម្មនៅក្នុងរបបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃពិតប្រាកដមែន ។ ខ្ញុំមិនបដិសេធទេ ក៏ប៉ុន្តែ ខ្ញុំសួរទាំងអស់សំណួរដែលខ្ញុំសួរតាំងពីលើកមុនថា បន្ទប់តូចចង្អៀតអីនេះ រហូតដល់ដំបូលអីនេះ ខ្ញុំខ្លាចលោកច្រឡំ ។ អ៊ីចឹងខ្ញុំខ្លាចលោកច្រឡំ ខ្លាចលោមិនជាប់ស-២១ វាជាប់នៅកន្លែងផ្សេងទៀត ហើយព្រោះលោកថាចងមុខមក លោកអត់ដឹងឯណាឯណីទេ ណ៎ា គេតែចងមុខចេញពីបន្ទប់ទៅរហូតដល់ពេលសួរចម្លើយក៏តែចងលោកទៀត ។ ដូច្នេះ លោកអត់មានមើលអីឃើញទេ រួចគេឌុបលោកពី ដាក់លោកចងពីស-២១ ឱ្យឡើងទៅលើឡាន គេចងមុខទៀត ធាក់ទម្លាក់ពីលើឡានមក លោកនៅជាប់មុខហ្នឹង គេចងទៀត ។ ដូច្នេះ វាម៉េច លោកអត់ដឹងថា អាណាស-២១ ពិតប្រាកដទេ ត្រង់ហ្នឹងហើយ ដែលខ្ញុំចង់សួរបញ្ជាក់លោកថា លោកមានភស្តុតាងអីនោះ? ហើយបើលោកឆ្លើយថា ទេអត់មានអីទេ មានតែភស្តុតាងលើខ្លួនខ្ញុំទទួលស្គាល់ហើយ អាភស្តុតាងលើខ្លួន ប៉ុន្តែ លោកមិនមែនរងទុក្ខនៅស-២១ ។ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេ ។ សូមអរគុណ ខ្ញុំសូមអស់សំណួរតុលាការ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារអន្តរជាតិ តើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទេ ដើម្បីសួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយសារលោក ការ សាវុត្ថ បានសួរសំណួរនោះអស់ទៅហើយ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដំណើរការនីតិវិធីនៃការស្តាប់សក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ចាន់ គឺដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឡាយ ចាន់ ដែលបានអញ្ជើញមកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការតាមការកោះហៅរបស់អង្គជំនុំជម្រះសាលាដំបូង ។ ហើយអង្គជំនុំជម្រះក៏បានយល់ដែរ អំពីស្ថានភាពប្រឈម និងការលំបាករបស់លោកនៅក្នុងការឆ្លើយនូវសំណួរជាច្រើន ដែលសួរដោយអង្គជំនុំជម្រះនិងភាគី ។ ហើយម៉្យាងទៀត ក៏លោកមានការលំបាកជាច្រើនដែលលោកបានរំឭកឡើងវិញនូវអ្វីដែលលោកបានជួបប្រទះ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ កន្លងមកនោះ ដែលពោរពេញទៅដោយការឈឺចាប់នោះ ។

អង្គជំនុំជម្រះ ដោយសារពេលវេលាអស់ហើយនៅសល់តិចតួច អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ។ ហើយអង្គជំនុំជម្រះនឹងលើកបន្តទៅដំណើរការសវនាការនៅពេលរសៀលចាប់ពីម៉ោងមួយកន្លះរសៀលនេះ ដោយស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតគឺ E233 ដែលអង្គជំនុំជម្រះបានធ្វើការកោះហៅគាត់មកហើយ ហើយគឺចាប់ផ្តើមធ្វើនៅចាប់ពីម៉ោងមួយកន្លះរសៀលនេះ អ៊ីចឹងអញ្ជើញភាគីចូលរួមដើម្បីឱ្យនៅក្នុងដំណើរការនីតិវិធីសវនាការដេញដោលនៅរសៀលនេះ ។

មន្ត្រីតុលាការសូមសម្របសម្រួលដល់ លោក ឡាយ ចាន់ ដើម្បីលោកបានទៅត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ដោយការរៀបចំនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ នៃអ.វ.ត.ក របស់យើង ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយឱ្យនាំគាត់មកកាន់សាលសវនាការឱ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១១:៥២ នាទី ដល់ម៉ោង ១៣:៣០ នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត ។

មន្ត្រីតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភោគ ខន ចូលមកកាន់ក្នុងបន្ទប់សវនាការ។

**លោក គីម ម៉េងឃី៖**

លោកប្រធានសុំអនុញ្ញាតលោកប្រធាន ។ តាងនាមឱ្យមេធាវីរដ្ឋប្បវេណីក្រុមបី ខ្ញុំបាទមានសំណើ

មួយពាក់ព័ន្ធទៅនឹងការដាក់នូវឯកសារដើម្បីជួយសម្រួលដល់អង្គជំនុំជម្រះក្នុងការពិចារណា ។ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីបានដាក់ បានឆ្លើយតបទៅនឹងការជូនដំណឹងរបស់អង្គជំនុំជម្រះ ហើយទន្ទឹមនឹងបានឆ្លើយតបទៅនឹងការជូនដំណឹងអំពីការដាក់ភស្តុតាង និងឯកសារថ្មីដែលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយនៅក្នុងឧបសម្ព័ន្ធនៃឯកសារនោះគឺឯកសារ E5/7/1.3 ដែលឯកសារនោះគឺភាសាដើម គឺជាភាសាខ្មែរ ហើយរហូតមកដល់ពេលនេះគឺបានបកប្រែទៅជាភាសាអង់គ្លេស ។ ហើយការបកប្រែទៅជាភាសាបារាំង គឺមិនទាន់ត្រូវបានធ្វើនៅឡើយទេ ។ ហើយដោយយល់ឃើញថា មេធាវីខាងការពារ និងអង្គសវនាការទាំងមូលត្រូវការបីភាសា ខាងក្រុមមេធាវីយើងខ្ញុំបានបកប្រែឯកសារនោះក្រៅផ្លូវការទៅជាភាសាបារាំង ហើយបើសិនជាលោកប្រធានអនុញ្ញាតយើងសូមស្នើសុំដាក់ជូននូវឯកសារដែលមាននៅក្នុងសំណុំរឿងរួចនោះហើយ ហើយភ្ជាប់នឹងឯកសារដែលយើងខ្ញុំបានបកប្រែជូនអង្គសវនាការដើម្បីពិនិត្យពិចារណា ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសួរទៅភាគីទាំងអស់ថា តើមានមតិយោបល់ចង់កត់សម្គាល់អ្វីដែលទេនូវឯកសារដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីបានលើកឡើងអម្បាញ់មិញនេះដោយសារ មានទាំងថា ឯកសារនេះនៅបកប្រែជាភាសាបារាំងហ្នឹងគឺមិនទាន់-- ក្រៅផ្លូវការនៅឡើយ ។ មានមតិយោបល់កត់សម្គាល់យ៉ាងណាទេអំពីបញ្ហានេះ ឯកសារដែលសុំដាក់នេះ ហើយនិងឯកសារដែលបកប្រែជាភាសាបារាំងក្រៅផ្លូវការនេះ ។

[១៣:៣៧:២៧]

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំដូចជាយល់មិនសូវច្បាស់ ហើយហាក់ដូចជាការបកប្រែមិនសូវយល់ ។ អង្គសវនាការចង់ដឹងថាភាគីមានការសង្កេតចង់លើកឡើងចំពោះការផលិត ឬក៏ការផ្តល់ជូននូវឯកសារបកប្រែមិនផ្លូវការនៅក្នុងដំណើរក្តីនេះដែរឬទេ? ឬក៏ភាគីទាំងឡាយជំទាស់ទៅលើការស្នើសុំដូច្នេះ? ដោយយើងត្រូវដឹងថាការបកប្រែនោះមិនមែនជាការបកប្រែផ្លូវការនោះទេ ការបកប្រែមិនផ្លូវការនោះធ្វើឡើងដើម្បីគ្រាន់តែជាការជ្រាបនូវព័ត៌មានទាំងឡាយតែប៉ុណ្ណោះ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ចំពោះខ្ញុំៗយល់ថា ការដាក់ឯកសារនេះចូលក្នុងសំណុំរឿងជាផ្លូវការ ខ្ញុំយល់ថា មិនអាចទាន់ទទួលយកបានទេ ពីព្រោះអ្វីក៏ដោយវាទាល់តែបកប្រែជាផ្លូវការឲ្យបានត្រឹមត្រូវចាំយកទៅដាក់ ពីព្រោះបើមិនទាន់ផ្លូវការដល់យកទៅដាក់ទៅក៏វានៅតែមិនទាន់ផ្លូវការ ។ ដូច្នេះ ខ្ញុំយល់ថាចំពោះខ្ញុំវិញខាងមេធាវីការពារគឺទទួលយកមិនទាន់បានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តាមការបង្ហាញរបស់មេធាវីការពារក្ដីលើកឡើងថា ពីរភាសាបានដាក់ជាផ្លូវការរួចហើយ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ។ ហើយដោយឡែកមានតែភាសាបារាំងទេ ដែលមិនទាន់បានបកប្រែជាផ្លូវការ គឺបានបកប្រែក្រៅផ្លូវការ ។ អ៊ីចឹងជាគោលការណ៍ការប្រើប្រាស់ភាសា គឺមានពីរភាសាដោយភាសាខ្មែរ និងភាសាអន្តរជាតិមួយទៀត បារាំង ឬអង់គ្លេសដាក់ទៅក្នុងសំណុំរឿងជាការចាត់ទុកថាជាផ្លូវការរួចហើយ ។ មេធាវីតំណាងឲ្យក្រុមបីដូច ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**លោក គីម ម៉េងឃី៖**

អរគុណលោកប្រធាន ។ លោកប្រធានមានប្រសាសន៍ហ្នឹងគឺត្រឹមត្រូវហើយ គឺភាសាដែលបានដាក់ជាភាសាដើមគឺភាសាខ្មែរ ហើយបកប្រែត្រឹមត្រូវជាភាសាអង់គ្លេស ហើយចំណែកឯជាភាសាបារាំងនោះគឺពួកយើងជួយសម្រួលដល់ខាងការងារដើម្បីងាយស្រួលនឹងយល់តែប៉ុណ្ណោះ បើសិនជាលោកប្រធានអនុញ្ញាត យើងខ្ញុំនឹងប្រគល់ជូនទៅឲ្យភាគីដែលលោកត្រូវការ ។ បើសិនជាភាគីគាត់មិនត្រូវការទេ យើងខ្ញុំនៅតែមិនទទូចសុំឲ្យយកការបកប្រែរបស់យើងទទួលស្គាល់ជាផ្លូវការនោះទេ ។

សូមអរគុណ ។

[១៣:៤២:៥៤]

**ប្រធានអង្គជំនុំ៖**

ដោយសារបញ្ហាការដាក់ឯកសារដែលមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីបានលើកឡើងនេះ គឺឯកសារដែលជាភាសាខ្មែរនិងភាសាអង់គ្លេសគឺ ដោយសារឯកសារនេះនៅក្នុងសំណុំរឿងហើយៗអង្គជំនុំជម្រះយល់ឃើញថា អាចលើកមកដេញដោលនៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សានេះបាន។ ដោយឡែកគឺឯកសារជាភាសាបារាំង ដែលមានការបកប្រែក្រៅផ្លូវការ ហើយមានការជំទាស់ពីមេធាវី

ការពារនោះគឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលើកឯកសារដែលមានការបកប្រែជា ភាសាបារាំងនោះមកដេញដោលទេ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកឈ្មោះអ្វីដែរ?

**លោក ភោគ ខន៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំឈ្មោះ ភោគ ខន ។

**ស៖** លោក ភោគ ខន តើលោកមានឈ្មោះអ្វីផ្សេងទៀតក្រៅពីឈ្មោះ ខន ដែរឬទេ?

**ឆ៖** បាទ,លោកប្រធានគឺគ្មានទេ ។

**ស៖** លោក ភោគ ខន អំមិញយើងជឿថា មន្ត្រីតុលាការបានសម្របសម្រួលជាមួយលោកហើយថា មុននឹងលោកឆ្លើយនឹងសំណួរលោកចាំមើលភ្លើងក្រហមនៅក្បាលមេក្រូនេះ ចាំមានសញ្ញាភ្លើងក្រហម សឹមលោកនិយាយ។ បើលោកនិយាយមុន គឺសំឡេងរបស់លោកមិនបានចូលទៅក្នុងប្រព័ន្ធនៃសំឡេងដែលអាចបកប្រែជាភាសាអន្តរជាតិបានទេ សូម្បីតែខ្មែរហ្នឹងក៏ស្តាប់មិនឮដែរ ។ សង្ឃឹមថាលោកយល់អំពីបញ្ហានេះ ហើយអនុវត្តឲ្យបានល្អ ។ លោក តើលោក ភោគ ខន ឆ្នាំនេះលោក មានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** បាទជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអាយុ ៥៧ឆ្នាំហើយ ។

[១៣:៤៥:០០]

**ស៖** នៅក្នុងសម័យសង្គ្រាម មុនឆ្នាំមួយពាន់ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោករស់នៅឯណា ហើយលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺខ្ញុំរស់នៅនឹងព្រៃកក្តាម នៅជាយោធាខ្មែរក្រហម ។

**ស៖** នៅយោធាកងអង្គភាពណាជាក់លាក់ដែរ លោកអាចនៅចងចាំបានទេ អាននិយាយប្រាប់ដល់អង្គសវនាការបានទេ អំពីអង្គភាពដែលលោកបានធ្វើកងទ័ពនៅក្នុងកាលពីលោកឈរជើងនៅព្រៃកក្តាមនោះ?

**ឆ៖** ជម្រាបប្រសាសន៍នៅក្នុងអង្គភាពវរសេនាតូច៣០៨ ។

**ស៖** នៅកងពលលេខប៉ុន្មានដែរ?

**ឆ៖** ជម្រាបប្រសាសន៍! នៅពេលនោះ គឺខ្ញុំដូចជាភ្លេចកងពលហើយ ចាំតែវរសេនាតូច ព្រោះកាលណោះវរកងពលចាស់មិនទាន់បង្កើតថ្មីនៅឡើយទេ ។

**ស៖** នៅក្នុងរឿងក្តីនេះ លោកបានដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើលោកប្តឹងទាមទារសំណងដោយខ្លួនឯង ឬក៏លោកទុកសិទ្ធិ ឬក៏ផ្ទេរសិទ្ធិនៅក្នុងការប្តឹងទាមទារសំណងនេះជូនទៅដល់មេធាវី ដែលជាអ្នកតំណាងរបស់លោក?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺថាការដាក់ជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺខ្ញុំបាទទាមទារសំណងក៏ខ្ញុំគ្មានសិទ្ធិនឹងទាមទារទេ គឺប្រគល់តួនាទីនេះជូនមេធាវីរបស់យើងខ្ញុំជាអ្នកជួយ ។

**ស៖** តាមពិតលោកមានសិទ្ធិក្នុងការប្តឹងទាមទារ ប៉ុន្តែលោករក្សាសិទ្ធិមិនទាមទារផ្ទាល់ដោយខ្លួនឯងទេ គឺការទាមទារនេះលោកប្រគល់សិទ្ធិ ផ្ទេរសិទ្ធិទៅឲ្យមេធាវីជាអ្នកតំណាងរបស់លោកប្តឹងទាមទារ ។ លោកចង់និយាយថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ដូច្នោះមែន ។

**ស៖** លោក តើស្ថានភាពនៃព្យសនកម្ម គឺផលអន្តរាយដែលវាមានចំពោះលោកដោយសារអំពើផ្សេងៗនៅក្នុងជំនាន់របបខ្មែរក្រហមនោះ បានប្រព្រឹត្តចំពោះលោកទាំងខាងស្មារតីនិងរាងកាយ តើលោកមានបន្សល់ទុកនូវផលវិបាកអ្វីខ្លះចំពោះរូបលោករហូតដល់សព្វថ្ងៃនេះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន លោកប្រធានចង់សួរពីឆ្នាំ១៩៧៥ ឬក៏មុន?

**ស៖** ដល់ពេលនេះ ដល់ពេលបច្ចុប្បន្នភាពនេះ តើលោកមានផលវិបាកអីទេ ដូចជាខាងរាងកាយមានការរបួស មានពិការដៃជើង ឬក៏ពិការត្រង់ណាមួយ ឬក៏សតិអារម្មណ៍ស្មារតីរបស់លោកហ្នឹងមានស្ថានភាពយ៉ាងម៉េចដែលវាបានបន្សល់ទុកនៅក្នុងអំឡុងពេលដែលលោកបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ហើយវាបាននៅសេសសល់រហូតដល់សព្វថ្ងៃនេះ?

[១៣:៤៩:០១]

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺថានៅក្នុងរាងកាយរបស់ខ្ញុំផ្ទាល់គឺថា ចាប់តាំងពីខ្ញុំបានចូលរួមនៅក្នុងជួរកងទ័ពរហូតមកដល់-- ខាងសុខភាពបន្សល់ទុកនូវការឈឺចាប់ជាច្រើនដែលធ្វើចំពោះរូបខ្ញុំផ្ទាល់ ដូចជាការកន្លងមកទុក្ខវេទនាគឺយ៉ាប់ណាស់ គឺថាកងទ័ពពេលនោះ គឺគ្មានសិទ្ធិសេរីភាព ព្រោះថាពេលសង្គ្រាមចង់ហើយ កងទ័ពក៏ទទួលនូវការលំបាកតទៅទៀត ។ រូបខ្ញុំក៏មានការពិការខ្លួនរហូតតាំងពីសម័យសង្គ្រាមរហូតមកដល់បច្ចុប្បន្ននេះ ។ សូមជម្រាបប្រសាសន៍ ។

**ស៖** សំណួរសួរថា តើលោកមានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ? តើលោកមានទំនាក់ទំនងផ្ទាល់ខ្លួនរបស់លោក ឬក៏លោកមានទំនាក់ទំនងដោយសារញាតិលោហិត ឬក៏ញាតិពន្ធ ឬក៏សហព័ទ្ធរបស់លោកដែលទទួលរងដោយការប៉ះពាល់ដោយជនជាប់ចោទនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! នៅក្នុងការពាក់ព័ន្ធនៅក្នុងរឿងនេះ គឺមានពាក់ព័ន្ធទៅលើបងខ្ញុំជីដូនមួយ ហើយនិងគ្រួសារខ្ញុំផ្ទាល់ពីសម័យឆ្នាំ១៩៧៥ រហូតមកដល់១៩៧៩ គឺគ្រួសារខ្ញុំទទួលរងទុក្ខវេទនានៅស-២១ ។

**ស៖** លោកនិយាយពាក្យថាគ្រួសារហ្នឹងចង់និយាយថា ភរិយារបស់លោក ឬក៏គ្រួសារជាឪពុកម្តាយ ជាបងប្អូនរបស់លោក?

**ឆ៖** បាទ, គឺដូចជាបងជីដូនមួយខ្ញុំ គឺជាបង ឯគ្រួសារមួយទៀតគឺជាប្រពន្ធផ្ទាល់របស់ខ្ញុំ ។

**ស៖** បងរបស់លោកដែលមានការពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ហ្នឹងឈ្មោះអីដែរ? ហើយគាត់ទទួលរងយ៉ាងម៉េចពីកងកំលាំងរបស់ខ្មែរក្រហមក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យនោះ? និយាយពីបងជីដូនមួយសិនណា ។

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺបងជីដូនមួយខ្ញុំគឺឈ្មោះដើមរបស់គាត់គឺឈ្មោះ ឈឿង ភាំ ឈ្មោះសម័យបដិវត្តន៍នោះគឺឈ្មោះ ទិន ណេត ។ គាត់រស់នៅក្នុងវរសេនាតូច៣១៧ ជាប្រធានកងអនុសេនាធំ ។

[១៣:៥២:០៧]

**ស៖** លោកបញ្ជាក់ម្តងទៀត ឈឿង អីគេ?

**ឆ៖** បាទ គឺឈ្មោះ ឈឿង ភាំ ឈ្មោះ បដិវត្តន៍គឺ ទិន ណេត ។

**ស៖** ឈ្មោះនេះមានការពាក់ព័ន្ធយ៉ាងម៉េចជាមួយនឹងអង្គហេតុចោទប្រកាន់ចំពោះជនជាប់ចោទ ទាក់ទិនទៅនឹងរឿងរ៉ាវយ៉ាងម៉េចចំពោះគាត់ ហើយនៅកន្លែងណា?

**ឆ៖** បាទ, នៅក្នុងអំឡុងឆ្នាំ១៩៧៦ គឺឈ្មោះ ឈឿង ភាំ ហៅ ទិន ណេត នេះក៏បានរស់នៅក្នុងកងពល អំវរសេនាតូច៣១៧ ជាកងវិន័យ គឺរស់នៅក្នុងឃ្មួញ ។ ពេលដែលចាប់ខ្លួននៅឆ្នាំ១៩៧៧ហ្នឹងគឺ ប៉ុន្តែការចាប់នោះ គឺមិនដឹងជាចាប់ទៅស-២១ ឬទៅកន្លែងណានោះទេ ក៏ប៉ុន្តែដោយបាត់ខ្លួនតាំងពីពេលនោះមករហូតមកដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែ ការស្រាវជ្រាវរកប្រវត្តិរូបរបស់គាត់គឺឃើញនៅក្នុង

មន្ទីរស-២១ ។

**ស៖** លោកមានឯកសារអ្វីបញ្ជាក់អំពីថាប្រវត្តិរូបរបស់គាត់ឈ្មោះ ទិន ណោត ឈ្មោះបដិវត្តន៍ ហើយឈ្មោះដើម ឈឿង ភាំ ហ្នឹងនៅមន្ទីរស-២១ ដែរឬទេ?

**ឆ៖** បាទ, គឺមានប្រវត្តិរូបផ្ទាល់របស់គាត់ផ្ទាល់បាទ ។

**ស៖** លោកបានយកមកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺយកមកបាទ ។

**ស៖** មន្ត្រីតុលាការយកឯកសារអម្បាញ់មិញនេះ ដាក់បញ្ចាំងនៅស្លាយ ។

[១៣:៥៥:១៨]

**ប្រធានអង្គជំនុំ៖**

រៀបចំឲ្យល្អមៗទៅ ហើយនិងអូសវាឲ្យឡើងទៅលើបណ្តើរៗទៅ ។

**លោក គឹម ម៉េងឃី៖**

សូមអនុញ្ញាតលោកប្រធានអង្គជំនុំជម្រះ! ដើម្បីងាយស្រួលក្នុងការបង្ហាញឯកសារនេះ គឺខ្ញុំបាទសូមជម្រាបលេខជានៅក្នុងឯកសារសំណុំរឿង គឺជាភាសាខ្មែរ ERN 00282314 ។ ហើយចំណែកឯភាសាអង់គ្លេសដែលមាននៅក្នុងសំណុំរឿងគឺមានលេខ 00345917 ដល់ 00345918 ។ សូមអរគុណលោកប្រធាន ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** (បានៗហើយ ដកចេញសិនទៅ) ឈ្មោះ លោកថាឈ្មោះ ឈឿង ភាំ ឈ្មោះអ៊ីចឹងត្រឹមត្រូវទេ ឈ្មោះ ភាំ អ៊ីចឹង ត្រឹមត្រូវទេ? ពីព្រោះអក្សរខ្មែរដូចមិនមែនឈ្មោះ ភាម់ ទេ ។

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន មិនមែន ឈឿង ភាម់ ទេ ឈឿង ភាំ, ឈឿង ភាំ, (ភ ដាក់ ១ំ) ។

[១៣:៥៧:៣៧]

**ស៖** អ៊ីចឹងឈ្មោះគាត់នេះ ឈ្មោះ ឈឿង ភាំ អ៊ីចឹងអេ៎ មិនមែន ឈឿង ជុំ ទេ? ឥឡូវឈ្មោះដើម អាហ្នឹងឈ្មោះបងប្អូនជីដូនមួយ ឈ្មោះដើមឈ្មោះអីដែលវានៅស្រុកដែលគេហៅនោះ ឈ្មោះអី?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន ឈ្មោះ ឈឿង ភាំ ទីលំនៅរបស់គាត់គឺភូមិគោកឫស្សីខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ឈ្មោះ គាត់ គឺឈ្មោះ ឈឿង ភាំ ។

**សៈ** គាត់ត្រូវជាបងប្អូនជីដូនមួយរបស់លោកហ្នឹង ជីដូនមួយខាងណា? ខាងឪពុក ឬក៏ខាងម្ដាយ?

**ឆៈ** ជម្រាបប្រសាសន៍ គឺខាងម្ដាយ ។

**សៈ** ឯកសារអំមិញដែលលោកយកមកបង្ហាញហ្នឹង តើឯកសារហ្នឹងដកចេញ យកចេញពីណាមក?

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះគឺមេធាវីរបស់ខ្ញុំបានយកឲ្យខ្ញុំ ។ ខ្ញុំបានឲ្យមេធាវីខ្ញុំស្រាវជ្រាវយកពីស-២១ គុកទួលស្លែង ។

**សៈ** ចុះប្រពន្ធរបស់លោក ឈ្មោះអ្វីដែរ?

**ឆៈ** ប្រពន្ធរបស់ខ្ញុំគឺឈ្មោះ ពិន លីន ឈ្មោះបដិវត្តន៍គឺ ពិន លាប ។

**សៈ** ហើយ ពិន លាប ហ្នឹងមានទំនាក់ទំនងយ៉ាងម៉េចជាមួយហ្នឹងអង្គហេតុចោទប្រកាន់ចំពោះជនជាប់ចោទ? គាត់ជាជនរងគ្រោះនៅកន្លែងណាដែរ? ហើយគាត់សព្វថ្ងៃរស់រានមានជីវិតដែរឬទេ?

[១៤:00:00]

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន! ចំពោះប្រពន្ធរបស់ខ្ញុំ គឺតាមការដែលដឹងគឺថាការចាប់ខ្លួននោះក៏មិន ក៏ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំកាលនោះ ខ្ញុំទៅស្វាយរៀងបាត់ហើយ ។ ហើយនេះបកមកវិញ គឺទើបទទួលដំណឹងថា ប្រពន្ធរបស់ខ្ញុំគេចាប់ខ្លួនបាត់ទៅហើយ ក៏ប៉ុន្តែមិនដឹងជាទៅស-២១ ឬទៅកន្លែងណានោះទេ? ប៉ុន្តែការសន្និដ្ឋានរបស់ខ្ញុំ គឺថាព្រោះសម័យសន្តិសុខពេលនោះ គឺមិនមានកន្លែងណាដែលឆ្ងាយទេ គឺមានតែស-២១ ឬព្រៃសតែប៉ុណ្ណោះ ។

**សៈ** លោកដឹងថា គាត់ស្លាប់ ឬរស់ទេ?

**ឆៈ** បាទ,ជម្រាបប្រសាសន៍លោកប្រធាន! ការបែកបាក់ក៏យូរបាត់ទៅហើយ ក៏ប៉ុន្តែខ្ញុំវាឃើញថា ការស្រាវជ្រាវរកប្រវត្តិរូបក៏មិនឃើញ ឯរូបថតក៏ខ្ញុំមិនបានរកឲ្យបានដិតដល់ដែល ព្រោះថាទីលំនៅវាឆ្ងាយ ។ ហេតុដូច្នេះ រូបថតនៅស-២១ ខ្ញុំរកបានតែមួយឆាបទេ គឺមិនបានដើររវែងឆ្ងាយទេ ។ ហេតុដូច្នេះ គឺខ្ញុំអាចសន្និដ្ឋានបានថា ស្លាប់ ព្រោះការបែកបាក់នេះ គឺយូរដែរហើយ គឺអត់ដែរបានជួបមុខគ្នាទេ ។

**សៈ** អ៊ីចឹងបានន័យថា កន្លងមកលោកបានដើររកឯកសារនៅមន្ទីរ ពាក់ព័ន្ធនឹងមន្ទីរស-២១ ដែរ ប៉ុន្តែដើររកបានតែមួយរយៈទេ រកមិនឃើញទេ ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ, អ៊ីចឹងមែន ។

**សៈ** ចុះខ្លួនលោកផ្ទាល់ តើលោកមានការពាក់ព័ន្ធយ៉ាងម៉េចទេ? ជាមួយនឹងមន្ទីរសន្តិសុខស-២១? ឬក៏អង្គហេតុដែលបានចោទប្រកាន់ទៅចំពោះជនជាប់ចោទនាពេលនេះ?

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺនៅក្នុងអំឡុងពេលដែលបាត់ខ្លួនប្រពន្ធខ្ញុំបាទទៅ ខ្ញុំក៏បានវិលត្រឡប់មកពីស្វាយរៀងវិញ រស់នៅក្នុងកងពល៣១០ បន្តទៅទៀតនៅក្នុងឋានៈជាអ្នកធ្វើបញ្ជីស្ថិតិនៅក្នុងកងពល ដែលមានឈ្មោះ ទុយ ជាប្រធាន ។ ដូច្នេះ គឺថា--

**សៈ** ឈប់សិន ឥឡូវចង់ដឹងថា តើលោកមានការពាក់ព័ន្ធយ៉ាងម៉េចសិន? ពាក់ព័ន្ធយ៉ាងម៉េចជាមួយនឹងមន្ទីរសន្តិសុខស-២១? ហើយពាក់ព័ន្ធនឹងអង្គហេតុណាដែលមានការចោទប្រកាន់ទៅលើជនជាប់ចោទ ដូចជាអង្គហេតុដែលកើតឡើងនៅមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញ ឬក៏នៅព្រៃស ដែលហៅថា មជ្ឈមណ្ឌលអប់រំកែប្រែសាជាថ្មីព្រៃស ដែលជាសាខារបស់មន្ទីរស-២១ ដែរនោះ? នេះជាសំណួរ ថាលោកពាក់ព័ន្ធនៅកន្លែងណា? ហើយការពាក់ព័ន្ធនោះ គឺអំពើរបស់គេប្រព្រឹត្តចំពោះលោកយ៉ាងដូចម្តេច? ដែលលោកអះអាងថាមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ចំពោះជនជាប់ចោទនោះ ។

[១៤:០៣:២៦]

**ឆៈ** បាទ, ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន! គឺពាក់ព័ន្ធទៅលើអង្គហេតុដែលគេចាប់ខ្លួនខ្ញុំផ្ទាល់ នៅឆ្នាំ១៩៧៨ នៅវ៉ារថទេះភ្លើងយើងទួលគោកភ្នំពេញនេះ ។ គឺបញ្ជូនខ្ញុំមិនដឹងថា ទៅស-២១ ឬមិនដឹងទៅណាទេ ក៏ប៉ុន្តែពេលនោះការចងមុខបិទអស់ហើយ ក៏មិនដឹងថាមន្ទីរនេះ គឺស-២១ ទេ ។

**សៈ** ឥឡូវនេះលោករៀបរាប់មើល៎ អំពីដំណើររឿងនៃការដែលលោកបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ពេលគេដែលចាប់ខ្លួនលោក ហើយនឹងក្រោយមកទៀត និយាយរួម គឺរហូតដល់ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ តើជីវិតរបស់លោកហ្នឹងបានជួបប្រទះនឹងរឿងរ៉ាវយ៉ាងដូចម្តេចខ្លះ? លោកអាចនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការបានដែរឬទេ? បើបានសូមអញ្ជើញ ។

**ឆៈ** សូមជម្រាបប្រសាសន៍លោកប្រធាន! អង្គសវនាការទាំងមូលគឺសូម-- ចំពោះរូបខ្ញុំផ្ទាល់ពីឆ្នាំ១៩៧៥ គឺខ្ញុំបានចូលមករំដោះទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥ ។ គឺបានចូលរួមការបោសសម្អាតនិងរៀបចំទីក្រុង និងជម្លៀសបងប្អូននៅទីក្រុងចេញពីទីក្រុងភ្នំពេញ ។ ពេលនោះ ក៏បងប្អូននៅទីក្រុងភ្នំពេញកាលចេញអស់ ក៏ខ្ញុំបានរៀបកងពលជាថ្មីនិងទ័ពជាថ្មីនៅភ្នំពេញ ដែលមានពេលនោះគឺនៅ

ក្រោមការគ្រប់គ្រងរបស់ភូមិភាគឧត្តរទិស ដែលមានលោក កុយ ធួន ជាប្រធានភូមិភាគ ។ ហើយរហូតមកបានរៀបចំទ័ពជាកងវរសេនាធំ៣១០ ខ្ញុំក៏បានរស់នៅក្នុងកងពិការ "ក៤" គេដកដាក់ពិការ "ក៤" នៅភូមិឃ្មួញ បឹងបាយ៉ាប យើងភ្នំពេញនេះ ។ រស់នៅជាមួយនោះ គឺមានឈ្មោះ ទី, ឈ្មោះ គីម និងឈ្មោះ ហេង គឺជាប្រធានក្តាប់កងពិការ "ក៤" រហូតមកខ្ញុំក៏នៅពេលនោះ គឺខ្ញុំនៅជាអ្នកក្តាប់ស្ថិតិជាជំនួយការរបស់វរសេនាតូច "ក៤" ដែលមាន ទី ជាប្រធាន ។ គឺក្តាប់ធ្វើបញ្ជីស្ថិតិ ស្នាមប្រវត្តិរូបរបស់អ្នកពិការទាំងអស់ និងលទ្ធផលផ្សេងៗដែលធ្វើបាន ។

[១៤:០៧:០២]

នៅឆ្នាំ១៩៧៦ ទើបពេលនោះក៏មានការចាប់ខ្លួន កុយ ធួន និងឈ្មោះ អឿន ប្រធានកងពល៣១០ ហើយនិងឈ្មោះ វឿន ជាអនុប្រធានកងពលនោះអស់ទៅ ក៏បានឈ្មោះ ទុយ មកពីភូមិភាគនិរតីមកក្តាប់នៅកងពល៣១០ បន្តទៀត ហើយខ្ញុំក៏បានរស់នៅនឹង "ក៤" មួយរយៈទៅ ក៏គេដកខ្ញុំមកនៅក្នុងមន្ទីរកងពលជាមួយ ទុយ នេះ ហើយនិង ជាង ដោយក្តាប់ខាងធ្វើប្រវត្តិរូបនិងស្ថិតិដដែល ។ ដែលជាជំនួយការខាងស្ថិតិនៅកងពល ដែលមាន មិត្តជាង ជាប្រធាន ។ បន្ទាប់មកទៀត ខ្ញុំមិនសូវបានចាំច្បាស់ដែរ ព្រោះទៅយូរដែរហើយ ហើយកន្លងមកក៏បានដកខ្ញុំទៅនៅកប់ស្រូវ នៅកប់ស្រូវមួយរយៈខ្លីទេប្រហែលជាម្ភៃថ្ងៃ ។ នៅកប់ស្រូវនោះក្តាប់អង្គភាពតូចមួយ គឺគេហៅថា មិនទាន់ជាមានអង្គភាពលេខត្រឹមត្រូវទេ ពេលនោះ គឺគេដាក់អង្គភាពតាតា សម្រាប់ដាំដំណាំនៅកប់ស្រូវ ។ រយៈប្រហែលជាដប់ប្រាំ ឬក៏ម្ភៃថ្ងៃតែប៉ុណ្ណោះទេ ក៏បានដកខ្ញុំមកមន្ទីរកងពលវិញ ទើប ទុយ បញ្ជូនខ្ញុំទៅ៣១៧ (អ៎!សុំទោស) អ៊ូ!៣១៧ ។ ពេលនោះ ខ្ញុំក៏បានជួបនឹងបងជីដូនមួយរបស់ខ្ញុំ គឺឈ្មោះ ឃឿង ភាំ ហៅ ពិន ណេត នេះឯង គឺជាប្រធានកងអនុសេនាធំ ហើយនិងឈ្មោះ ហាម ប៉ូ ហៅ ហាម ហួន ជាអនុប្រធាន ។ ពេលនោះ ការរៀបចំកង៣១៧នោះ គឺកងថ្មីទេ គឺជា គេដាក់ឈ្មោះថា ៣១៧ គឺជាកងវិន័យ សំខាន់បំផុត គឺថា៣១៧ ដែលចេញពីកងវិន័យនេះហើយ គឺមានតែទៅព្រៃស ឬក៏ស-២១ អ្នកណាដែលប្រព្រឹត្តខុស ។ រហូតមកខ្ញុំនៅបានយូរទៅទើបចាប់ខ្លួនឈ្មោះ នៅ-- ឃឿង ភាំ នៅឆ្នាំ៧៧ បងជីដូនមួយខ្ញុំនោះ គឺនៅឆ្នាំ៧៧ ហើយនិង ហាម ប៉ូ មួយទៀត គឺនៅឆ្នាំនោះជាមួយនឹងគ្នាដែរ ។

ពេលដែលចាប់បងជីដូនមួយខ្ញុំបាត់ទៅ ក៏ខ្ញុំក៏នៅជាបណ្តោះអាសន្នគេហៅថា នៅក្តាប់កងគាត់ជាបន្ត មួយរយៈខ្លីក៏បានដកខ្ញុំទៅនៅកំពង់ឆ្នាំង គឺព្រលានយន្តហោះថ្មី ដែលធ្វើនៅកំពង់ឆ្នាំង ។ សម័យនោះ គេដាក់ព្រលាន-- ធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង ។ ខ្ញុំធ្វើជាអ្នកវាស់ស្ទង់ដី សម្រាប់ជីកកកាយ

ដើម្បីឲ្យស្មើដីនៅវាលវង់កំពង់ឆ្នាំង ។

តាមខ្ញុំចាំ ភ្លេចខ្លះ ខ្លះគឺថា គឺថាវារំលងពេលវេលាយូរ ហើយសុខភាពក៏មិនសូវចាំដែរ សព្វថ្ងៃឈឺច្រើនផង ភ្លេចខ្លះ ។ សូមជម្រាបប្រាប់ជូនលោកប្រធាន! គឺពេលនោះពួកខ្ញុំបាន-- សម័យ ខ្ញុំបានវិលត្រឡប់មកវិញ គេដកមកនៅជាមួយនឹង ទុយ ដដែល ក៏គេបានរៀបចំឲ្យខ្ញុំមានគ្រួសារនៅឆ្នាំមួយពាន់ប្រាំបួនរយ ដើមឆ្នាំ-- ចុងឆ្នាំ១៩៧៧ ។ គេរៀបគ្រួសារនៅហ្នឹង ជិតវត្តភ្នំនេះឯង គឺបានកសាងគ្រួសារចំនួនប្រហែលជាបីខែបន្តិច ក៏បានបែកគ្នាទៅ ។ គេក៏ដកទៅនៅអង្គភាពគេ ខ្ញុំក៏នៅអង្គភាពខ្ញុំទៅ គឺពេលនោះការជួបជុំគ្រួសារមានរយៈកំណត់ និងមានវិន័យត្រឹមត្រូវក្នុងរយៈពេលថា មួយខែ ឬក៏កន្លះខែ គេឲ្យជួបម្តងៗតែបីថ្ងៃទេ ។ ពេលនោះខ្ញុំក៏ដកទៅស្វាយរៀងបាត់ទៅ ទុយ ហ្នឹង អ្នកបញ្ជូនទៅក្នុងកងពល៣១០ដែរ ក៏ប៉ុន្តែ ដកចម្រុះ ។ សម័យស្វាយរៀង តាមព្រំប្រទល់ហ្នឹង គឺមានការវិវាទគ្នានៅតាមព្រំដែន ។

[១៤:១១:៤៧]

គេទៅនោះខ្ញុំនៅជាកង នៅក្តាប់តេអូទេ គឺមិនបានទៅសមរភូមិទេ គឺនៅកាន់ខាងតេអូ ជាមួយនឹង ជាង ។ កាលនោះ ខ្ញុំមិនបានក្តាប់ថា គ្រួសារខ្ញុំនេះត្រូវគេចាប់ខ្លួននៅឆ្នាំ៧៧ ចុងឆ្នាំ-- អ៊ំ៧៨ ហើយ ចូល៧៨ ហើយ ។ ខ្ញុំបកមកវិញនោះ គឺវាគេចាប់ចុងប្រហែលជាចុង៧៧ ហើយ ពួកខ្ញុំរៀបការបានតែបីខែទេ គឺគេចាប់ខ្លួន ។ ពេលដែលចាប់ខ្លួននោះ គឺគ្រួសារខ្ញុំមានទម្ងន់ចំនួន យើងស្មានទៅប្រហែលជាមួយខែទេ គឺតាមរយៈការដឹង គឺក្នុងពេលជួបម្តងៗ គឺតែងតែនិយាយ ធម្មតាគ្រួសារគេតែងតែប្រាប់គ្នាទម្ងន់ប្រហែលជាមួយខែ ក៏បាត់ខ្លួនរហូតទៅ ។ ពេលកន្លងមកទៀត ខ្ញុំក៏-- គេដកមកវិញ គឺនៅឆ្នាំ៧៨ ខ្ញុំមករស់នៅក្នុងអង្គភាពដដែល ក៏ប៉ុន្តែការចេញបំពេញការងារនៅទួលគោក ជិតវ៉ារទេះភ្លើង ជាទូទៅតែងធ្វើការងារនៅទីនោះរហូត ។

ពេលដែលបាត់ប្រពន្ធយូរពេកខ្ញុំក៏បានទៅអង្គភាពរបស់គេ គឺកាត់ដេរ គេគឺជានារីកាត់ដេរនៅកងពល៣១០នេះឯង ខ្ញុំបានទៅសួរ ។ ពេលខ្ញុំទៅដល់ក៏បាត់គ្រួសារខ្ញុំទៅ គឺឃើញតែនារីផ្សេងមកពីភូមិភាគនិរតីគេក្តាប់នៅទីនោះ ។ កាលនោះ ក៏ខ្ញុំមិនស្គាល់ថានារីនោះជាអ្នកណា ព្រោះខ្ញុំមិនបានសួរគេដែរ ទើបនារីមួយដែលស្គាល់ខ្ញុំ គឺឈ្មោះ មិត្តចាប ។ មិត្តចាប ទើបនឹងប្រាប់ខ្ញុំថា "បងគ្រួសារបងឯងនេះគេស្មើទៅរៀនខាងលើហើយ មិនដឹងទៅរៀនឯណាទេ" ខ្ញុំក៏មិនចាប់អារម្មណ៍ថា គេចាប់ទេ ។ ទើបនឹងមកដល់ពេលដែលគេចាប់ខ្លួន បានខ្ញុំដឹងថា ឱ!គ្រួសារខ្ញុំគេចាប់ខ្លួនពេលនោះឯង ។

[១៤:១៤:០៣]

ពេលដែលចាប់ខ្លួនខ្ញុំបន្ទាប់មកទៀតនោះ ក៏ចាប់នៅវ៉ារទេះភ្លើង យើងទូលគោកនេះឯង ។ ពេលនោះ ខ្ញុំកំពុងបំពេញការងារនៅពេលជិតចប់ម៉ោងធ្វើការហើយ ខ្ញុំក៏ឡើងមកឡើងប្រហែលជាម៉ោងប្រាំកន្លះ ជិតប្រាំមួយទៅហើយ ។ ពេលនោះ គឺឡាន គេហៅថា ឡាំបាតាកង់បី បានបរទៅទីនោះ ខ្ញុំកំពុងតែឡើងពីធ្វើការមកក៏ជួបនឹងឡានហ្នឹង គេឡើងមកក៏ភ្ជង់បណ្ដោយទៅគ្នាគេបីនាក់ ។ អ្នកបើកហ្នឹងមួយ អ្នកចាប់នោះពីរ គឺពេលនោះខ្ញុំក៏មានការរន្ធត់ដែរ ព្រោះខ្ញុំមិនដឹងថា មានកំហុសអ្វីផង ។ ចាប់ខ្ញុំចូលក្នុងនោះទៅក៏គេចងខ្ញុំ ក៏ប៉ុន្តែគេចងមិនខ្លាំងទេ គឺចងតិចទេ ចងល្មមតែលើកដៃបន្តិចបន្តួចទៅ ។ ឯឡាននោះឃ្លុបជិតអស់អត់មានមើលខាងណាឃើញទេ បិទជិតទាំងមុខទាំងក្រោយ ។ អាកញ្ចក់ខាងមុខ ដែលពួកអ្នកបើកនោះ ក៏ឃើញបិទ ខាងក្រោយក៏បិទ ចំហៀងក៏បិទអស់ ។ ខ្ញុំអង្គុយកណ្ដាលអ្នកយាមនៅសងខាងពីរនាក់ ម្ខាងម្នាក់ ។ តែមិនដឹងថាទៅឆ្វេង ឬក៏ទៅស្ដាំទេ ព្រោះខ្ញុំមើលវាមិនឃើញដែរ គេអង្គុយភ្ជង់ជាប់ ។ ខ្ញុំអង្គុយសណ្ដូកជើងកណ្ដាលហ្នឹងទៅ ។ រហូតមកដល់កន្លែងមួយ គឺជាកន្លែងនោះ ក៏ខ្ញុំមិនថាកន្លែងណា គឺនៅចម្ងាយប្រហែលជាស្មាន ប្រហែលជាមួយរយយម៉ែត្រ បើស្មានទៅមួយរយម៉ែត្រ គេចាប់ចងមុខខ្ញុំភ្លឹប ជាប់ជិតបាត់ ។ ឡានបើកប្រហែលជាមួយរយម៉ែត្រ មិនយូរទេ នៅពេលទៅដល់ទៅ ឮឡាន អាឡាំប៉ាតានេះឈប់ងក់ទៅ ក៏ឮទ្វារផ្ទះនេះ ក្រាកៗទៅ គេរុញខ្ញុំចូលប្លុកទៅ ។ ខ្ញុំក៏មិនដឹងថា ទីនោះ វាមានគ្នាប៉ុន្មាននាក់ទេ ព្រោះមើលមិនឃើញ ។ តាមស្មានផ្ទះនោះបិទជិត គេទាញទ្វារបិទ ឮសូរឈឹបទៅវិញទៅ ក៏គេឲ្យខ្ញុំឈរមួយសន្ទុះ ភ្ជង់ជាប់ ស្រាយចង ចងសាថ្មីម្ដងទៀត គឺរឹតខ្លាំងមែនទែន ។ រឹងខ្លាំងរហូត បិទមុខរហូត ទើបបានគេដាក់ខ្នោះច្រវាក់ជើង ហើយក៏គេបណ្ដើរចេញទៅ ។ តាមសន្នឹកជើងអ្នកបណ្ដើរ គឺមានតែពីរនាក់ទេ ដើរចូលទៅ ប៉ុន្តែមិនដឹងជាចូលតាមផ្លូវណាទេ ព្រោះខ្ញុំអត់ដឹងដែរ ព្រោះមើលវាមិនឃើញទេ ។ ដោយការដឹកនឹងខ្សែចងក ដឹកដូចគោអ៊ីចឹង ។

ចូលទៅដល់ក្នុងបន្ទប់ឃុំឃាំង គឺគេដាក់ខ្នោះ ដាក់ខ្នោះជើង (សូមទោស) សូមថយបន្តិច ។ ចូលទៅ គឺខ្ញុំក៏មិន ដូចជាមិនបានថតទេ ព្រោះខ្ញុំទៅពេលនោះ ដូចជាមិនឃើញថតទេ ។ មិនបានឃើញថត ហើយមិនបានធ្វើអ្វីទាំងអស់ពេលចូលទៅដល់កន្លែងឃុំឃាំងតែម្ដង ។ ដល់ដាក់ខ្នោះជើង ស្រាយដៃ ដាក់ខ្នោះជើងរួច ស្រាយដៃទើបគេស្រាយមុខចេញ ។ ពេលដែលស្រាយមុខចេញហ្នឹង ក៏ខ្ញុំបានឃើញ ខ្ញុំអើតមើលឆ្វេង ស្ដាំ ទៅ ប៉ុន្តែស្រាយមុខដាក់ខ្នោះរួចទៅហើយ គេបិទទ្វារទៅវិញ ខ្ញុំអើតឆ្វេង ស្ដាំ ឃើញឈ្មោះ យឹម យ៉ាវ មួយគឺនៅអង្គភាពជាមួយខ្ញុំពីដើមនោះ នៅ៣១៧ដែរ គឺនៅទីនោះជាមួយ

គ្នា ។ ប៉ុន្តែ គេនៅកៀនជញ្ជាំង ខ្ញុំនៅដូចគេ ម្ខាងម្នាក់ មើលគ្នាឃើញ ក៏ប៉ុន្តែមិនអាចនិយាយគ្នាបានទេ នៅពេលនោះ ។ យឹម យ៉ាវ គឺមើលអត់យល់ទេ គឺស្គមមែនទែន ។ ខ្ញុំក៏មានវន្ទត់ចិត្តពេលនោះឯង ។

[១៤:១៨:០៧]

រហូតបានដល់បីថ្ងៃ គឺដាក់ខ្ញុំជាប់ ដោយអត់មានខោអាវវែងទេ អាវក៏អត់ ខោក៏មាន គឺខោខ្លី តែមួយប៉ុណ្ណោះ ។ អស់រយៈពេលបីថ្ងៃ គឺគេមិនទាន់បានធ្វើអ្វីទេ បីថ្ងៃកន្លងមក ទើបគេចាប់ផ្ដើម អង្គរក្សខាងការពារគុក គេបញ្ចេញខ្ញុំទៅ គឺដាក់ច្រវាក់ជើងដដែល ដោះខ្នោះជើងចេញ គេដាក់ច្រវាក់ ។ ហើយគេចងខ្ញុំបិទមុខ បណ្ដើរចេញទៅ ។ តែខ្ញុំមិនដឹងថា ដោយងងឹត គឺប្រហែលជាអគារ១ផ្ទាល់ដី ហើយ ព្រោះថាប៉ះជើងតែបន្តិចមកចុះដល់ដី គឺដើរដីស្មើរហូត ។

កន្លែងសួរចម្លើយ ខ្ញុំមិនដឹងថាកន្លែងនោះជាកន្លែងណាដែរ ពីព្រោះថាបិទមុខអស់ហើយ គឺអត់មើលឃើញទេ គេដឹកចូលទៅ គេបិទទ្វារឈឹបទៅ ។ បើនៅក្នុងនោះ តាមខ្ញុំស្មាន គឺមានតែពីរនាក់ទេ ការសួរចម្លើយខ្ញុំ គឺមានតែពីរនាក់ទេ មុនដំបូងទាំងអស់គឺមានតែពីរ ។ គឺមានតាមការគេហៅគ្នាគេហ្នឹង គឺខ្ញុំអាចចំណាំបានថា គេមានមួយ គឺឈ្មោះ ហ៊ មានមួយ គឺឈ្មោះ សេង គេបានហៅគ្នាគេ ប៉ុន្តែខ្ញុំមិនឃើញមុខគេថា ហ៊ នោះយ៉ាងម៉េច? សេង នោះយ៉ាងម៉េច?ទេ ។ បានសួរចម្លើយ គេចងខ្ញុំរួច ឲ្យចង--ព័ន្ធស្លាបសេក ចងដៃ ត្រឹមកដៃទៅក្រោយ ព័ន្ធទៅក្រោយទៅបានគេចងជើង គេឲ្យដេកផ្កាប់មុខ ទើបគេសួរខ្ញុំថា “មិត្តឯងឆ្លើយប្រាប់អង្គការឲ្យត្រង់ទៅចុះ កុំឲ្យវាវែងឆ្ងាយ គេនឹងដោះលែងអ្នកឯងទៅវិញ ឆ្លើយត្រង់គេដោះលែងវិញហើយ” ។ ខ្ញុំក៏មិនដឹងថាឆ្លើយយ៉ាងម៉េចទេ ព្រោះថាមិនដឹងជាខ្ញុំពាក់ព័ន្ធជាមួយអ្នកណាផង គឺធ្លាប់តែនៅបំពេញការងារជូនអង្គការរហូត តាំងពីឆ្នាំមុនឆ្នាំ១៩៧៥ រហូតមកដល់ ១៩៧៥ រហូតដល់មក៧៧-៧៨ ខ្ញុំមិនដែលទៅពាក់ព័ន្ធជាមួយអ្នកផង ហេតុអ្វីបានខ្ញុំមានទោស ។ ទើបមិត្តមួយនោះ ខ្ញុំមិនបានមើលមុខទេ ប៉ុន្តែឮតែសូរ គេខ្សឹបប្រាប់គ្នាគេថា “មិត្តឯងយកនែ៎ ខ្សែតី នោះមកឲ្យឯង” ខ្ញុំថា “អឺ!ដល់រឿងហើយ” ។ ភ័យដែរខ្ញុំ ព្រោះផ្កាប់មុខ មានរើណារួច ព្រោះចងជាប់ដី ផ្កាប់មុខនឹងដី ទាញដាក់យកម្ដង ឆាំង ឆាំងហើយ ឆាំងទៀត រើទាល់តែទន់ខ្លួន ។ ខ្ញុំផ្សាអស់ហើយ ខ្នង ។ ហេតុដូច្នេះ ការធ្វើនេះ គឺមានពីរនាក់ ដល់គេធ្វើរួចអស់ចិត្ត អស់ចង់ ក៏គេទៅអង្គុយនៅកៅអីទៅ ឯមិត្តសេង ឬក៏ ហ៊ គេប្រាប់ថា “អាសេង ឯងវ៉ៃទៀតទៅ មិត្តសេង ឯងវ៉ៃម្ដងទៅ” ។ សេង ក៏ទាញ រំពាត់ ខ្សែតី ដដែលហ្នឹង ដាក់ទៅ ដាក់រហូតសឹងតែដាច់ខ្សែតីអស់ ។ ទើបបាន ហ៊ គេថា “សេង បង ខាងកើតគាត់អញ្ជើញមក” ។ ខ្ញុំមិនដឹង បងខាងកើតណាផងខ្ញុំឮតែបងខាងកើត ព្រោះខ្ញុំនៅនឹងដី មាន

បានអើត សូម្បីតែក្រឡេកភ្នែក មិនប៊ានមើលផង ។ គាត់ក៏ដើរចូលមក គាត់មិនបានធ្វើអ្វីទេ គាត់ដើរទៅអង្គុយទៅ ។ ខ្ញុំក៏ឮសម្រឹបជើង គេទាញកៅអី ទៅអង្គុយទៅ ខ្ញុំក៏មិនដឹងថា បងខាងកើតហ្នឹង ឈ្មោះអ្នកណា ព្រោះខ្ញុំអត់ស្គាល់ទេពេលនោះ ។

[១៤:២១:៥១]

សួរអស់ចិត្ត អស់ចង់ ក៏សេង នោះ ក៏បានវ៉ៃខ្ញុំបន្តទៀត វ៉ៃរួចទៅ ខ្ញុំទន់ខ្លួនលែងដឹងអ្វីទាំងអស់ ហើយវង្វេងអស់រលីងឈឹង ។ វ៉ៃរួច ខ្ញុំក៏ វាបាត់មាត់ បាត់ក លែងនិយាយ លែងអ្វីទាំងអស់ វាស្មារតីនៅមាន ក៏ប៉ុន្តែដូចវិញ្ញាណសឹងបាត់ខ្លះ ព្រោះអស់ពាក់កណ្តាល ការឈឺចាប់ ។ រហូតវ៉ៃអស់ចិត្តអស់ចង់ ដូចខ្ញុំមិនដឹងឆ្លើយថាម៉េច នេះជាវគ្គទីមួយ ។ ហើយបងខាងកើត គាត់អង្គុយក៏មិនយូរដែរ គឺអង្គុយប្រហែលជាដប់ប្រាំ ទៅម្ភៃនាទីទេ គាត់ក្រោកឡើងក៏ ខ្ញុំឮដែរ “ហ៊ឺស!” មួយម៉ាត់ មិនដឹងជាគាត់ធាក់ខ្ញុំ ឬក៏មិនដឹងអ្នកណាធាក់ទេ ក៏ប៉ុន្តែតាមខ្ញុំស្មាន ប្រហែលជាគាត់មែន ក៏មិនដឹង ព្រោះថាខ្ញុំមិនបានចាប់អារម្មណ៍ទេ ព្រោះខ្ញុំស្មារតី វាវង្វេងអស់ទៅហើយ ឮសូរតែមួយជើងម៉ុំងដាក់ក្បាលទៅ ក៏ហ៊ឺស ម៉ុំងដើរទៅបាត់ទៅ រហូតលែងមកវិញបណ្តោយ ។ នេះបានថា ខ្ញុំមិនអាចសន្និដ្ឋានពេលនោះ វិញ្ញាណរបស់ខ្ញុំបាត់ខ្លះទៅហើយ ។

រហូតមកដល់យកខ្ញុំ គេវ៉ៃរួចអស់ចិត្ត អស់ចង់ទៅ ក៏គេយកខ្ញុំមកដាក់វិញ គឺមិនមែនដាក់កន្លែងដដែលនោះទេ គឺដាក់នៅក្នុងបន្ទប់មួយៗ ដែលមានបន្ទប់គរឥដ្ឋ ដែលខ្ញុំបានទៅឃើញនៅហ្នឹងស-២១ ពេលដែលដឹកទៅហ្នឹង មិនដឹងថាដឹកដល់បន្ទប់នោះទេ ។ ប៉ុន្តែទៅដល់ ពេលគេស្រាយមុខចេញ ទើបបានដឹងថា អូ៎! បន្ទប់នេះ គេគរឥដ្ឋ ដែលមានទទឹងប្រហែលជាមួយម៉ែត្រ លើសតិចតួច បណ្តោយប្រហែលជាពីរម៉ែត្រជាង ។ គេនៅបន្ទប់តែឯង ដាក់ដោយឡែក ដោយមានដាក់ច្រវាក់ជើងសងខាងឯដៃអត់មានដាក់ទេ ។ នៅទីនោះ គឺមានកាដុង កាដុងទឹកសម្រាប់នោមនោះ ប្រហែលជា បើវាល់ទៅប្រហែលជាបី ទៅបួនលីត្រ និងកែសគ្រាប់មួយសម្រាប់បត់ជើង ។

[១៤:២៤:០០]

ខ្ញុំក៏រស់នៅទីនោះដោយការស៊ីចុក ក៏មានពេលវេលាគេ ម៉ោងមួយថ្ងៃ មានតែពីរដងទេ គឺពេលព្រឹកម៉ោងដប់មួយ ឬក៏ម៉ោងដប់ពីរ មិនទៀង ។ តាមខ្ញុំស្មានទម្រាំតែវា គឺយូរណាស់ ទម្រាំបានពេលហូបម្តងៗ គឺបបរតែមួយចានចង្កឹះ រាវៗ ឆ្អែតក៏ដោយ មិនឆ្អែតក៏ដោយ គឺអស់ប៉ុណ្ណឹងឯង ។

សូមជម្រាបលោកប្រធាន! គឺខ្ញុំរស់នៅក្នុងបន្ទប់តែម្នាក់ឯងហ្នឹង អស់រយៈពេលមួយសប្តាហ៍

ទើបគេចាប់ផ្ដើមបន្ដជាវគ្គទីពីរ វគ្គទីពីរទៀតហ្នឹង ខ្ញុំគេដឹកទៅគេដាក់ច្រវាក់ដដែល គេបិទមុខដដែល ។ ទៅដល់វគ្គទីពីរហ្នឹង ខ្ញុំវានៅពេលនោះសន្លប់ធំមែនទែន ។ ក៏ប៉ុន្តែ សួរចម្លើយទៅអ្នកដដែល អត់មានអ្នកណាទៀតទេ គឺមានតែឈ្មោះ ហ៊, សេង តែពីរនាក់ប៉ុណ្ណឹងឯង ។ ដល់វគ្គក្រោយ បងខាងកើតអត់បានទៅទេ គាត់បាត់មុខរហូតតាំងពីវគ្គទីមួយមក រហូតដល់អត់ដែលឃើញមុខគាត់ទេ ខ្ញុំក៏មិនបានចំណាំថា អ្នកណាទេ គឺបងខាងកើតឮសួរគេហៅវាទៅ ខ្ញុំថាបងខាងកើតអ៊ីចឹងទៅ ។ ប៉ាន់ក្នុងចិត្តថា បងខាងកើតមានទទួលខុសត្រូវខ្ពស់ជាងគេហើយនៅស-២១ ។ សូមជម្រាបថា នៅពេលនោះ ខ្ញុំមិនបានដឹងថា មន្ទីរស-២១ គឺសន្តិសុខទួលស្លែងនោះ ជាមន្ទីរស-២១ ទេ ចូលទៅអត់ដឹងអីសោះ ។ វាកន្លងមក ពេលវគ្គទីពីរ គឺខ្ញុំសន្លប់លែងដឹងអ្វីទាំងអស់ ។ ពេលភ្ញាក់ខ្លួនឡើង ដែលគេសួររួចៗ គេយកមកវិញ ភ្ញាក់ខ្លួនឡើង ដឹងតែនៅក្នុងបន្ទប់ម្នាក់ឯងទៀតដដែល អាកន្លែងដដែលហ្នឹង ។

[១៤:២៥:៥៤]

សូមបន្តទៅទៀត គឺនៅក្នុងឆ្នាំ-- នៅក្នុងប្រហែលជាអំឡុងឆ្នាំ សូមជម្រាបឲ្យច្បាស់បន្តិចទៅ ព្រោះថា នៅឆ្នាំ៧៨ ដែលខ្ញុំជាប់ទោសដដែលនោះ គឺវាចុងហើយ ឃើញថាការជាប់របស់ខ្ញុំនោះ គឺរយៈពេលយូរដែរ ក៏ប៉ុន្តែតាំងពីធ្វើទារុណកម្មពីរដងមក ក៏គេមិនដែលបានធ្វើអ្វីតទៅទៀតទេ រហូតទាល់តែ ប្រហែលជាខ្ញុំមិនចាំខែថ្ងៃទេ ។ ប៉ុន្តែ ទាល់តែគេដឹកចេញ មិនដឹងជាថ្ងៃណា ខែណា ដែរ ព្រោះពេលនោះនៅតែក្នុងបន្ទប់រហូត មិនដែលបានដោះចេញទៅណាដែរ ។ ពេលនោះ គឺខ្ញុំប៉ិះនឹងស្លាប់ហើយ ព្រោះស្គមអស់រលីងហើយ នៅតែស្បែកនិងឆ្អឹងទេ ។ មានឡានគេបញ្ឈរចាំ ក៏ខ្ញុំមិនបានចាប់អារម្មណ៍ថា ឡាននោះ គេដឹកអ្នកណាដែរ គឺមកដល់ស្រាប់តែគេអូសចេញមក អ្នកទោសទាំងអស់នៅទីនោះ គឺទាំងអ្នកក្រៅ អ្នកក្នុង គេបញ្ចេញចំនួន ភាគច្រើនគេចងមុខអស់ហើយ ដៃខ្នោះ ច្រវាក់ក ជើងដាក់ច្រវាក់ ដៃចងស្លាបសេក ភ្នែកចងជាប់ អូសចេញពីបន្ទប់ឃុំឃាំងទាំងអស់ គឺឡើងឡានមិនដឹងជាឡានសេអីមសេ ឬក៏ឡានកាត់ៗចិន ស៊ីលចិន ខ្ញុំមិនដឹងដែរ ព្រោះចងមុខអស់ ។ អានោះ វាចាប់លើកដាក់លើបោះៗចូលទៅដូចជ្រូក ។ ពេលដឹកចេញទៅ ក៏ខ្ញុំមិនដឹងថា គេដឹកទៅណាដែរ ព្រោះថាវាវង្វេងវង្វាន់អស់ហើយ ព្រោះពេលនោះ វាមុខមិនដឹងជាដឹកទៅឆ្វេង មិនដឹងជាដឹកទៅស្ដាំទេ ។ ទៅប្រហែលជាយូរគ្រាន់ដែរ ព្រោះអីបើគិតទៅចង់ជិតមួយម៉ោង ពេលនោះពេលល្ងាច ដឹងតែពេលល្ងាចៗប្រហែលជាម៉ោងប្រាំមួយ ប្រាំពីរហើយ ម៉ោងប្រាំពីរយប់ គឺចេញអ្នកទោសច្រើន យប់នោះបើតាមការប៉ាន់ស្មានអង្គុយលែងចង្អៀតដែរ ប្រហែលជាសាមមិនដឹង មួយឡាន ។ ទៅដល់កន្លែងមួយនោះ គឺខ្ញុំមិនដឹងថា

កន្លែងណានោះ ជាកន្លែងណាទេ ព្រោះថាចូលទៅដល់ ដឹងថាទៅដល់ទីនោះ គឺមានផ្ទះមួយហើយ ។ ផ្ទះហ្នឹងបែបជាផ្ទះឈើទេ តាមឡើងទៅ គឺផ្ទះឈើ ។ ចូលទៅដល់ គឺចូលក្នុងបន្ទប់គឺបិទភ្លឹបៗ អ្នកទោសនៅនោះទាំងអស់នៅពេលយប់ជ្រៅ ពេលយប់ជ្រៅ ម៉ោងដប់ ប្រហែលម៉ោងដប់ ម៉ោងអីហ្នឹង ស្មានមើលទៅ ព្រោះវាយូរដែរ ។ គេបញ្ចេញម្តងពីរ ម្តងបួន ម្តងប្រាំៗ ខ្ញុំថាពួកនេះគេបញ្ចេញយកទៅក្នុងចិត្តឮសូរតែក្រោកក្រាកៗ តែភ្នែកហ្នឹងមិនបានឃើញទិសដៅអ្វីទេ ព្រោះយប់ដែរ ងងឹតដែរ ។ ប៉ុន្តែក្នុងនោះគឺហាក់បីដូចជាមិនបានដុតភ្លើង ដុតអ្វីទេមើលទៅ ដូចជាងងឹតៗ ។ ចេញទៅបាត់អស់ៗ មួយសន្ទុះយូរគ្រាន់ដែលទៅ បានឃើញមកយកទៀតៗ ទាល់តែអស់មនុស្ស ។ ឯចំណែក ខ្ញុំនៅចុងក្រោយគេបង្អស់ គឺពេលនោះ បើខ្ញុំស្មានទៅ ប្រហែលជាយប់ថ្ងៃ៦ មករាហ្នឹង ស្មានមើលទៅ ព្រោះខ្ញុំមិនដឹងថាពេលនោះវាខែថ្ងៃឆ្នាំណាដែរ ព្រោះវង្វេងនៅតែក្នុងគុករហូត មិនដែលនឹងឃើញពន្លឺថ្ងៃ មិនដែលឃើញផ្ទេង មិនដែលឃើញស្តាំ ឃើញតែក្បាលអ្នកយាមដើរទៅដើរមកៗ ។

នៅក្នុងចុងក្រោយគេ គឺប្រាំមួយនាក់ៗ ចុងបង្ហើយ គឺខ្ញុំថាពេលនេះចប់ហើយ ខ្ញុំគ្មានរស់ទេ វាសង្ឃឹមតិចណាស់ បើចង្កៀងអស់ប្រេងរលីង ជិតអស់ហើយ នៅឡឹមៗទេ វាគ្មានសង្ឃឹមទេ ។ ពេលទៅដល់ គឺមានវាងងឹតភ្នែកចងអស់ហើយ ដៃចងទៅក្រោយ ឯជើង អត់មានតែជើងទេ អត់បានចង ។ គេទាក់កដឹកទៅហ្នឹង ទាក់ក បើតាមសំរឹបជើងមនុស្សដើរ ខ្ញុំស្មានប្រហែលជាបីនាក់ទេ យកទៅវ៉ៃនោះ ។ ពេលនោះគេឲ្យលត់ជង្គង់នៅមាត់អន្លង់ ខ្ញុំទៅហើយ ខ្ញុំថាសូន្យហើយជីវិតពេលនេះ គឺអស់បានឃើញពន្លឺថ្ងៃទៀតហើយ ។ តែចៃដន្យល្អណាស់ ពេលវ៉ៃខ្ញុំជាលើកទីបី វ៉ៃអ្នកទីពីរចូលហើយ អ្នកទីបីខ្ញុំទីបី វ៉ៃទីពីរធ្លាក់ព្រឹសព្រុសបាត់ទៅ ប្រហែលជាទីបី ខ្ញុំក៏លត់ជង្គង់ស្រួលហើយនៅមាត់អន្លង់ ។ យាដំបងភឹងទៅ ខ្ញុំក៏ដូចជាភ្ញាក់ដែរ ភឹងទៅ វ៉ៃទៅមុជក្បាលផុត ទរឆ្អឹងជំនីរទឹងធ្លាក់អន្លង់គ្គុក សន្លប់ភ្លឹង ។ ឯពួកវាក៏វ៉ៃថែមមនុស្សបីនាក់ពីលើថែមទៀត សង្កត់ពីលើខ្ញុំជាប់ អត់ដឹង ។ ខ្ញុំអត់ដឹងទេពេលនោះ ខ្ញុំមិនដឹងថា ខ្ញុំស្លាប់ ឬរស់ទេ ព្រោះសន្លប់បាត់ហើយ នៅពីក្រោមខ្មោច ។ ពេលនោះសន្លប់ឡើងមួយយប់ បើតាមស្មានប្រហែលជាម៉ោងមួយម៉ោងពីរហើយ ម៉ោងពីរយប់ ។ ភ្ញាក់ដឹងខ្លួនឡើង ព្រាលខាងកើត មើលទៅព្រាងៗវង្វេងឈឹង អត់មានដឹងឯណាជើងត្បូងទេពេលនោះ ។ មិនដឹងថាជើងមិនដឹងថាត្បូងទេ វង្វេងឈឹងហើយសន្លប់ ។ ទើបខ្ញុំក្រោកឡើងក៏ដៃជាប់ចំណងអ៊ីចឹង មិនដឹងក្រោកយ៉ាងម៉េចរួច ចេះតែខំរំកិលៗពីលើខ្មោច រំកិលបម្រះៗ អាជើងខំធាក់ក្រាញ ណាស្គមផង ស្គមៗឡើងដើរសឹងដើររលំ ងាកមកបានប្រាស់ខ្លួន បានអង្គុយលូតសណ្តូកជើង ។ បានវា វាអាខ្មោចនោះវាដូចជា

ជួយទាញអាចំណងភ្នែករបូតឡើង ងើបមកឃើញខ្មោចពីលើពេញ ។ ខ្លួនខ្ញុំសុទ្ធតែឈាមឆ្អាបស្អុយ គគ្រុកពេញតែខ្លួនហ្នឹង បានងើបផុតពីខ្មោចមក ផុតមួយច្រមុះបន្តិចមក ក៏ដូចជាអស់កម្លាំងសឹងតែ សន្លប់ទៅម្តងទៀតហើយ វាស្អុយពេក ឆ្អាបឈាមផង មើលមុខខ្ញុំ ភ្នែកខ្ញុំសុទ្ធតែថ្នក់ឈាមទាំងអស់ ។ ងើបចេញមក ភ្លឺឡើងដឹងមើលតែថ្ងៃរះហើយ ពួកវាបាត់អស់ ពួកគេមិនដឹងជាទៅនោះ ហើយខ្ញុំងើប ផុតតែពីអន្លង់ក៏ផ្ទុះកាំភ្លើងក្នុងបណ្តោយ ។ តាមស្មានមិនដឹងជាផ្ទុះទីណាទេ គ្រាន់តែស្មានទៅខ្ញុំដឹង គឺ ស្មានមុនីវង្សមុនគេ ឮស្ករក្តុងៗនៅអរិយក្សត្រ ។ ពេលនោះខ្ញុំក៏បានក្រោកចេញមកពីអន្លង់មក ក៏បាន ដើមឈើនៅ ខ្ញុំដឹងថាកន្លែងនោះ វាខ្ញុំមិនស្គាល់ថា ជើងឯកដែរហ្នឹង កន្លែងនោះដែលខ្ញុំ បានឃើញដែល ភ្លឺភ្នែកហើយ ក៏អត់ជើងថា ជើងឯកទេ ទើបតែដឹងពេលក្រោយ ដែលឮបងប្អូនគេនិយាយថា ជើងឯក ជាកន្លែងប្រហារមនុស្ស កន្លែងសម្លាប់មនុស្ស ព្រោះខ្ញុំកាលនោះខ្ញុំវង្វេង ខ្ញុំមិនដែលបានដើរពីជើងឯក ហើយទៅនៅភ្នំពេញ ។ ដើរវង្វេងគិតថាពីជើងឯកទៅនោះ បើរាប់ទៅប្រហែលជាពីររយម៉ែត្រ មិនដល់ ទេ ខ្ញុំដេកមួយយប់បាត់ទៅហើយ ស្អុយខ្មោចនោះ វាស្អុយ នៅជើងឯកវាសុទ្ធតែខ្មោច ។ សូមទោសបក បន្តិចព្រោះថា ពេលនោះវាមានការភ្លេច ឯណាចំណងនៅជាប់ទេ ខ្ញុំដើរនោះតេះតះៗ ដួលផ្កាប់មុខ ក្រោយឡើងដើរតេះតះៗដួលផ្កាប់មុខ គ្រាន់តែក្រោកឈរប្រហែលជាចង់មួយម៉ោងជាងបានងើបរួច ។ បានដើមឈើធំមួយនៅនឹងជើងឯកហ្នឹងដែរ តែតាមខ្ញុំស្មានបែបមានតែជើងឯក ដើមឈើនោះសុទ្ធតែ ខ្មោចដែរ ខ្ញុំដើរលូនផង អឹផង ដើរផង វាផង តតេះតតះម្នាក់ឯងទៀត ទៅដល់ហ្នឹង គល់ឈើហ្នឹង ក៏យកដៃទៅរុះៗរហូតទាល់តែដាច់ខ្សែ ។ ទើបបានខ្ញុំស្រវាតេះតះបានឈើមួយដើរឈើច្រត់រហូតទៅ ដល់ចេក គុម្ពចេក ពេលនោះអត់មានមនុស្សទេ ស្ងាត់ឈឹងអស់ហើយ បែបជារត់ខ្មេចខ្ទីរអស់ហើយ ។ ត្រង់នោះ ដឹងថាដើមចេក មានដើមចេក ច្បារមួយមានដើមចេកច្រើន ។ ប៉ុន្តែ មិនដឹងទីណាទេ ខ្ញុំអត់ វង្វេងអស់ឈឹង អត់មានដឹងជើងត្បូងទេ ។ ហេវពេកយកដៃខំកកេរ អាមាត់ ខំកកេរ គល់ចេកនោះស៊ី ជញ្ជក់ផ្អែមៗមានកម្លាំងគ្រាន់បានដេកនៅមួយយប់ទៀត ។ រហូតមកដូចជាគុណបុណ្យលោកជួយទៅចុះ បានដើរមកដល់ផ្លាក់ទន្លេរយើង បានដឹងថា ជើងត្បូង ។ កៀកទន្លេ ដឹងជើងត្បូង ហើយខ្ញុំថា ឱ!បាន រស់ហើយពេលនេះ បានក្តារមួយបន្ទះ ប្រហែលជាពីរម៉ែត្រ គេវៃភ្ជាប់ គ្នានៅនោះឯង ក៏ខ្ញុំស្រាយបាន បណ្តែតតាមទឹកទៅ បានដើរ វាអត់សូវបានដើរទេ វាព្រោះបណ្តែតទៅ វាមានកម្លាំងគ្រាន់បន្តិចត្រជាក់ ផង រហូតមិនដឹងទៅទិសតំបន់ឯណាទេ ទឹកហូរល្ហឹមៗចេះតែ បណ្តោយៗទៅ ។

មកដល់ជ្រោយចង្វារ បានដឹងថាស្អី អានេះស្ពានជ្រោយចង្វារ ។ ហួសពីស្ពានជ្រោយចង្វារ

ប្រហែលជា១ពីរគីឡូដីបន្តិច បានជួបនឹងកងទ័ពវៀតណាម ហើយនិងខ្មែរយើងប្រហែលជាដប់នាក់ ។ ឃើញខ្ញុំ-- ខ្លះគេ ខ្លះក៏គេទៅគេស្មានថាខ្ញុំស្លាប់ទេ សូម្បីតែខ្ញុំលើកដៃក៏គេស្មាន ស្លាប់នៅទឹកដី ឃើញលើកដៃ ខ្លះគេលើកខ្ញុំដាក់លើកាណូត ។ បរទៅ គេមិនបរមកភ្នំពេញ គេបរទៅក្រោម ទៅណោះទៀត រហូតដល់ជិតសាលាលេខប្រាំ កាលនោះកំពុងតែប្រទាញប្រទង់បាញ់គ្នាសម្បើមណាស់ ឯខ្ញុំក៏ឈឺផង បានផ្ញើនឹងអ៊ំម្នាក់ គេលើកឡើងក៏ផ្ញើទុកទៅអ៊ំ គេអុំទូករកីត១ គេលើកដាក់លើទូកឲ្យគាត់យកទៅនៅថែរក្សា តែគេប្រាប់ថា គេនឹងត្រឡប់មកយកវិញ ។ ខ្ញុំបានរស់នៅជាមួយគាត់នោះឈ្មោះ អ៊ំជូ គាត់អាយុប្រហែល៦៥ ហើយពីកាលនោះ ។ គាត់បានដាក់ថ្នាំឲ្យខ្ញុំ ព្យាបាលរហូតទាល់តែខ្ញុំបានជា សម្លាកស្លាកស្នាមដែលមានរបួសបែកឈាមនោះ ក៏វាបានធូរស្រាល រហូតនៅជាមួយគាត់ចំនួនពីរខែ បានមានសាច់មានឈាមស្រួលបួល ក៏រង់ចាំមើលកងទ័ពគេទៅយកមកវិញ ។ ខ្ញុំមិនចេះឃើញទៅទេ ខ្ញុំក៏បានសុំលា អ៊ំជូ នោះក៏ទៅស្រុកកំណើតក៏មិនបានបកមកភ្នំពេញទេ គឺទៅបណ្តោយតាមផ្លូវជាតិលេខប្រាំរហូតទៅដល់បាត់ដំបង ។

[១៤:៣៧:៣០]

**ប្រធានអង្គជំនុំ៖**

បង ភោគ ខន ឥឡូវបញ្ចាក់ឡើងវិញ ហើយលោករៀបរាប់ទៅជាមានការកំសត់ណាស់ មែនទេ? ហើយជួបប្រទះនូវរឿងហេតុជាច្រើននៅក្នុងឆាកជីវិត ។ ឥឡូវនេះ យើងចង់បកក្រោយវិញថា ពេលដែលគេចាប់បញ្ជូនលោកទៅដល់កន្លែងឃុំឃាំងហ្នឹង បើកទ្វារផ្ទះក្រាក រុញទ្វារផ្ទះបិទវិញ ។

**ស៖** សំណួរសួរ ថាកន្លែងដែលគេរុញលោកចូលទៅហ្នឹងជាផ្ទះ ហើយផ្ទះហ្នឹង ផ្ទះយ៉ាងម៉េចជាផ្ទះ ល្វែង ឬក៏ជាផ្ទះជា ភូមិគ្រឹះ ហៅថា វីឡា នោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺពេលដែលគេបញ្ចូលខ្ញុំទៅនោះ ខ្ញុំមិនបានឃើញទេ ក៏ប៉ុន្តែតាមការបិទទ្វារ គឺមិនមែនជាវីឡាទេ គឺផ្ទះឈើ ប្រហែលជាឈើទេ មិនមែនជាឥដ្ឋទេ ។

**ស៖** ពីកន្លែងទ្វារដែលបើក ហើយរុញលោកចូលទៅ ទៅដល់កន្លែងឃុំឃាំងហ្នឹង លោកដើរប៉ុន្មានជំហាន ដល់កន្លែងដែលគេដាក់ឃុំលោកនោះ មានដើរទៅ មានប៉ុន្មានប្រហែលប៉ុន្មានជំហានទៅដល់កន្លែងគេឃុំឃាំង?

**ឆ៖** បាទ, ពេលដែលគេបញ្ចូលទៅក្នុងផ្ទះនោះហើយ គេចងរួច បានចេញទៅបិទមុខអស់ បើខ្ញុំស្មានប្រហែលជាម្ភៃ ទៅម្ភៃប្រាំនាទី ដើរដល់កន្លែងឃុំឃាំង ។

**ស៖** ពីកន្លែងបើទ្វារអំមិញដើរទៅកន្លែងដែលគេដាក់ឃុំឃាំងរហូតដល់ម្ភៃទៅម្ភៃប្រាំនាទីឯណោះ ដើរជាប់ ឬក៏ដើរឈប់ មានឈប់សម្រាក ដើរម្ភៃប្រាំនាទី?

**ឆ៖** បាទ, ដើរទៅ គឺវាមានការសម្រាកខ្លះដែរ ព្រោះវា ពេលដើរទៅ វាដឹកខ្ញុំទៅក៏វាអាចងងឹត ជំពប់ដួលទីណាត់ទីណែងទៅ ទម្រាំបានក្រោកឡើងបានដើរទៅទៀត ។ ខ្ញុំឃើញថា បើតាមខ្ញុំស្មាន ប្រហែលជាម្ភៃ ទៅម្ភៃប្រាំនាទី ព្រោះយូរគ្រាន់ដែរ ។

**ស៖** លោកនិយាយអំមិញថា ពេលដែលលោកចូលដល់កន្លែងនុំង គេអត់មានកន្លែងថតរូប ឬក៏ មានការដកស្រង់សួរនាំអំពីព័ត៌មានស្តីពីជីវប្រវត្តិរបស់លោកទេ ពិតអ៊ីចឹងមែនទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកប្រធាន! គឺពេលនោះ គឺពិតជាអ៊ីចឹងមែន អត់មានទេ អត់មាន បានសួរខ្ញុំទេ គឺចូលដល់កន្លែងឃុំឃាំងតែម្តង គឺអត់មានឃើញថត អត់មានធ្វើប្រវត្តិរូបអីទេអត់ទេ។

**ស៖** លោកទៅដល់កន្លែងនោះនៅពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺពេលយប់ ។

**ស៖** ចុះសម្លៀកបំពាក់ដែលលោកស្លៀកពាក់ទៅហ្នឹង គេទុកឲ្យលោកស្លៀកពាក់ដដែលទេ ឬក៏ គេដោះសម្លៀកបំពាក់លោកចេញ មុននឹងគេដាក់ឃុំខ្លួនលោក?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺនៅពេលនោះ គឺនៅពេលចូលបន្ទប់ឈើនោះ គឺ គេដោះសម្លៀកបំពាក់វែងអស់ហើយ ខោវែងក៏អស់ហើយ អាវដៃវែងក៏អស់ គឺនៅតែខោខ្លីទេ គេដឹក ចេញទៅ ។

**ស៖** ពេលទៅដល់កន្លែងឃុំឃាំង តើសម្លៀកបំពាក់ហ្នឹងស្លៀកពាក់យ៉ាងម៉េច លោកស្លៀក ពាក់យ៉ាងម៉េច?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺដល់កន្លែងឃុំឃាំង គឺនៅតែខោខ្លីទេ អត់មានខោ វែងទេ ។

**ស៖** កន្លែងឃុំឃាំងលោកហ្នឹង គឺនៅជាន់ក្រោមផ្ទាល់ដី ហើយជាប្រភេទ ជាបន្ទប់ឃុំឃាំងតូច សំណួរសួរថា តើលោកបានឃើញទិដ្ឋភាពនៃបន្ទប់ឃុំឃាំងផ្សេងទៀត ក្រៅពីមនុស្សម្នាក់ដែលលោក បានស្គាល់ហ្នឹង មានបន្ទប់ឃុំឃាំងអីផ្សេងទៀតច្រើនទេ នៅជិតកន្លែងឃុំឃាំងលោកនោះ?

**ឆ៖** បាទ, ជម្រាបប្រសាន៍លោកប្រធាន! គឺនៅបន្ទប់ឃុំឃាំងនោះ គឺពេលដែលចូលទៅ គឺគេ មានការចងបិទមុខហើយ មុននឹងចូលគេបិទមុខអស់ហើយ ប៉ុន្តែដាក់ខ្នោះរួចស្រួលបួល ទើបគេស្រាយ

ស្រាយមុខចេញ ក៏ខ្ញុំបានក្រឡេកភ្នែកទៅឃើញឈ្មោះ យឹម យ៉ាវ មួយគឺរស់នៅទីនោះ វាជាប់ខ្នោះដូចខ្ញុំដែរ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានក្រឡេកមើលជុំវិញ ថាកន្លែងណាដែលមានមនុស្សច្រើនតទៅទៀតទេ ព្រោះកន្លែងនោះជាបន្ទប់រួម ដែលមានចំនួនមនុស្ស បើរាប់ខ្សែជួរខ្ញុំ បើខ្ញុំតាម បើខ្ញុំបានអង្គុយមើលម្តងៗ គឺមានចំនួន១៥នាក់មួយខ្សែ ហើយខ្សែមួយទៀតទល់ជើងខ្ញុំដែរមានចំនួនតែដប់នាក់ទេ តាមការដែលខ្ញុំដឹងផុតពីនោះពុំបានឃើញទេ ។

**សៈ** អ៊ីចឹងបានន័យថា កន្លែងឃុំឃាំងរួមដែលលោកចូលទៅត្រូវគេឃុំខ្លួនដំបូងហ្នឹង គឺជាបន្ទប់ឃុំឃាំងរួមដែលមានទំហំធំ មិនមែនបន្ទប់តូចសម្រាប់ឃុំឃាំងតែមនុស្សម្នាក់ៗទេ អ៊ីចឹងមែនទេ?

[១៤:៤៣:១៥]

**ឆៈ** បាទ, អ៊ីចឹងមែន ។

**សៈ** ចុះពេលគេសួរចម្លើយ គេចាត់ការយ៉ាងម៉េចជាមួយលោក? កាលពីពេលគេនាំចេញរហូតដល់ពេលសួរចម្លើយរួច ហើយនាំយកមកវិញ គេប្រព្រឹត្តទៅចំពោះលោក ប្រព្រឹត្តចំពោះលោកយ៉ាងដូចម្តេចខ្លះ?

**ឆៈ** បាទ, តាមខ្ញុំដឹង គឺពេលដែលសួរចម្លើយ គឺឆ្មាំអ្នកយាមខាងក្រៅហ្នឹង គេបានចូលទៅដោះខ្នោះជើងចេញ ដែលមានខ្នោះជើងរួម ។ ក៏ប៉ុន្តែ មុននឹងដោះជើងខ្ញុំចេញនេះ គឺដាក់ចងអ្នកដទៃផ្សេងទៀតអស់ហើយ ព្រោះខ្សែម៉ាស្នូករួមនោះ គេដាក់រួមគ្នា ឯនេះគេចងអ្នកផ្សេងឲ្យអស់រួច ទើបគេដោះយកខ្ញុំចេញ ហើយនិងដាក់ខ្នោះជើង ដាក់ច្រវាក់ជើង បណ្តើរចេញទៅ ទើបពួកនោះគេស្រាយចំណងវិញ គេដាក់ខ្នោះទៅវិញ ។ ទើបគេចងមុខខ្ញុំបណ្តើរចេញទៅ ហើយនិងចងដៃផង ច្រវាក់ជើងជាប់ ។

**សៈ** ច្រវាក់ជើងជាប់យ៉ាងម៉េចទៅ ម៉េចដើររួចបើជាប់ច្រវាក់ជើង?

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោកប្រធាន ច្រវាក់ គឺមានវែងប្រវែងនេះ ប្រហែលជាប្រាំ ទៅប្រាមួយ ប្រាំពីរតឹក ហើយមានក្រវង់ទាំងសងខាង គេអាចបើកបញ្ចូលបានដាក់ខ្នោះទាំងសងខាងទៅយើងអាចដើរបាន ។

**សៈ** ដើរដោយអូសច្រវាក់នឹងដី ឬក៏នឹងឥដ្ឋអ៊ីចឹង?

[១៤:៤៥:០០]

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ដោយដាក់ជើងទាំងសងខាងដើរអូសដីទៅ ។

**សៈ** កន្លែងសួរចម្លើយ គេនាំលោកទៅសួរចម្លើយនៅកន្លែងណា លោកចាំទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកប្រធាន! គឺថាកន្លែងសួរ ខ្ញុំមិនដឹងថាកន្លែងណា នៅជាកន្លែងណានោះទេ ព្រោះថា ការដើរទៅវាមានច្រវាក់ជើងជាប់ផង ឯមុខក៏ចងជាប់ ឯដៃក៏ចងជាប់ មុខក៏មិនអាចមើលទៅឆ្វេង មើលស្តាំមើលឃើញថាកន្លែងណានោះទេ ។ ក៏ប៉ុន្តែ ចូលទៅដល់ក្នុងនោះ គេចងរួចស្រួលបួល គេបិទទ្វារជិត ដែលមានបង្អួចខ្ពស់ៗមិនអាចមើលឃើញទេ មើលឃើញទេ បើមើលៗឃើញតែលើ មើលឃើញតែមែកឈើ ។ ក៏ប៉ុន្តែ ត្រង់ទីទៃទៅទៀត គឺមិនមើលឃើញទេ គឺថា ចងរួចហើយទើបស្រាយមុខចេញ ។

**ស៖** ចម្ងាយប្រហែលជាប៉ុន្មានម៉ែត្រពីកន្លែងគេឃុំឃាំងលោក?

**ឆ៖** បាទ, តាមការស្មាន វាដើររយៈពេលតិចដែរទេ បើជារាប់ជានាទីមិនដល់ជា ប្រាំនាទីទេដល់ហើយ ព្រោះដើរមួយភ្លែតទេ ។

**ស៖** ប្រហែលជាប៉ុន្មានម៉ែត្រដែរ? ឬក៏ប៉ុន្មានជំហានដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ប្រហែលជា បើរាប់ជាជំហាន បើខ្ញុំមិនស្មានមិនខុសគឺប្រហែលជាមួយរយជំហានតែប៉ុណ្ណោះទេ ។

**ស៖** កន្លែងសួរលោកហ្នឹង គេសួរនៅកន្លែងជាន់ផ្ទាល់ដី ឬក៏នៅជាន់ទីមួយ ជាន់ទីពីរ ជាន់ទីបី?

**ឆ៖** ជម្រាបប្រសាសន៍! គឺនៅផ្ទាល់ដីទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់សម្រាក ។ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី រហូតដល់ម៉ោងបី ចាប់បន្តដំណើរការសួរដេញដោលតទៅទៀត ។ មន្ត្រីតុលាការសម្របសម្រួលរកកន្លែងសមរម្យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានសម្រាក ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៨នាទី ដល់ម៉ោង ១៥:០៥នាទី]*

**សួរបន្តដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសកិច្ចបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គោគ ខន តទៀត ។

**ស៖** ភោគ ខន លោកបាននិយាយរៀបរាប់ជូនដល់អង្គសវនាការរួចហើយថា លោកត្រូវបានបុគ្គលិកដែលធ្វើការនៅកន្លែងដែលគេឃុំឃាំងលោកនោះ បានសួរចម្លើយ ហើយនិងមានការប្រើអំពើហិង្សាលោក រហូតដល់លោកសន្លប់ផងទាំងពីរដង ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺអ៊ីចឹងមែន ។

**ស៖** ហើយអ្នកសួរចម្លើយហ្នឹង លើកទីមួយហ្នឹងមានពីរនាក់ ហើយមានវត្តមានម្នាក់ទៀតអង្គុយនៅទីនោះដែរ គឺបងខាងកើត ។ លោកបានឆ្លើយថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺពិតជាអ៊ីចឹងមែន ។

**ស៖** ក្នុងអំឡុងពេលដែលគេសួរចម្លើយលោកដោយបង្ខំនោះ តើគេប្រើអំពើហិង្សាចំពោះលោកហ្នឹងយ៉ាងដូចម្ដេចទៅ? យ៉ាងដូចម្ដេចខ្លះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធានគឺ ការធ្វើអំពើហិង្សាពេលនោះគឺ ការវ៉ៃនឹងខ្សែតីខ្សែតីតែមួយខ្សែ វ៉ៃផ្លាស់ប្ដូរគ្នាពីរនាក់ វាវ៉ៃរហូតទាល់តែខ្ញុំទន់ខ្លួន លែងដឹងខ្លួនអ្វីទាំងអស់ ។

**ស៖** ចុះនៅក្នុងការសួរចម្លើយលើកទីពីរ តើគេប្រើអំពើហិង្សាទៅលើលោកដោយរបៀបណា? ដោយមធ្យោបាយអ្វីដែរ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ គឺលើកទីពីរក៏របៀបតែមួយដែរ ។

**ស៖** បានសេចក្ដីថា គេវាយលោកនឹងខ្សែតីដូចលើកមុនដដែល ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែន ។

**ស៖** ហើយក្នុងអំឡុងពេលដែលគេវាយលោកនឹងខ្សែតីហ្នឹង តើលោកដេក ឬក៏លោកអង្គុយ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺការដែលគេធ្វើវ៉ៃទារុណកម្មនឹងខ្សែតីហ្នឹង គឺចងដៃទៅក្រោយ ចងជើង ឲ្យដេកផ្កាប់មុខ ។

**ស៖** នៅក្នុងអំឡុងពេលគេសួរចម្លើយហ្នឹងគេមានបានរុំមុខលោកដែរឬទេ?

**ឆ៖** បាទ, អត់ទេ ។

[១៥:០៧:៥៤]

**ស៖** ខ្នោះ ឬក៏ច្រវាក់ដែលគេដាក់ពីកន្លែងនាំលោកពីកន្លែងឃុំឃាំង ទៅកន្លែងសួរចម្លើយហ្នឹងទៅដល់ហ្នឹងគេមានការផ្លាស់ប្ដូរទេ ប្ដូរខ្នោះទេ ឬក៏ប្រើច្រវាក់ដដែល ដែលបានដាក់លោកនាំបណ្ដើរចេញពីកន្លែងឃុំឃាំងទៅកន្លែងសួរចម្លើយនោះ?

**ឆ៖** បាទ, គឺថាពេលបណ្ដើរទៅគេដាក់ច្រវាក់ខ្នោះជើងដើរទៅ ទៅដល់ពេលនោះគឺគេចងមុខ ដល់ពេលនោះគេបិទទ្វាររួចបញ្ចូលក្នុង គឺគេដោះខ្នោះចេញ និងដោះខ្នោះជើងចេញ គេស្រាយចំណង ពីត្រឹមគន្លាក់ដៃ លើគន្លាក់ដៃយើងចេញទៅ ទើបគេផ្លាស់ប្ដូរមកចងឯកដៃវិញ ហើយនិងគេចងជើង នឹងខ្សែ ។

**ស៖** អ៊ីចឹងគេចងជើងលោកនឹងខ្សែ ។ ខ្សែអីគេ? ចងជើងមួយ ឬក៏ជើងទាំងពីរជាប់គ្នា ឬក៏ចង ជើងតែមួយ ហើយចុងខ្សែម្ខាងទៀតចងទៅជាប់នឹងអីទៅ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺគេចងជើងទាំងពីរដោយខ្សែអង្រឹងៗ ហើយឯ ដៃចុងខ្សែគេយកមកចងភ្ជាប់នឹងកដៃទាំងសងខាង ។

**ស៖** នៅក្នុងការសួរចម្លើយហ្នឹង តើមានមនុស្សផ្សេងទៀត មនុស្សទីបី ឬក៏បងខាងកើតហ្នឹង បានសួរចម្លើយលោកដោយផ្ទាល់ដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺការសួរចម្លើយជាលើកទីមួយ គឺខ្ញុំបានដឹងថាមាន តែឈ្មោះហ៊ា និងឈ្មោះ សេង ទេដែលជាអ្នកវ៉ៃ ហើយពេលនោះក៏ឮឈ្មោះ ហ៊ា គេហៅថា “សេង បង ខាងកើតគាត់អញ្ជើញមកហើយ” ។ ខ្ញុំក៏មិនដឹងថា បងខាងកើតនោះជាអ្នកណាទេ ប៉ុន្តែ គាត់ដើរអួស បញ្ឆិតក្បាលខ្ញុំទៅ គាត់អង្គុយនៅកៅអីហ្នឹងទៅ ។ ឯខ្ញុំបានក្រឡេកតែកន្ទុយភ្នែកបន្តិចទេ ព្រោះថា ការ ឈឺផ្សាពេញខ្លួន ក៏មិនបានស្គាល់ថា បងខាងកើតនោះជាអ្នកណា ឬក៏ ឌុច ដូចបានស្គាល់សព្វថ្ងៃនេះទេ ដែលខ្ញុំបានស្គាល់ថា បងខាងកើតនោះជាអ្នកណា ។ ពេលនោះគឺអត់ទេ អត់មានស្គាល់ទេ ។

**ស៖** បងខាងកើតហ្នឹងបានសួរចម្លើយលោកដោយផ្ទាល់ដែរឬទេ?

**ឆ៖** បាទ, ពេលនោះតាមខ្ញុំចាំ គឺមិនបានសួរទេ ។

**ស៖** គាត់មានបានបញ្ជាកូនចៅរបស់គាត់ឲ្យធ្វើអ្វី ប្រព្រឹត្តអំពើអ្វីទៅលើខ្លួនលោកដែរឬទេ?

**ឆ៖** បាទ បើពេលដែលខ្ញុំបានដឹងថា បងខាងកើតគាត់ទៅអង្គុយនោះគឺ គាត់មិនបានបញ្ចេញ ជាវាចារថា អ្នកឯងសួរខ្ញុំឲ្យឆ្លើយពីនេះ ឬក៏ឆ្លើយពីនោះ ពីរឿង *សេអ៊ីអា* ឬក៏អ្វីផ្សេងនោះ គឺគ្មានទេ គឺគ្រាន់តែអង្គុយមួយសន្ទុះ ដែល ហ៊ា និង សេង នេះគេបានវ៉ៃខ្ញុំរួចទៅ គឺគាត់ក្រោកឡើង ស្របពេលនឹង ខ្ញុំលែងដឹងខ្លួនអ្វីទាំងអស់ទៅហើយ ។ ប៉ុន្តែ អាចឮនៅតិចៗ គឺស្នូរជើងធាក់ខ្ញុំក្បាលមួយជើងតែប៉ុណ្ណោះ ទេ ប៉ុន្តែមិនដឹងជាបងខាងកើត ឬក៏ សេង និង ហ៊ា នោះទេ ។

[១៥:១១:១៧]

**ស៖** ក្រៅពីការប្រើអំពើហិង្សាទៅលើលោកផ្ទាល់នៅក្នុងអំឡុងពេលសួរចម្លើយពីរដង តើមានការប្រើអំពើហិង្សា ឬក៏ប្រព្រឹត្តយ៉ាងម៉េចដោយមន្ត្រីនៃកន្លែងដែលឃុំឃាំងលោកហ្នឹង ទៅលើលោកផ្សេងទៀតដែរឬទេ ឬក៏តែពីរដងនុ៎ងទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺការប្រើអំពើហិង្សាគឺមានចំនួនតែពីរដងប៉ុណ្ណោះឯងទេ ។

**ស៖** លោកបាននិយាយរៀបរាប់ថា លោកត្រូវគេវាយជាមនុស្សក្នុងចំណោមមនុស្សពេលដែលនាំទៅវាយហ្នឹងគឺមានបីនាក់ ហើយលោកជាមនុស្សទីបី ហើយថាវាយទៅលោកក៏គេច ហើយត្រូវដងខ្លួន ត្រូវឯឆ្អឹងជំនី ហើយក៏ដួលសន្លប់ចូលទៅក្នុងរណ្តៅនៃសាកសពរួម ហើយក្រោយមកលោកបានដឹងខ្លួន ហើយប្រឹងប្រវេប្រវា ហើយរហូតដល់លោកបានធ្វើដំណើរចេញពីទីនោះ ហើយលោកអះអាងថាថ្ងៃនោះគឺថ្ងៃ០៦ ពីព្រោះព្រលឹមឡើងភ្លឺស្រាង១ នៅពេលដែលងើបចេញ-- វារចេញពីរណ្តៅសពរួមនោះក៏បានឮកាំភ្លើងចេញពីទិសខាងកើត គឺពីទិសអរិយក្សត្រ ឬក៏ពីទិសខាងកើតនៃស្ពានមុនីវង្ស ។ នេះលោកបានឆ្លើយអ៊ីចឹង នេះតាមយើងស្តាប់បានពីដែលលោកបាននិយាយរៀបរាប់ តើរឿងហ្នឹងពិតអ៊ីចឹងដែរទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺពិតជាអ៊ីចឹងមែន ។

**ស៖** សំណួរសួរថា លោកបានចាកចេញពីទីជើងឯក លោកអះអាងថា កន្លែងដែលគេយកលោកទៅសម្លាប់នោះ ពីរណ្តៅសពរួមហ្នឹង លោកបានធ្វើដំណើរទាំងលំបាក ដោយអស់កម្លាំងផង ដោយត្រូវនឹងគេវាយផង គឺបានទៅដល់ទន្លេ ។ សួរថា លោកដើរទៅតាមមធ្យោបាយយ៉ាងម៉េចទៅ បានជាលោកដើរពីទីកន្លែងដែលគេនាំទៅសម្លាប់នោះរហូតដល់មាត់ទន្លេ? ហើយបើដល់មាត់ទន្លេ ទន្លេនុ៎ងទន្លេងអីទេ បើលោកថាស្គាល់ច្បាស់ ថាដល់ទន្លេ កន្លែងនោះគឺជានាំឲ្យលោកអាចគិតថា រស់រានមានជីវិតហើយ ពីព្រោះដល់គោលដៅដែលលោកបានស្គាល់ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺពេលនោះគឺខ្ញុំធ្វើដំណើរអស់រយៈពេលយូរដែរ ចាប់ពីជើងឯកទៅ ក៏ប៉ុន្តែ ពេលនោះមិនដឹងថាទិសទៅខាងណាទេ វារយៈពេលយូរដែរហើយ រហូតមកដល់ទន្លេហ្នឹងបានខ្ញុំដឹងថា ទឹកហូរទៅខាងណា ឬមួយក៏ទៅខាងត្បូង ឬក៏ទៅខាងជើង ព្រោះពេលណាតែទឹកហូរ បើទន្លេសាប ឬក៏ទន្លេមេគង្គយើង ទឹកហូរទៅលិច ដឹងតែទៅលិចហើយ ព្រោះខ្ញុំដឹងថា ទិសទៅលិចវាទៅស្រុក ទៅភូមិកំណើតរបស់ខ្ញុំ គឺឬនៅ អាចទៅដល់កំពង់ឆ្នាំង ក៏អាចនឹកសង្ឃឹមថា បានជួបបងប្អូនខ្ញុំនៅទីនោះដែរ ។ អ៊ីចឹងហើយក៏ការស្មានខ្ញុំអាចទៅបាន អាចបណ្តែតទៅតាមបណ្តោយតាម

ទន្លេនេះ ។

[១៥:១៤:៤៤]

**ស៖** លោកចាំទេ ទន្លេដែលលោកទៅជួបហ្នឹង ទន្លេដែលមានស្ពានមុនីវង្ស ឬក៏ទន្លេណាផ្សេង ពីព្រោះលោកអះអាងថា ជើងឯក បឹងជើងឯកនៅឯណោះជិតតាខ្មៅឯណោះ នៅខាងជិតព្រៃស ជិតតាខ្មៅឯណោះចម្ងាយពីនេះជាងដប់គីឡូពីភ្នំពេញ ។ អ៊ីចឹងបានសំណួរសួរថា លោកទៅជួបទន្លេហ្នឹងទន្លេបាសាក់ ឬក៏ទន្លេសាប ឬក៏ទន្លេមេគង្គ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺពេលនោះថា ខ្ញុំបាទដើរផង លូនផង ក្រាបផង រហូតមកដល់ទន្លេហ្នឹង ខ្ញុំអាចសន្និដ្ឋានបានថា វាជួរបួនមុខនេះដែរ តែជិតៗទន្លេបួនមុខនោះ ព្រោះឆ្ងាយគ្រាន់ដែរ ប៉ុន្តែអាចទន្លេបួនមុខ ។ ខ្ញុំប៉ាន់ស្មាន គឺទន្លេសាប ព្រោះខ្ញុំស្គាល់ជួរនោះទន្លេសាបហើយ ។ ទន្លេសាបធ្លាក់ទៅទន្លេសាប ។

**ស៖** ទន្លេបួនហ្នឹង កន្លែងមុខវាំងហ្នឹងឯង ហើយមុខវាំងហ្នឹងមន្ទីរ៨៧០ នៅទីនោះ ។ បានន័យថាសន្តិសុខជំនាន់ ប៉ុល ពត ហ្នឹង គេតឹងតែង ទន្លេម្តុំបួនមុខហ្នឹងឯង ពីព្រោះសុទ្ធតែជាមជ្ឈមណ្ឌលនៃអង្គការចាត់តាំងជាន់ខ្ពស់បំផុតរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ម៉េចបានទៅលោកអាចទៅឈរ ឬក៏ទៅនៅទីនោះបាន?

[១៥:១៦:១២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពេលនោះ គឺជាពេលវឹកវរហើយ ក៏ពួកនេះរត់អស់ គឺស្ងាត់ហើយ ។ ពេលស្ងាត់ហើយ ខ្ញុំទៅនោះ ក៏អត់មានមនុស្សទេ គឺមានតែសន្ទឹកកាណូត ពួកវៀត-ណាម ហើយនិងកងទ័ព១៧៩ គឺកងទ័ពរណសិរ្សរំដោះជាតិចូលមកទេ ។ ពេលនោះ គឺនៅទីក្រុងភ្នំពេញ គឺរត់ចេញអស់ហើយ ទ័ពទាំងប៉ុន្មាន គឺស្ងាត់ ។ ឮសូរតែកាណូតតាមទន្លេ ឬក៏អូប័រ អីផ្សេងៗហ្នឹងទ័ពវៀតណាមទេ ។

**ស៖** ហើយដឹងអ៊ីចឹងដែរ លោកម៉េចក៏មិនធ្វើដំណើរតាមផ្លូវគោក ព្រោះផ្លូវទឹកហ្នឹង ទន្លេមេគង្គហ្នឹងវាដូចជាគ្រោះថ្នាក់ ទន្លេមុខវាំងនេះ មានអ្នកណាទៅហ៊ានឆ្លងកាត់ ។ ហើយខែមួយ ខែមករា បើនិយាយវាគិតខែមករា វាជារដូវទន្លេសាប ត្រូវហូរចេញពីទន្លេសាប ព្រោះទឹកស្រក ចាប់ផ្តើមនូវរដូវនេសាទ វាមិនអាចហូរចូលបានទេ ។ ទន្លេហ្នឹងហូរចូលបានតែខែដប់ ខែប្រាំបួនអីទេ ដែលវាចូលនៅរដូវទឹកឡើង តែរដូវទឹកស្រកហើយ មានទៅហូរអី មានតែហូរចេញមកខាងណោះ ។ ម៉េចលោកហែល

ក្ដារម៉េចទៅបញ្ច្រាសទឹកម៉េចកើត?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! បញ្ជាក់ឲ្យច្បាស់ គឺថា ខ្ញុំក៏វាតាមដែលខ្ញុំចាំហើយ គឺវាមានបន្ទះក្ដារ ខ្ញុំមិនបានហែលនៅតាមកណ្ដាលទន្លេនោះទេ គឺគៀនៗ សសៀរៗតាមព្រៃទេ រហូតទៅដល់ហួស ខ្ញុំគ្រាន់តែហែលតាមទន្លេយើងហ្នឹង វារយៈពេលប្រហែលជាពីរបីថ្ងៃ ទើបបានឆ្លងផុតស្ពានជ្រោយចង្វា ខ្ញុំអាចដឹងថា អំស្ពានជ្រោយចង្វា ។ មកជិតកន្លែងអង្គភាពចាស់ខ្ញុំនៅ គឺនៅខាងជិតស្ពានជ្រោយចង្វានេះ ខ្ញុំដឹង អាចដឹងត្រឹមនោះ ។ ដឹងថា ស្ពានជ្រោយចង្វា គឺជាផ្លូវទៅទន្លេសាប ឬក៏ទៅកំពង់ឆ្នាំង ។

**ស៖** យើងបញ្ជាក់បន្តិច ។ កាលពីនៅក្នុងពាក្យបណ្ដឹងរៀបរាប់អំពីអង្គហេតុនៃការប្ដឹងរបស់លោក លោកបានរៀបរាប់ថា នៅក្នុងខែតុលា ឆ្នាំ១៩៧៨ លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រធានគុកទួលស្លែង បានបញ្ជាកូនទាហានឲ្យខ្ញុំទៅសួរចម្លើយម្ដង ។ តែខ្ញុំដើរមិនរួច គេបានយកអង្រឹងសែងខ្ញុំទៅជួប ឌុច ។ មានរឿងហេតុនេះដែរឬទេ? ដូចជាឆ្លើយអំមិញ ទាំងរៀបរាប់ខ្លួនឯង ទាំងការឆ្លើយផងដូចមិនមានបង្ហាញអំពីអង្គហេតុនេះទេ ហើយសួរបញ្ជាក់ហើយម្ដងហើយ ម្ដងទៀត ដូចអត់មានទេ ។ ប៉ុន្តែ នៅក្នុងឯកសារដែលដាក់មកនៅក្នុងរបស់លោក បានសរសេរហ្នឹងយ៉ាងច្បាស់លាស់ ។ តើមានរឿងអីចឹងដែរទេ?

[១៥:១៩:០៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺជាការកន្លងយូរហើយ ក៏ខ្ញុំអាចភ្លេចដែរ ប៉ុន្តែការភាន់ច្រឡំ ឬក៏ការភ្លេចភ្លាំងទេ ហេតុដូច្នេះ ខ្ញុំមិនបានស្គាល់ថា កាំង ហ្គេកអ៊ាវ ឬហៅ ឌុច នោះទេ ។ ពេលនោះ ប៉ុន្តែការសួរ គឺខ្ញុំអាចច្បាស់ថា ពេលនោះ គឺមានតែពីរទេ ហើយនិងថ្ងៃក្រោយមកទៀត-- ថ្ងៃទីមួយហ្នឹងមានបងខាងកើតគាត់ហ្នឹង ទៅពិតមែន ។ ក៏ប៉ុន្តែ ការសែង ការអីនោះ ខ្ញុំដូចជាភ្លេចហើយ ព្រោះមិនបានចាំច្រើនទេ ។

**ស៖** សំណេរបន្តលោកបានសរសេរថា ឌុច បានគំរាមខ្ញុំថា “ឯងចង់ស្លាប់ដូចប្រពន្ធឯង ឬយ៉ាងណា?” បន្តទៀត “បន្ទាប់មក ឌុច បានបញ្ជាឲ្យមិត្ត ឡាច និងមិត្តលៀប ធ្វើទារុណកម្មបញ្ច្រកទឹកខ្ញុំឈ្លក់ទឹកនិយាយមិនរួចទើបយកទៅដាក់គុកវិញ” ។ នេះជាចម្លើយឯកសារ ដែលឯងរៀបរាប់នៅក្នុងពាក្យបណ្ដឹង បង្ហាញអំពីអង្គហេតុដែលនាំឲ្យមានការប្ដឹង ។ ប៉ុន្តែ ការបង្ហាញអម្បាញ់មិញជូនដល់អង្គសវនាការ គឺយើងបានសួរបញ្ជាក់ម្ដងហើយម្ដងទៀតពុំមានអង្គហេតុនេះទេ ។ តើវាមានអង្គហេតុនេះទេ

ឬក៏មិនមានទេ?

**ឆ៖** បាទ, តាមខ្ញុំច្បាស់ដូចជាមិនមានទេ ។

**ស៖** យើងអានបន្តទៀតនៅក្នុងពាក្យបណ្ដឹងរបស់ឯងដែលបង្ហាញអំពីអង្គហេតុ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ សភាពការណ៍ច្របូកច្របល់-- វិច្ឆិកា នៅឆ្នាំ១៩៧៨ សភាពការណ៍ច្របូកច្របល់ នៅវេលាម៉ោងប្រាំមួយល្ងាច ឌុច បានប្រមូលអ្នកទោសទាំងអស់ តម្រង់ជួរយកទៅសម្លាប់ ។ គេយកអ្នកខាងមុខទៅសម្លាប់មុន ចំណែកខ្ញុំទៅនៅក្រោយគេ ដោយយប់ងងឹតមើលមិនឃើញ ខ្ញុំបានប្រាសខ្លួនធ្លាក់ទៅក្នុងទឹកស្រះក្បែរនោះសម្ងំក្នុងទឹកយ៉ាងយូរ តែគ្មានអ្នកណាចាប់អារម្មណ៍ទេ ។ ប្រហែលម៉ោងមួយយប់ខ្ញុំបានឡើងរបងទាំងដៃជាប់ចំណង ចេញតាមគុម្ពចេកមកដល់មាត់ទន្លេ មានក្តារមួយឆ្លងទៅត្រើយខាងកើតស្នាក់នៅម្តុំព្រៃខ្មែរ ជាមួយអ៊ំម្នាក់ឈ្មោះ ជូ ។ ពេលថ្ងៃគាត់បានជួយលាក់ខ្ញុំក្នុងព្រៃ ពេលយប់ចូលមកដល់ក្នុងផ្ទះ រហូតដល់ថ្ងៃ៧ មករា ៧៩ ជាថ្ងៃរំដោះ ទើបខ្ញុំបានត្រលប់ទៅស្រុកកំណើតវិញ ។

នេះជាភាពខុសគ្នាដាច់ឆ្ងាយ រវាងការដែលលោកបានឆ្លើយ អំពីអង្គហេតុដែលចំពោះមុខអង្គសវនាការអម្បាញ់មិញនេះ គឺជាក់លាក់ថ្ងៃ៦ រហូតដល់មានផ្ទុះអាវុធ នៅទិសខាងកើត ។ ហើយអំមិញបានបញ្ជាក់ថា ទៅដល់មុខវាំងហ្នឹងគឺ ក៏ពួកហ្នឹងរត់ខ្ចាត់ខ្ចាយអស់ហើយ បានជាលោកទៅដល់ ។ ប៉ុន្តែសំណេរកាលមុន គឺបានសរសេរច្បាស់លាស់ ហើយក៏អង្គជំនុំជម្រះខ្ញុំខ្លួនឯងមិនយល់ដែរថា ដល់មាត់ទន្លេហ្នឹងមានក្តារមួយឆ្លងទៅត្រើយខាងកើតទៅស្នាក់នៅម្តុំព្រៃខ្មែរ ហើយព្រៃខ្មែរជិតកំពង់ឆ្នាំងឯណោះ ហើយទៅឆ្លងទន្លេឯណោះ ទៅនៅឯព្រៃខ្មែរឯណោះ ។ មាន១អង្គហេតុហ្នឹងទេ? អង្គហេតុដែលយើងអានអម្បាញ់មិញនេះមានទេ? ឬក៏អង្គហេតុណាមួយនៅក្នុងចំណោមអង្គហេតុពីរ ដែលលោកបានឆ្លើយ និងអង្គហេតុដែលយើងអាននេះ អង្គហេតុណាមួយដែលច្បាស់លាស់?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! គឺអង្គហេតុនេះ គឺវាដែលច្បាស់លាស់ជាងគេគឺអង្គហេតុដែលខ្ញុំបានឆ្លើយនេះ ។

[១៥:២៣:១៥]

**ស៖** លោកចេះអក្សរទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ចេះតើ ។

**ស៖** ចុះកាលដែលរៀបរាប់នូវពាក្យបណ្តឹង របស់លោកដែលគេបានសរសេររៀបរាប់ហ្នឹង អំពីអង្គហេតុនៃបណ្តឹងហ្នឹង លោកធ្វើដោយខ្លួនឯង ឬក៏អ្នកណាជាអ្នកធ្វើឲ្យលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺកាលដែលធ្វើជាអង្គហេតុនេះ គឺនៅក្នុងភូមិរបស់ខ្ញុំផ្ទាល់ គឺខាងអង្គការអាដហុក បានចុះទៅស្រាវជ្រាវរក ។ ហើយបានធ្វើសម្ភាសន៍ជាមួយខ្ញុំផ្ទាល់នៅលើផ្ទះ ហើយបានធ្វើក៏ប៉ុន្តែត្រង់ណោះ ខ្ញុំដូចជាមិនបានរៀបរាប់ប្រាប់គាត់ទេ ពេលខ្ញុំមើលឃើញក្នុងអង្គហេតុនេះ ខ្ញុំថាម៉េចបានជាអង្គហេតុនេះទៅអ៊ីចេះវិញ ។ ហើយចំណុចដែលខ្ញុំបានរៀបរាប់ប្រាប់គាត់ គឺនៅថ្ងៃដែលខ្ញុំគេយកទៅប្រហារ គឺខ្ញុំបានប្រាប់គាត់ថា គឺជាថ្ងៃយប់ថ្ងៃ០៦ ឆ្នាំ១៩៧៩ ។ ប៉ុន្តែវា មិនដឹងជាយប់ម៉ោងប៉ុន្មាន ព្រោះថាពេលនោះគឺពេលយប់ហើយ គាត់ក៏បានកត់ទៅ មិនដឹងជាគាត់ ដល់ពេលឃើញ ខ្ញុំក៏ឃើញថាការណ៍នេះខុសដែរ ព្រោះវាហួសពេលហើយ ខ្ញុំឃើញខុស ខ្ញុំក៏មិនបានមើលអង្គហេតុនេះ បានច្បាស់លាស់ទេ ព្រោះថា កន្លងមកការងារជីវភាពដោយវាពិបាកពេកផងទៅ ក៏ខ្ញុំក៏ចេះតែទុក ទុកតែរហូតដល់ថ្ងៃនេះក៏មិនបានជាគិតដែរ សុំទោស អភ័យទោស លោកប្រធាន ។

**ស៖** លោកជិះមានក្តារហ្នឹង ក្តារឈើអីទៅដែលថា ជិះហើយឆ្លងទឹកទន្លេមេគង្គនោះ ជាប្រភេទក្តារ ឬក៏ជាទូក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ក្តារទេ ។

**ស៖** ក្តារទំហំប៉ុនណាទៅអាចហែលទឹកឆ្លងទន្លេមេគង្គបាន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ក្តារនេះវា វាក្តារទំហំបីតឹក ក៏ប៉ុន្តែគេវៃភ្ជាប់គ្នាបីបន្ទះ វាទំហំប្រហែលជាមួយម៉ែត្រទេ ដែលខ្ញុំដាក់ទ្រាប់លើដើមទ្រូងហែលឆ្លងទៅ ។

**ស៖** ឥឡូវដល់ពេលនេះ លោកនៅប្រកាន់ថា លោកជាប់នៅក្នុងមន្ទីរស-២១ ដែលបច្ចុប្បន្នគេស្គាល់ទូទៅជាគុកទួលស្លែងទេ ឬក៏លោកប្រកាន់ជំហរថា មិនច្បាស់លាស់ថា លោកស្គាល់ច្បាស់ទេកន្លែងដែលអង្គាល់ពីគេចាប់ខ្លួនលោកមកឃុំឃាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺការចាប់ខ្លួនចូលមកទី មន្ទីរគឺអង្កាល់ណោះខ្ញុំមិនបានដឹងថាកន្លែងនេះជាស-២១ ឬក៏គេហៅថា ទួលស្លែងនោះទេ ។ ដោយយើងខ្ញុំគេចង់មុខអស់ទៅហើយ គឺចូលក្នុងបន្ទប់ឃុំឃាំង ក៏មិនអាចមើលទៅឆ្វេង មើលទៅស្តាំ ឬក៏សួរអ្នកណាថា កន្លែងនេះជាកន្លែងអ្វី ក៏ប៉ុន្តែខ្ញុំអាចសន្និដ្ឋានខ្លួនខ្ញុំថា ព្រោះការជាប់ជើងជាប់ខ្នោះហើយ គឺជាកន្លែងសន្តិសុខ ក៏ប៉ុន្តែមិនដឹងថាសន្តិសុខ២១ទេ ទើបតែដឹងនៅឆ្នាំ២០០៨ ដែលខ្ញុំបានទៅជាមួយនឹងអង្គការដែលនាំទៅស្រាវជ្រាវរកប្រវត្តិរូបបងប្រុស ហើយនិងប្រវត្តិរូបគ្រួសារខ្ញុំ ហើយក្នុងការ និងរូបខ្ញុំផ្ទាល់ ។ ក៏ប៉ុន្តែការស្រាវជ្រាវរកក៏អត់មានឃើញព្រោះតាមឃើញតែបងខ្ញុំម្នាក់ ហើយនិងគ្រួសារប្រពន្ធខ្ញុំនោះ ក៏អត់បានឃើញដែរ ។

[១៥:២៧:១៥]

**ស៖** លោកមានទិដ្ឋភាព ឬក៏រូបភាពជាសំណង់ ឬក៏ជាដើមឈើ ឬក៏អ្វីដែលជាការកត់សម្គាល់ទេនៅក្នុងអំឡុងពេលដែលលោកជាប់ឃុំ ជាពិសេសពេលដែលនាំលោកទៅសួរចម្លើយ ដែលថា លោកថាអគារក្រោមហ្នឹង តើលោកមានការកត់សម្គាល់នៅទីហ្នឹងជុំវិញហ្នឹងមានអគារអីផ្សេងដែរទេ? ឬក៏អត់មានអគារអីទេវាមានតែដើមឈើទេ? ហើយអាកន្លែងសួរចម្លើយលោកហ្នឹង គឺអគារ ជាអគារថ្ម ឬក៏អគារឈើ? ហើយមានប៉ុន្មានជាន់ដែរ?

**ឆ៖** បាទជម្រាបប្រសាសន៍លោកប្រធាន! គឺការដែលគេយកទៅសួរចម្លើយគឺអគារនោះជាអគារឈើទេដែលគេស្រាយភ្នែកហើយគឺអគារឈើ ។ ហើយនៅជាន់ផ្ទាល់ដីទេ ហើយនៅជុំវិញនោះបើតាមការក្រឡេកទៅគឺមានដើមឈើខ្លះដែរ ប៉ុន្តែវា ខ្ញុំសម្លឹងមើលទៅឃើញសន្លឹក ឬក៏ពាក់កណ្តាលដើមទេព្រោះជញ្ជាំងអាទ្វារនោះគេបិទជិតអស់ហើយ នៅតែបង្អួចខ្ពស់ដែលអាចអើត មិនអើតមើលឃើញព្រោះគេចងផ្កាប់មុខទៅហើយ វាមិនបានឃើញឆ្វេងស្តាំទេ ។

**ស៖** និយាយពីរបបហូបចុកវិញ គេផ្តល់ឲ្យលោកហូបចុកយ៉ាងម៉េចទៅក្នុងអំឡុងពេលដែលលោកជាប់ឃុំឃាំងនៅទីនោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន គឺការហូបចុកនៅទីនោះ គឺឃើញថាមានការលំបាកច្រើនដោយជីវភាព អ៎នែ របបហូបគ្មានគ្រប់គ្រាន់ គឺរបបហូបមានតែបបរាវ ។ ហើយហូបនោះក៏មិនទៀងទាត់ពេលវេលា តែបបរមួយវែកគេដាក់មួយចានធុន មួយកន្លែងហូបរួមគេដាក់មួយចានធុន គេដួសដាក់មួយចាន១ មួយវែក១១រហូតគ្រប់គ្នាទៅ គឺយើងហូបតែប៉ុណ្ណោះ មានអំបិលតែបួនដប់គ្រាប់ ឬក៏ពីរពីគ្រាន់តែប៉ុណ្ណោះឯងទេ ។

**ស៖** ចុះងូតទឹក លោកទទួលបានការងូតទឹកទេ ហើយងូតទៀងទាត់ទេការងូតទឹក ឬក៏របៀបងូតទឹកងូតយ៉ាងម៉េច?

[១៥:២៩:២៧]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺការមុជទឹក គឺវាមិនទៀតទាត់ទេ ជួនកាលគេឃើញបើតាមខ្ញុំស្មានរាប់ទៅ គឺថាមួយអាទិត្យគេអាចឲ្យងូតម្តង ក៏ប៉ុន្តែ ងូតនោះ គឺមានរបៀបរបស់គេ គឺមានក្មេងនៅការពារឃាមគុកនោះ គឺមានក្មេងអាយុប្រហែលជា១៤-១៥ឆ្នាំទេ ។ គឺគេអូសទុយោមកគេច្រូបាច់បាញ់គ្រប់គ្នាអ៊ីចេះទៅ ព្រោះថា អ្នកណាត្រូវជោកក៏ជោកទៅ អ្នកណាត្រូវមិនជោកក៏ហីទៅ

ក្អែលក៏រីកទៅកមរមាស់ពេញខ្លួន ហើយនិងចៃ យើងចៃសៗរមាស់រហូត ព្រោះថាការដេកពួនក៏គ្មានកន្ទេលគ្មានអ្វីទាំងអស់ គឺដេកផ្ទាល់ឥដ្ឋផ្ទាល់ដីតែម្តង ។

**ស៖** ឥឡូវ ងាកមកប្រពន្ធរបស់លោកវិញ ឈ្មោះពិតប្រាកដប្រពន្ធរបស់លោកឈ្មោះអ្វីទៅ?

**ឆ៖** បាទ, ឈ្មោះប្រពន្ធរបស់ខ្ញុំគឺឈ្មោះ ពិតប្រាកដគឺ ពិន លីន ឈ្មោះបដិវត្តសម័យនោះ គឺ ពិន លៀប ។

**ស៖** គាត់មានមុខរបរធ្វើអ្វីដែរ?គាត់មានមុខងារធ្វើអីកាលពីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន គឺមានមុខងារជានារីការពារកងពល៣១០ ។

**ស៖** ចុះអ្នកណាគេឈ្មោះ ទុយ លាប? លោកស្គាល់ ទុយ លាប ទេ?

**ឆ៖** បាទ,លោកប្រធានគឺ ទុយ លាប ហ្នឹងហើយជា ពិន លីន នោះ ក៏ខ្ញុំមិនបានចាំឈ្មោះឪពុកគេប្រហែលខ្ញុំដាក់ទៅដាក់ ទុយ លាប ទៅ ប៉ុន្តែតាមពិតគឺ ពិន លាប ។ ពិន លីន ហៅ ពិន លាប ។

**ស៖** កាលណោះ គាត់ទៅធ្វើការនៅអង្គភាពកាត់ដេរនៃកងពល៣១០ហ្នឹង គាត់ឈរជើងនៅកន្លែងណា?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន ។ គឺនៅឈរជើងនៅជិតអង់តែនទូរទស្សន៍ចាស់នៅទួលគោក ។

**ស៖** នៅក្នុងពាក្យបណ្តឹងរបស់លោក លោកដាក់ថា ជនរងគ្រោះឈ្មោះ ទុយ លាប ភេទស្រី អាយុ ១៩ ឆ្នាំជាប្រពន្ធ គាត់ជាប្រធានរោងចក្រតម្បាញស្ទឹងមានជ័យ ។ លោកយកចម្លើយមួយណាពិតឥឡូវហ្នឹង ក្នុងពាក្យបណ្តឹងលោកថ្លែងការណ៍ក្នុងការទាមទារដូចជាឆ្ងាយពីអ្វីដែលលោកបាននិយាយនៅទីនេះទាំងមុខងារ ទាំងទីកន្លែងអង្គភាព?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺតាមចម្លើយនេះ ព្រោះថាជាពិតប្រាកដគឺនៅអង្គភាពកាត់ដេរ៣១០ គឺពិតប្រាកដ ។

**ស៖** បញ្ជាក់មួយដងទៀតថាតើលោកប្រាកដទេថា ប្រពន្ធរបស់លោកឈ្មោះ ទុយ លាប ហើយក្រោយមកលោកថា ពិន លីន ហើយឈ្មោះបដិវត្ត ពិន លាប នោះពិតជាត្រូវបានចាប់ខ្លួន ហើយយកទៅឃុំឃាំង និងសម្លាប់នៅក្នុងមន្ទីរស-២១ ដែលបច្ចុប្បន្នហៅថា គុកទួលស្លែង ឬក៏មិនច្បាស់ទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺការចាប់ខ្លួននេះ ព្រោះបាត់ទៅក៏ខ្ញុំមិនដឹងថា ចាប់ទៅស-២១ ឬក៏ទៅកន្លែងណានោះទេ ព្រោះខ្ញុំមិនបានចាំដែរ ក៏ប៉ុន្តែការបាត់ខ្លួនខ្ញុំទើបតែជាការសន្និដ្ឋានដោយខ្លួនឯងថា បើការចាប់ខ្លួនទៅបាត់ហើយ គឺមិនអាចទៅទីណានោះទេ បើមិនព្រៃស គេហៅថាសម័យនោះ គេហៅថា ព្រៃស គឺជាតំបន់កែប្រែ ។ ខ្ញុំក៏ធ្លាប់ឮដែរថាព្រៃស ប៉ុន្តែស-២១ ខ្ញុំមិនដែលសូវបានស្គាល់ទេ ព្រោះស-២១ ខ្ញុំមិនដែលទៅបៀតដែរ ប៉ុន្តែឮៗល្បៀងគេថា ព្រៃស ប៉ុន្តែចាប់ខ្លួនទៅណានោះក៏ខ្ញុំអត់បានដឹងដែរ ព្រោះថាបាត់រហូតទៅ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ-- អំ មន្ត្រីផ្នែកខាងសោតទស្សន៍ បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍នូវឯកសារដែលមានលេខ ERN 00282314 ។

ជនជាប់ចោទពិនិត្យមើលឯកសារនេះមើល៍?

រំកិលៗទៀត រំកិលៗទៅឡើងលើទៀត ខាងមន្ត្រីសោតទស្សន៍រំកិលឯកសារឡើងលើ ដើម្បីឲ្យផុតទៅ ទៀតៗ បានហើយ ។

ជនជាប់ចោទតើឯកសារនេះយ៉ាងម៉េចដែរ? លោកកត់សម្គាល់ឃើញចំពោះឯកសារតែមួយនេះថាយ៉ាងម៉េចទៅ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះប្លែកនៅត្រង់ដែលមានអក្សរ E លេខ TSL ហើយគឺអក្សរ E នៅពីលើ E ហើយមានលេខ តើ E នោះជាស្អី ខ្ញុំទើបហ្នឹងឃើញលើកដំបូងនេះឯង ។ ក៏ប៉ុន្តែរបៀបធ្វើប្រវត្តិរូបបែបនេះ មិនមែនរបៀបធ្វើប្រវត្តិរូបរបស់ស-២១ សម្រាប់យុទ្ធជនខ្លួនឯងក៏មិនធ្វើអ៊ីចឹង សម្រាប់អ្នកទោសដែលមកជាប់ ក៏មិនធ្វើប្រវត្តិរូបអ៊ីចឹងដែរ ។ ក៏ប៉ុន្តែ សូមបញ្ជាក់ជូនលោកប្រធានថា ឈ្មោះនេ៎ះ ឈឿង ភាំ នេះមើលតាម *ហ្សាយលេប* ឃើញគាត់មកជាប់នៅនេះមែន នេះឯកសារដែលយើងខ្ញុំទទួលស្គាល់ គឺនៅក្នុងបញ្ជីអ្នកទោសស-២១ ត្រង់ទំព័រ ERN00171465 ត្រង់លេខរៀង 1213 ឈឿង ភាំ ហៅ ណេត សមាជិកវរសេនាតូច ១១៧ កងពល ៣១០ ចាប់ខ្លួននៅថ្ងៃ៣វិច្ឆិកា ១៩៧៧ ហើយយកទៅកម្ទេចនៅថ្ងៃ៧ ខែវិច្ឆិកា ១៩៧៧ ដែរ។ ដូច្នេះ នេះឯកសារដែលខ្ញុំទទួលស្គាល់នេះ ។ ឯចំណែក ឯកសារនេះ អាចដោយមកតាមហោប៉ៅរបស់ជនរងគ្រោះក៏ថាបាន ។ ក៏ប៉ុន្តែ

អក្សរ E ហ្នឹងស្អី? អក្សរ E លេខកូដពីខាងលើឯកសារនេះ ខ្ញុំអត់ទាន់ស្គាល់ទេ។ សូមអរគុណសូមបញ្ចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណជនជាប់ចោទ។ អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភោគ ខន នេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកស្រីចៅក្រម ខាតរាយច៌ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៌៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំសូមសួរសំណួរពីរបីទៅដល់លោកអំពីកាលបរិច្ឆេទ ឬក៏ការប៉ាន់ប្រមាណពីកាលបរិច្ឆេទនៃការចាប់ខ្លួន ហើយដែលគេបញ្ជូនលោកទៅស-២១ ។ តើលោកអាចប្រាប់ខ្ញុំបានទេថា លោកចាំទេថា ត្រូវកើតឡើងនៅពេលណាដែលគេចាប់ខ្លួនលោក ហើយយកទៅដល់ស-២១ ដូចដែលលោកបានប្រាប់យើងនៅថ្ងៃនេះនោះ?

[១៥:៣៩:០៤]

**ឆ៖** សូមជម្រាបលោកចៅក្រម! គឺការចាប់ខ្លួនរបស់ខ្ញុំគឺនៅ ខ្ញុំចាំមិនសូវបានទេ ព្រោះថានៅឆ្នាំ១៩៧៨ គឺចាប់នៅវ៉ារទេះភ្លើងនៅពេលល្ងាច ម៉ោងប្រាំមួយ ថាម៉ោងប្រាំទៅម៉ោងប្រាំមួយ គឺនៅវ៉ារទេះភ្លើងទួលគោក ។

**ស៖** តើលោកចាំបានទេ ថាតើក្នុងពេលណាមួយ ក្នុងរដូវណាមួយនៃឆ្នាំ ពេលដែលគេចាប់ខ្លួនលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺប្រហែលជាខ្ញុំដូចចាំមិនសូវបានដែរ ព្រោះថាវាកន្លងយូរ ហើយមិនដឹងជារដូវណាដែរ ។ សូមជម្រាបប្រសាសន៍ ។

**ស៖** បន្ទាប់ពីគេចាប់ខ្លួនលោក ហើយគេយកទៅស-២១ហើយ តើលោកអាចប្រាប់យើងអំពីកាលពេលវេលាដែលលោកចំណាយពេលនៅទីនោះ គេឃុំខ្លួនប្រហែលប៉ុនណាដែររយៈពេល?

**ឆ៖** ជម្រាបប្រសាសន៍ចៅក្រម! គឺខ្ញុំក៏មិនបានចាំខែ ចាំថ្ងៃថា ពេលនោះគឺប៉ុន្មានខែនោះទេ ក៏ប៉ុន្តែរយៈបើរាប់ទៅប្រហែលជាយូរ ស្មានទៅយូរដែរ ស្មានទៅប្រហែលបីទៅបួនខែទេ ។

**ស៖** លោកបានប្រាប់យើងពីខាងដើមថា នៅពេលដែលគេដាក់ខ្លួនឃុំខ្លួនលោកនៅកន្លែងឃុំឃាំងនោះ ហើយលោកបាននៅក្នុងបន្ទប់ជាមួយអ្នកទោសផ្សេងម្នាក់ទៀតដែលលោកស្គាល់។ តើលោកអាច

ប្រាប់យើងម្តងទៀតទេថា អ្នកនោះជាអ្នកណាដែលលោកថាស្គាល់គ្នានោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កាលដែលខ្ញុំស្គាល់នោះគឺឈ្មោះ យឹម យ៉ាវ ដែលខ្ញុំបានស្គាល់នៅអង្គភាព៣១៧។ ហើយការចាប់ខ្លួននោះគឺចាប់នៅឆ្នាំដែលខ្ញុំនៅ៣១៧ នោះគឺនៅឆ្នាំ១៩៧៧ ហើយ គឺចាប់ខ្លួននៅឆ្នាំ១៩៧៧ នេះឯង ។ គឺជាយុទ្ធជនទេ អ៎សុំទោស វាជាប្រធានកងអនុសេនាតូច ។

**ស៖** តើលោកបាននិយាយទៅរកគាត់ដែរឬទេ នៅពេលដែលលោកជាប់នៅបន្ទប់ឃុំឃាំងជាមួយគ្នានោះ?

[១៥:៤២:៣៣]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! នៅពេលនោះគឺមិនបាននិយាយរកគ្នាទេ គឺគ្រាន់តែសម្លឹងគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ឯការនិយាយស្តីគឺអត់មានសិទ្ធិនិយាយតគ្នាទេ ព្រោះនៅឆ្ងាយពីគ្នាដែរ ។

**ស៖** ថាតើមានអ្នកណាផ្សេងទៀតទេ ដែលនៅក្នុងកន្លែងឃុំឃាំងជាមួយលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍! គឺនៅទីនោះមួយខ្សែខ្ញុំនោះ បើខ្ញុំរាប់ទាំងដែលខ្ញុំស្គាល់ផង គឺមានចំនួនដប់ប្រាំនាក់ ។ ឯខ្សែទីពីរដែលទល់ជើងគ្នានោះមានចំនួនតែដប់នាក់ទេ ។

**ស៖** បើយើងបូកបញ្ចូលបញ្ជីកែតម្រូវរបស់ស-២១ គឺ 00330119 គឺមានអ្នកទោសលេខ អ្នកទោសម្នាក់លេខ12047 សូមឲ្យខាងសោតទស្សន៍បង្ហាញបញ្ជីត្រង់លេខនេះនៅក្នុងអេក្រង់ ។

សូមអភ័យទោសគឺថា មួយលេខខាងក្រោមហ្នឹងគឺ 12048 អ៊ីចឹងតើលោកអាចអានចំណុចដែលបានគូសពណ៌ខៀវមួយជួរនេះដែរឬទេ?

**ឆ៖** បាទចំណុច 12048 ឈ្មោះ យឹម យ៉ាវ ប្រធានកងសន្តិសុខ ស្រុក១៥៤ ភូមិភាគនិរតី ។ នេះដូចជាមិនមែនទេ គឺ យឹម យ៉ាវ នេះជាប្រធានកងអនុសេនាតូចនៅ៣១៧ នេះ យឹម យ៉ាវ នៅនិរតីឯណោះ ។

**ស៖** សូមអរគុណ ។ គិតថាយើងអាចធ្វើឲ្យខ្ញុំអស់ចម្ងល់ព្រោះថា យឹម យ៉ាវ កន្លែងនេះត្រូវបានគេសម្លាប់នៅខែឧសភា ឆ្នាំ១៩៧៨ ។ អ៊ីចឹងគឺថា អាចមុនពេលដែលលោក បានត្រូវគេឃុំខ្លួននៅទួលស្លែង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពិតអ៊ីចឹងមែន ។

**ស៖** សូមអរគុណ សូមឲ្យខាងសោតទស្សន៍បង្វិលរូបនេះទៅជារូបធម្មតាវិញ ។ សំណួរលោកបាននិយាយថា គេយកលោកទៅជើងឯកនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តើត្រឹមត្រូវអ៊ីចឹងទេ?

**ឆ៖** បាទ, ពិតជាត្រឹមត្រូវ ។

**ស៖** ជួនកាលការបកប្រែហ្នឹងមានការលំបាក ដូចថាខ្ញុំមិនបានយល់ភាសាខ្មែរច្បាស់ទេ អ៊ីចឹងសូមឲ្យលោកប្រាប់ខ្ញុំជាថ្មីម្តងទៀត ហេតុអ្វីបានជាលោកដឹងថា កន្លែងនោះជាជើងឯក?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការដឹងនេះពេលដែលគេយកទៅកម្ទេចនោះ ខ្ញុំក៏មិនបានដឹងថាទីនោះជាជើងឯកទេ ដោយមិនបានស្គាល់ថា ទីណានោះជាជើងឯង ឬក៏អ្វីនោះទេ គឺថាចងមុខបាត់អស់ហើយ ។ ប៉ុន្តែការទៅយកទៅដាក់នៅទីនោះគឺមានផ្ទះឈើមួយខ្នង បានន័យថា បើខ្ញុំចូលទៅគឺ តាមការស្មានដែលចងមុខទៀតគឺអាចថា ផ្ទះឈើប្រាកដនៅក្នុងកន្លែងនោះ។ ប៉ុន្តែ មិនដឹងថាទីនោះជាជើងឯកឬក៏អ្វីនោះទេ ។ សូមជម្រាប។

[១៥:៤៨:០៦]

**ស៖** ថាតើលោកដឹងពេលក្រោយមកគឺដឹងដោយវិធីណា ដែលលោកដឹងថាទីនោះជាជើងឯងនោះ?

**ឆ៖** តាមការដែលខ្ញុំបានដឹង គឺដឹងនៅរយៈពេលថ្មីៗកន្លងមកនេះហើយទេ នៅពេលដែលខ្ញុំបាទខ្ញុំធ្វើការទស្សនកិច្ច ឬក៏ចូលមកស-២១ តាមរយៈស-២១ ទើបខ្ញុំអាចដឹងថា កន្លែងជើងឯកគឺជាកន្លែងដែលខ្ញុំទៅកម្ទេចនៅថ្ងៃនោះ បានខ្ញុំអាចសន្និដ្ឋានថាជាជើងឯក ។

**ស៖** ដូច្នេះ លោកមិនបានត្រលប់ទៅជើងឯកជាថ្មីម្តងទៀត ពេលដែលលោកបានរត់ចេញពីកន្លែងនោះតាំងពីដើមខែមករា ឆ្នាំ១៩៧៩ មិនដែលបានទៅកន្លែងហ្នឹងទៀតទេ តើមែនឬទេ?

**ឆ៖** បាទ, តាំងពីពេលនោះមកខ្ញុំមិនដែលបានទៅជើងឯកនេះទេ ព្រោះថា បានមកតែមន្ទីរស-២១ ដែលគេហៅថា គុកទួលស្លែងនៅឆ្នាំ២០០៨នេះដែរ មិនដែលបានឃើញជើងឯកទេ ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេថាតើលោកបានស្គាល់ថា នៅដើមខែមករា ថាលោកបានទៅដល់កន្លែងនោះ តើលោកបានដឹងទេ នៅពេលនោះថាលោកបានទៅដល់កន្លែងនោះជើងឯកនោះ?

**ឆ៖** បាទ, តាមការដែលខ្ញុំបានដឹងចាំតិចតួច គឺថាបានទៅដល់ គឺឡានឈប់នៅឆ្ងាយដែរ គឺថាដើរទៅដល់ផ្ទះតូចនោះ គឺមានចំងាយយូរគ្រាន់ដែរ តែជិះព្រោះគ្នាច្រើន ហើយអ្នកទោសទាំងអស់នោះក៏វាមានការស្គាំងស្គមច្រើន ដើរដោយពិបាក គឺមិនបានជិតដល់ទេ គឺឈប់ឆ្ងាយគ្រាន់ដែរ ។ បើដើរបណ្តើរទៅដួលផង ត្រដាប់ត្រដួស អាអ្នកចងដឹកដូចគោនោះ រាប់ទៅប្រហែលជាដប់ប្រាំនាទី គឺដល់ផ្ទះ ។ ស្មានទៅប្រហែលដប់ប្រាំនាទីទៅដល់ផ្ទះឈើនោះ ។ ប៉ុន្តែ ខ្ញុំមិនដឹងថា ផ្ទះឈើនោះកន្លែងណាដែរ ។

**ស៖** ថាតើលោកដឹងដូចម្ដេចបានថាជាថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅពេលលោកបានថាទៅជើងឯកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺថាការដឹងនេះដោយរយៈពេលល្ងាចម៉ោងប្រាំមួយ ឬក៏ម៉ោងប្រាំពីរយប់ គេដឹកចេញទៅ ពេលល្ងាចនោះ-- ខ្ញុំមិនដឹងថាថ្ងៃនោះជាថ្ងៃទី៦ ទេ ក៏ប៉ុន្តែដល់ពេលព្រឹកឡើងដែលខ្ញុំដឹងខ្លួនឡើង ខ្ញុំដឹងថា ស្នូរអាវុធផ្ទុះ គឺនៅថ្ងៃទី២ ដែលខ្ញុំបានរួចពីរណ្ដៅ គឺខ្ញុំថារយៈពេលដែលរំដោះហើយ គេលើកឡើងថាថ្ងៃ៧ មករា ទើបបានខ្ញុំដឹងថាថ្ងៃ៧ មករា ថាថ្ងៃនោះ ។ ប៉ុន្តែដឹកអាចស្មានខ្លួនខ្ញុំថាថ្ងៃទី៦ហើយ ដែលខ្ញុំបានធ្លាក់រណ្ដៅចូលទៅក្នុងនោះ គឺថ្ងៃទី៦ យប់ថ្ងៃទី៦ ព្រឹកឡើងថ្ងៃទី៧ មករា ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ហើយសូមអរគុណដែលលោកបានអញ្ជើញមកផ្ដល់អ្វីៗដែលជា អ្វីដែរលោកបានឆ្លងកាត់សាមសិបឆ្នាំមកហើយ ។

អ៊ីចឹងសូមអរគុណលោកប្រធាន ខ្ញុំអត់មានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមសួរស្ដីអង្គសវនាការនិងដើមបណ្ដឹងរដ្ឋប្បវេណី ។ ខ្ញុំចង់សួរទៅកាន់លោកទាក់ទងទៅនឹងឯកសារ ដែលហាក់ដូចជាបង្ហាញថា បានដាក់ចូលដើម្បីគាំទ្រទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ។ ជាបឋម ខ្ញុំចង់ដឹង តើលោកមានមុខនាទីនៅក្នុងសេវាកម្មរថភ្លើងដែរឬទេ? ថាតើលោកធ្លាប់ធ្វើការនៅជាកម្មកររទេះភ្លើងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ចំណុចនេះកាលដែលខ្ញុំបានទៅធ្វើការនៅរ៉ារទេះភ្លើងនេះ គឺខ្ញុំមានមុខនាទីមួយចំនួនដែលបានដកចេញពីមន្ទីរ៣១៤ *(អត់សុំទោស)* ៣១០ ចេញទៅ គឺទៅនៅក្នុងរយៈពេលខ្លីនៅនឹងរ៉ារទេះភ្លើង គឺរយៈពេលខ្លីទេ ។ ពេលនោះ គឺខ្ញុំបាននៅហ្នឹងរ៉ារទេះភ្លើងពិតប្រាកដមែន ។

**ស៖** ថាតើលោកធ្វើការងារអ្វីនៅរ៉ារទេះភ្លើងនោះ?

**ឆៈ** កាលនោះ គឺខ្ញុំចូលថ្មីត្រូវជាខាងការ គេឲ្យនៅខាងក្តាប់ខាងវ៉ៃដែកធ្វើញញួរនៅនឹងរាំរទេះភ្លើងវ៉ៃដែក ក្តាប់កម្មករវ៉ៃដែក ។

[១៥:៥៤:២៣]

**សៈ** តើគេឲ្យលោកជាជាង ឲ្យលោកធ្វើជាងដែរឬទេ? ឬក៏គេឲ្យលោកធ្វើអ្វីដែលទាក់ទងបញ្ហាដែកអីផ្សេងៗនោះ?

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោកចៅក្រម ពេលនោះខ្ញុំមិនបានជាអ្នកជាងទេ គឺខ្ញុំគេឲ្យធ្វើនៅមើលការខុសត្រូវទីនោះជាបណ្តោះអាសន្ន ។

**សៈ** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវពីលោក នៅពេលដែលលោកប្រធានសួរទៅកាន់លោកៗបានឆ្លើយថា លោកមានឈ្មោះ ភោគ ខន ហើយលោកមិនមានឈ្មោះក្រៅពីនោះ នោះទេ ។ តើលោកដឹងអំពីឈ្មោះ ភោគ សាខុន ដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ត្រង់នេះហើយដែលខ្ញុំសូមជម្រាបប្រសាសន៍ថា ពេលសម័យនោះ ខ្ញុំមានឈ្មោះ ហើយខ្ញុំមិនបានជម្រាបថា ពីសម័យជំនាន់បីឆ្នាំនោះខ្ញុំប្រែឈ្មោះទេ ។ សម័យនោះក៏ខ្ញុំប្រែឈ្មោះពី ភោគ ខន មកពីហៅថា ភោគ សារុន ទេ គឺមិនមែន ភោគ ខុន ទេ ។

**សៈ** ថាតើខាងសោតទស្សន៍អាចបង្ហាញនៅលើអេក្រង់នូវឯកសារមួយច្បាប់ដែលមានលេខ E5/7.13 គឺ E5/7.3 លេខ ERN មាន 00282312 ។

តើលោកអាចមើលឃើញ ឬអាចធ្លាប់ឃើញឯកសារនេះតាំងពីមុនដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ឯកសារនេះវានាមត្រកូល គឺដូចខ្ញុំដែរ ក៏ប៉ុន្តែឈ្មោះគឺខុសគ្នា ។ ឈ្មោះចុង គឺខុស ។

**សៈ** ថាតើឯកសារនេះដែលត្រូវបានគេធ្លាប់បង្ហាញលោកតាំងពីពេលមុនដែរឬទេ ឬក៏លោកធ្លាប់បង្ហាញឯកសារនេះមុនពេលសវនាការនេះដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ឯកសារនេះមេធាវីខ្ញុំបានបង្ហាញខ្ញុំជាច្រើនដងដែរហើយ ប៉ុន្តែខ្ញុំមិនសន្និដ្ឋានថាឈ្មោះខ្ញុំទេ ព្រោះឈ្មោះខ្ញុំគឺ សារុន គេនេះឈ្មោះ សាខុន ។

**សៈ** ដូច្នេះអ្វីដែលលោកជម្រាបយើងខ្ញុំថ្ងៃនេះ ថាតើឯកសារមួយនេះ គឺវារៀបរាប់អំពីលោក ឬក៏មិនមែនទេ?

[១៥:៥៨:៣៨]

**ឆ៖** បាទ, ឯកសារនេះតាមមើលទៅ វាមិនមែនរៀបរាប់ពីខ្ញុំទេ ពីព្រោះថាចម្លើយឈ្មោះនេះ គឺខ្ញុំដូចជា សង្ខាក់សំងំមិនសូវស្គាល់ដែល ព្រោះខ្ញុំចូលថ្មី ព្រោះពួកនេះខ្ញុំចូទៅគឺមានស្គាល់តែបុគ្គលដែល ខ្វែង ដែលមាន-- ព្រោះចម្លើយរបស់ សុខ ម៉ាន់ គឺខ្ញុំអត់បានស្គាល់ សុខ ម៉ាន់ ទេ ខ្ញុំស្គាល់តែចំនួនប្រាពីរ នាក់ខាងក្រោមដែលមានឈ្មោះ សយ សារិន, ទី សុវត្ថា, កេត ចាគុណ, ជិនសុ ស៊ុនឡេង, ណេត សុជល, នារី តូ ស៊ីឃីម, នារី ម៉ុក សុខលីម ។ នេះក៏ខ្ញុំស្គាល់ក៏វាមិនទាន់ស្គាល់ជិតដល់មែនទែនទេ ព្រោះខ្ញុំជាអ្នកចូលថ្មី ប៉ុន្តែនារីនេះ តាមដឹងខ្ញុំបានជួបជាញឹកញាប់ ប៉ុន្តែមិនបានជាជិតស្និតទេ ព្រោះខ្ញុំអ្នក ថ្មីក្រោយ ។ ជម្រាបប្រសាសន៍ ។

**ស៖** ខ្ញុំនឹងព្យាយាមធ្វើសង្ខេបឯកសារតាមអ្វីដែលខ្ញុំយល់ តាមការបកប្រែជាភាសាអង់គ្លេស ។ ខ្ញុំជឿថា ខ្ញុំយល់ថា ឯកសារនេះជាឯកសារវិភាគទៅលើចម្លើយសារភាពរបស់បុគ្គល សុខ ម៉ុន ដែលធ្វើ ការនៅភ្នំពេញ គឺ សុខ ណាន់ នៅក្នុងតម្បាញ ត-៤ ។ ដូច្នេះ វាជាចម្លើយដែលបានដាក់បន្ទុក និងចោទ ប្រកាន់ទៅលើ ភោគ សាខុន ដែលគាត់ធ្លាប់ធ្វើការតាំងពីមុននៅរទេះភ្លើង ។ ហើយលោក ភោគ សាខុន ទទួលបន្ទុកផ្នែកជាង ហើយនៅពេលនោះ គាត់នៅតែធ្វើការងារនៅផ្នែករថភ្លើង ។ ដូច្នេះ ហើយសំណួរ របស់ខ្ញុំក៏ខ្ញុំចង់បញ្ជាក់ទៅលើចំណុចនេះ ចំពោះខ្ញុំវាហាក់ដូចជាបង្ហាញថា នៅក្នុងបញ្ជីអ្នកទោសដែល ត្រូវបានគេចាប់ខ្លួន គឺបញ្ជីអ្នកទោសដែលបានផ្តល់ដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ៦១(១) គឺមានលោក សុន ណាន់ ដែលគាត់ជាបុគ្គលិកនៅតម្បាញ ត-៤ ខ្ញុំជឿថាជាបុគ្គលតែមួយ ហើយបុគ្គល នេះត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៦ ហើយត្រូវបានគេសម្លាប់ចោលនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយបុគ្គលនេះមានលេខ 9638 ។ តើលោកស្គាល់បុគ្គល សុខ ណាន់ នេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ឈ្មោះ សុខ ណាន់ នេះខ្ញុំអត់បានស្គាល់ទេ ។

**ស៖** លោកដឹងទេថា តើឯកសារមួយនេះ បានទៅដល់ដៃមេធាវីរបស់លោកតាមរបៀបណា? ឬក៏មេធាវីអាចពន្យល់ទៅលើរបៀបដែលឯកសារនេះយកមកដាក់បញ្ចូលនៅក្នុងឯកសារទាំងអស់នេះ?

[១៦:០២:៥៦]

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន! សូមគោរពអង្គជំនុំជម្រះសាលាដំបូង ។ ខ្ញុំបាទតាងនាមឲ្យមេធាវី របស់ដើមបណ្តឹងរដ្ឋប្បវេណីសូមបំភ្លឺអង្គសវនាការពាក់ព័ន្ធទៅនឹងឯកសារនេះ ពួកយើងបាន ពួកយើងខ្ញុំ បានស្រាវជ្រាវនៅក្នុង*វេបសាយ* របស់អង្គការក្រៅរដ្ឋាភិបាល ដែលយើងហៅថាមជ្ឈមណ្ឌលឯកសារ

នៃកម្ពុជាពាក់ព័ន្ធនឹងឈ្មោះរបស់លោកអ៊ំ ដែលសរសេរថា ដែលមានឈ្មោះថា ភោគ សារុន ។ អ្វីដែលមានការកត់សម្គាល់ថា ជាឯកសារពាក់ព័ន្ធនឹងគាត់នោះ គឺពួកយើងខ្ញុំបានជូនទៅគាត់ពិនិត្យមើល គឺទីមួយ គឺមានការសរសេរដៃមិនច្បាស់ទេនៅពាក្យថា សារុន ឬក៏សាខុន បើសិនខិតចុះក្រោមជាភាសាខ្មែរ ។ ក៏ប៉ុន្តែ អ្វីដែលពាក់ព័ន្ធនឹងគាត់នោះ គឺគាត់អាចដឹងបានថា តួនាទីរបស់គាត់ជាកម្មកររថភ្លើងនៅពេលនោះ ។ ហើយលើសពីនេះទៀត គឺអ្នកដែលមានឈ្មោះនៅក្នុងឯកសារនោះ គឺគាត់ទទួលស្គាល់ថាគាត់បានស្គាល់អ្នកទាំងអស់នោះ ។

[១៦:០៤:១៤]

ហេតុដូច្នេះ ទើបយើងខ្ញុំបានបង្ហាញនូវឯកសារនេះ ហើយដោយបានស្នើសុំទៅអង្គការ *ឌីស៊ីខេម* ផ្តល់នូវឯកសារជាច្បាប់ពេញលេញមកឲ្យយើងខ្ញុំ គឺមានភ្ជាប់ជាមួយនឹងឯកសារវ៉ៃជាអង្គុលីលេខដាក់ថា ភោគ សាខុន ក៏ប៉ុន្តែការសរសេរដៃនោះគឺមើលមិនច្បាស់ថា សាខុន ឬក៏ សារុន នោះទេ ។ តែតាមការអះអាងរបស់ជនរងគ្រោះ គឺគាត់អះអាងថានេះពិតជាឈ្មោះរបស់គាត់ ទៅតាមឯកសារនេះ ។

សូមអរគុណ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

លោកប្រធាន! ខ្ញុំចង់ធ្វើការបញ្ជាក់ ហើយខ្ញុំធ្វើសង្កេតជាទូទៅនៅទីនេះ ។ លោកចៅក្រមឃើញកត់សម្គាល់ឃើញការពីម្សិលមិញផងដែរថា សាក្សីនៅចំពោះលោក លោកស្រីចៅក្រម គឺមានចម្លើយដែលមានលក្ខណៈមិនច្បាស់ ។ ដូច្នេះហើយដើម្បីដោះស្រាយទៅលើស្ថានភាពនៅក្នុងបរិបទរបស់យើង គឺសាក្សីនេះត្រូវបានសួរដោយសហចៅក្រមស៊ើបអង្កេត ហើយសហចៅក្រមស៊ើបអង្កេតអាចធ្វើការបញ្ជាក់ទៅលើឯកសារដូច្នេះ ការធ្វើដូច្នេះ គឺយើងអាចធ្វើការយល់ច្បាស់អំពីសក្ខីកម្ម ។ ហើយយើងអាចធ្វើការប្រមូលបាននូវឯកសារផ្សេងៗទាក់ទងទៅនឹងអ្នករស់រានមានជីវិតនេះផងដែរ ។

យើងធ្វើការងារទៅលើរឿងក្តីនេះ នៅពេលដែលបុគ្គលទាំងឡាយគាត់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងកត់សម្គាល់ឃើញថា ហើយកត់សម្គាល់ទៅលើរឿងក្តីមួយចំនួនដោយយើងប្រមូលឯកសារផ្សេងៗ ។ ហើយសហចៅក្រមស៊ើបអង្កេតបានបំពេញការងារមួយចំនួន ហើយយើងមិនច្បាស់ទៅលើចំណុចផ្សេងៗ ។ ដូច្នេះហើយយើងយល់ថា ចម្លើយនេះវាមានលក្ខណៈចាប់អារម្មណ៍ ហើយនៅក្នុងនេះ គឺយើងបានព្យាយាមធ្វើយ៉ាងណាប្រមូលនូវធាតុផ្សំទាំងឡាយតាមដែលយើងធ្វើទៅបាន ហើយយើងបានទៅមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ រកឯកសារ ។ ហើយនៅថ្ងៃនេះយើងកត់

សម្គាល់ឃើញថា ការកែប្រែទាំងឡាយដែលមាននៅក្នុងចម្លើយនេះ គឺវាជាចំណុចមួយដែលយើងគិតថាវាសំខាន់ ។ ហើយបុគ្គលនេះ គាត់ជម្រាបយើងអំពីការឆ្លងកាត់របស់គាត់និងបទពិសោធរបស់គាត់ ហើយយើងសូមត្រឡប់នៅលើចំណុចនេះវិញ ។

[១៦:០៧:១៦]

ចម្លើយទាំងនេះ គឺត្រូវបានប្រមូលបានដោយខាងអ្នកការពារក្ដីខាងផ្នែកសិទ្ធិមនុស្ស ហើយដែលអ្នកទាំងនោះ គឺគាត់បានទៅតាមភូមិទាំងឡាយនៅក្នុងប្រទេសកម្ពុជា ប្រមូលនូវឯកសារចម្លើយទាំងអស់នេះ ។ ហើយចម្លើយទាំងអស់នេះ គឺវាមានសម្រាប់យើង ហើយវាបានអនុញ្ញាត និងផ្ដល់ឱ្យយើងក្នុងការបង្កើតទៅលើរឿងរ៉ាវទាំងឡាយរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយយើងបានបំពេញបន្ថែមទៅលើពាក្យសុំតាំងខ្លួនរបស់ពួកគេ ។ ដូច្នេះ ហើយយើងគិតថា វាចម្លើយមួយដែលវាជាក់លាក់។

ហើយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល គឺយើងឱ្យសាក្សី គាត់លើកឡើងចម្លើយរបស់គាត់ដោយឯងៗ ហើយពេលខ្លះទៅវាមានបញ្ហាផ្សេងៗចំពោះអ្វីដែលគាត់លើកឡើងនូវបទពិសោធរបស់គាត់ ចេញពីការរៀបរាប់របស់គាត់ខ្លួនឯងនោះ ហើយចំណុចទាំងអស់នេះ គឺជាការដាក់នូវសេចក្ដីសង្កេតរបស់ខ្ញុំលើចំណុចនេះ ។

[១៦:០៨:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ទាក់ទងទៅនឹងឯកសារមួយនេះ ដែលឯកសារនេះ ត្រូវបានបញ្ចូលនៅក្នុងពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណី ហើយឯកសារនេះ គឺវាទាក់ទងទៅនឹងបងប្អូនជីដូនមួយរបស់លោក ខ្ញុំជឿដូច្នេះ ។ ហើយខ្ញុំហាក់ដូចជាមិនចាំឈ្មោះរបស់គាត់ទេ គឺឈ្មោះ ទិន ណេត ដែលជាឈ្មោះបដិវត្តន៍ ។ តើលោកអាចជម្រាបខ្ញុំដែរឬទេ? តើលោកចងចាំថា លោកត្រូវបានចាប់ខ្លួនមុនបងប្អូនជីដូនមួយរបស់គាត់ ឬក៏ចាប់ខ្លួនមុនបងប្អូនជីដូនមួយរបស់លោកនោះត្រឹមតែប៉ុន្មានខែមុនតែប៉ុណ្ណោះ?

**ឆ៖** ជម្រាបប្រសាសណ៍លោកចៅក្រម! ការចាប់ខ្លួនរបស់បងប្រុសខ្ញុំនេះ គឺនៅឆ្នាំ១៩៧៧ ប៉ុន្តែមិនដឹងខែណា គ្រាន់តែអាចចាំបានឆ្នាំ១៩៧៧ គឺមុនខ្ញុំទៀត ។

**ស៖** នៅពេលដែលគេសួរលោក នៅពេលដែលគេសួរចម្លើយលោក នៅពេលដែលគេឃុំលោក តើគេមាននិយាយជាមួយលោកអំពីបងប្អូនជីដូនមួយរបស់លោកដែរឬទេ? ហើយគេបានសួរលោកថា លោកស្ថិតនៅក្នុងខ្សែសង្វាក់របស់ក្រុមតែមួយដែរឬទេ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍ គឺនៅថ្ងៃសួរចម្លើយខ្ញុំដូចជា និយាយសាបកបន្តិចទៅចុះ នៅថ្ងៃសួរចម្លើយលើកទីពីរ គឺឈ្មោះ ហ៊ា ហើយនិងឈ្មោះ សេង គឺបានសួរខ្ញុំមួយចំណុចដែរ ខ្ញុំក៏វាភ្លេច សុំទោសលោកប្រធាន គឺគេបានសួរថា "មិត្តឯងដឹងថា ប្រពន្ធមិត្តឯងស្លាប់នៅទីណាទេ?" ។ គេសួរបញ្ជាក់ថា ស្លាប់នៅទីណា? ខ្ញុំថាពុំបានដឹងថា ប្រពន្ធខ្ញុំមិនដឹងគេចាប់នៅទីណានោះទេ ក៏ប៉ុន្តែគេឲ្យខ្ញុំឆ្លើយថា "មិត្តឯងចង់ស្លាប់ដូចប្រពន្ធមិត្តឯង ឬក៏ដូចបងមិត្តឯងដែរ" ។ នេះមានតែប៉ុណ្ណេះទេ ខ្ញុំបានបញ្ជាក់នូវការចាំបន្តិចបន្តួច ហើយភ្លេចខ្លះ អាចចាំបានតិច ។

**ស៖** ដូច្នេះ គេបានលើកឡើងអំពីឈ្មោះបងរបស់លោក ហើយគេក៏បានលើកឡើងអំពីឈ្មោះរបស់បងលោកដែរឬទេ?

[១៦:១១:៥០]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺពេលនោះគឺគេអត់បានជម្រាបឈ្មោះទេ ក៏ប៉ុន្តែគេប្រាប់ថា "ដូចបងជីដូនមួយមិត្តឯង ឬដូចប្រពន្ធមិត្តឯង បើមិត្តឯងមិនឆ្លើយមានតែផ្លូវមួយនោះឯងទេ" ។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង ។

**ស៖** ខ្ញុំអត់ដឹងថាតើលោកអាចឆ្លើយសំណួររបស់ខ្ញុំ ឬក៏លោកមិនឆ្លើយ? ដើម្បីឲ្យយើងយល់អំពីបញ្ហានេះ ។ លោកដឹងថា ឯកសារនេះ គឺយើងទទួលបានទាក់ទងទៅនឹងប្រវត្តិរូបសង្ខេបរបស់បងជីដូនមួយរបស់លោក ហើយឯកសារនេះបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើឯកសារនេះមកពីទីតាំងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏វាមកពីប្រភពណាផ្សេង?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះ ទទួល ខ្ញុំទទួលបានតាមរយៈមេធាវីដែលបានយកមកឲ្យខ្ញុំ ។

**ស៖** តើលោកបានទៅពិនិត្យមើលទួលស្លែងជាមួយនឹងមេធាវីរបស់លោកដែរឬទេ? ឬក៏ធ្លាប់ទៅជាមួយនឹងអ្នកតំណាងមកពីអង្គការផ្សេងដែរឬទេ? ដោយសារតែមុននោះលោកបាននិយាយថា នៅពេលដែលលោកទៅលេងទួលស្លែង ទៅពិនិត្យទួលស្លែងនោះ គឺលោកអាចទទួលបានឯកសារប្រវត្តិរូបសង្ខេបរបស់បងជីដូនមួយរបស់លោក ។ ប៉ុន្តែ លោកមិនបានទទួលឯកសារប្រវត្តិរូបទាក់ទងនឹងប្រពន្ធ

របស់លោកទេ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺការដែលទៅនៅស-២១នោះ គេហៅថា ទួលស្លែងនោះ ខ្ញុំទៅក្នុងឆ្នាំ២០០៨ នេះហើយទេ គឺទៅពេលនោះ គឺមានអង្គការ មេធាវីគ្មានព្រំដែន និងអង្គការ *ធីភីអូ (TPO)* ។ គេបានជូនខ្ញុំទៅមើលនៅគុកទួលស្លែង ដើម្បីស្រាវជ្រាវរកការពិត ហើយនិងរកឯកសារមួយចំនួន ។ ក៏ប៉ុន្តែ ពេលទៅនោះ ខ្ញុំក៏វារយៈពេលខ្លីដែរ ខ្ញុំមិនបានដើរឯកសារ ឬក៏រករូបថតនិងប្រវត្តិរូបរបស់គ្រួសារខ្ញុំបាទទេ គឺខ្ញុំបានពឹងពាក់ទៅលើមេធាវីដែលជាអ្នក មេធាវីការពារខ្ញុំផ្ទាល់ គឺឲ្យគាត់រក ។ ពេលនោះគាត់រកបានឃើញប្រវត្តិរូប ដែលឈ្មោះ ឈឿង ភាំ ហៅ ទិន ណេត ដែលជាបងជីដូនមួយខ្ញុំ ។ ឯចំណែកគ្រួសារខ្ញុំ ប្រពន្ធខ្ញុំនោះ ខ្ញុំរកមិនបានឃើញដែរ ព្រោះខ្ញុំទៅពេលនោះប្រញាប់ពេក ហើយម្យ៉ាងក្រោយមកទៀត ក៏ខ្ញុំមិនដែលបានមកដែរ ព្រោះថាលំនៅដ្ឋានវាឆ្ងាយ ព្រោះតែជីវភាពនិងការរស់នៅក៏លំបាក ម្លោះហើយក៏មិនបានស្រាវជ្រាវរកដែរ គឺបានមានបានតែរូបប្រវត្តិរូបរបស់បងជីដូនមួយ ខ្ញុំតែប៉ុណ្ណោះ ។

[១៦:១៥:១៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមអរគុណលោកច្រើនចំពោះអ្វីដែលលោកបានបំភ្លឺជូនយើងខ្ញុំ ទោះបីជាវាមានការលំបាកក៏ដោយ ខ្ញុំសំណួរនោះទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោក រោគ ខន ។ អង្គជំនុំជម្រះក៏បានយល់ដឹងអំពីការលំបាករបស់លោកដែរ ដែលប្រឈមនឹងការឆ្លើយនឹងសំណួរដែលសួរលោកជាច្រើន ហើយអង្គហេតុបានកើតកន្លងមកជាងសាមសិបឆ្នាំមកហើយ ។ ហើយក្រៅពីនោះ ក៏មានបរិកាសមួយដែលធ្វើឲ្យរំឭកឡើងវិញអំពីទុក្ខសោករបស់លោកនោះ ជាការប្រឈមមួយ ។ ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបថា ការដែលស្តាប់សក្ខីកម្ម សេចក្តីថ្លែងការណ៍របស់លោក បទពិសោធន៍ដែលលោកបានរស់នៅក្នុង-- ឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះមិនទាន់ចប់នៅឡើយទេ ដោយនៅភាគីផ្សេងៗទៀតមិនទាន់បានសួរសំណួរដល់លោកពាក់ព័ន្ធនឹងអង្គហេតុដែលលោកប្តឹងទាមទារ ហើយនិងត្រូវធ្វើសក្ខីកម្មនេះ ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចអញ្ជើញលោក ដើម្បីធ្វើសក្ខីកម្មបន្តនៅព្រឹកថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួន ។

ហើយមុននឹងប្រកាសបិទបញ្ចប់នេះ គឺអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីនិងសាធារណជន

ឲ្យបានជម្រាបថា អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចកំណត់កាលវិភាគសម្រាប់ដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញបន្តសម្រាប់រយៈពេលចាប់ពីថ្ងៃ១៣ ខែកក្កដា ដល់ថ្ងៃ២៦ ខែសីហា ឆ្នាំ២០០៩ ខាងមុខនេះ ដោយមានកំណត់នូវកាលវេលា និងលំដាប់ដែលត្រូវស្តាប់សក្ខីកម្មសាក្សីនិងអ្នកជំនាញ ។ អាស្រ័យហេតុនេះ ភាគីអាចរកមើលនូវព័ត៌មានស្តីពីដីកាកំណត់កាលវិភាគសម្រាប់ដំណើរការសវនាការទៅខាងមុខនៅ*វេបសាយ* នៃ អ.វ.ត.ក ។

ហើយសវនាការថ្ងៃនេះ គឺអង្គជំនុំជម្រះប្រកាសផ្អាកសវនាការត្រឹមនេះសិន ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែកចាប់វេលាម៉ោងប្រាំបួនព្រឹក ។ មន្ត្រីតុលាការសម្របសម្រួលដល់លោក ភោគ ខន ដើម្បីលោកបានរកកន្លែងសម្រាកបានសមរម្យ ហើយអញ្ជើញគាត់មកកាន់សាលសវនាការនៅស្អែកឲ្យបានមុនម៉ោងប្រាំបួន ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងប្រាំបួន នៅថ្ងៃស្អែក ។

*[សវនាការផ្អាកនៅម៉ោង ១៦:១៨នាទី]*